សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# តួនាទីព្រះរាជអាជ្ញាក្នុងការអនុវត្តសាលក្រមព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

តាក់តែងឡើងដោយ
និស្សិតឈ្មោះ កញ្ញា **មាស ស្រីឡា**
លោក **ឆាន់ ម៉េងហ៊ាង**

សាស្ត្រាចារ្យណែនាំ
**លោក ជួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **មាស ស្រីឡា** និង **ធាន់ ម៉េងហ៊ាង** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី ២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

លោកឪពុក **មាស សំណាង** និង អ្នកម្តាយ **តិន សុភា**

លោកឪពុក **នែម ធាន់** និង អ្នកម្តាយ **ភាន សាណើ**

ជាអនេកប្បការដែលលោកទាំងពីរបានផ្តល់កំណើតដល់រូបកូនព្រមទាំងខិតខំពុះពារនូវគ្រប់ឧបសគ្គ ដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូនតាំងពីមិនទាន់ដឹងក្តីរហូតដល់កូនធំ និងព្រមទាំងជួយទំនុកបម្រុងទាំងផ្នែកបញ្ញាស្មារតី និង ផ្នែកសម្ភារៈតាំងពីការសិក្សាចាប់ពីថ្នាក់បឋមសិក្សារហូតដល់ឧត្តមសិក្សា។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រី សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រទាំងអស់** ដែលបានយកចិត្តទុកដាក់ និងចំណាយពេលវេលាដ៏មានតម្លៃរបស់លោក ដើម្បីបណ្តុះបណ្តាល ចែករំលែកចំណេះដឹងដែលលោកមាន ព្រមទាំងបទពិសោធន៍ផ្ទាល់ខ្លួនក្នុងសង្គម មកបង្ហាត់បង្រៀនយើងខ្ញុំ និងមិត្តរួមថ្នាក់ទាំងអស់គ្នា គ្រប់មុខវិជ្ជាតាំងពីថ្នាក់មូលដ្ឋានរហូតដល់បានបញ្ចប់ការសិក្សា និងក្លាយជាបុគ្គលដែលមានសមត្ថភាពក្នុងសង្គម។

ជាពិសេសសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលបានដឹកនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ និងបានចំណាយពេលវេលាដ៏មានតម្លៃទាំងកម្លាំងកាយ កម្លាំងចិត្ត គំនិតប្រាជ្ញាស្មារតី ដើម្បីបណ្តុះបណ្តាល និងពន្យល់ណែនាំដើម្បីឱ្យការចងក្រងសារណាមួយនេះទទួលបានជោគជ័យ។

លោកពូ **ខា ផល្លី** ប្រធាននាយកដ្ឋានសុខាភិបាល សង្គមកិច្ច និងកិច្ចការនារី នៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានផ្តល់យោបល់ និងបានជួយកែតម្រូវអក្ខរាវិរុទ្ធដើម្បីឱ្យសារណាមួយនេះទទួលបាននូវភាពល្អប្រសើរ។

លោក **ចែ សុខ** និង លោក **សេង ហៀង** ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការផ្តល់ជាគំនិតយោបល់ទាក់ទងចំពោះការអនុវត្តជាក់ស្តែងនៃការអនុវត្តទោសរបស់ព្រះរាជអាជ្ញា ដើម្បីឲ្យសារណាយើងខ្ញុំបានសម្រេចពេញលេញចេញជារូបរាងដែលគួរជាទីមោទនៈ ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងអប់រំយុវជន និងកីឡាដែលបានផ្តល់ឱកាសដល់កុលបុត្រខ្មែរគ្រប់រូប ក៏ដូចជាយើងទាំងពីរបានសិក្សារៀនសូត្រ និងខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការពង្រឹងវិស័យអប់រំ ដើម្បីបណ្តុះនូវធនធានមនុស្សសម្រាប់ការអភិវឌ្ឍប្រទេសជាតិយើងឱ្យកាន់តែរីកចម្រើន។

ជាទីបញ្ចប់យើងខ្ញុំសូមគោរពជូនពរ **លោកអ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ឯកឧត្តម លោកជំទាវ ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកសាស្ត្រាចារ្យ ជួន ប៉ុនធី លោក លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច លោកពូ ជា ផល្លី លោកចែ សុង និង លោក សេង ហៀង** សូមឲ្យសមប្រកបជួបប្រទះតែនឹងសេចក្តីសុខ សេចក្តីចម្រើន សុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ មានកម្លាំងពលំខ្លាំងក្លា ប្រាជ្ញាស្មារតីចងចាំបានល្អ និងសូមឲ្យមានសំណាងល្អគ្រប់ពេលវេលា ជាពិសេសសូមឲ្យទទួលបានជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

ស្ថាប័នអយ្យការ សំដៅលើស្ថាប័នមួយដែលធានាក្នុងការអនុវត្តបណ្តឹងអាជ្ញាដើម្បីស្វែងរកនូវការពិតដើម្បីផ្តល់យុត្តិធម៌ដល់គ្រប់បុគ្គលដែលជាគូភាគីក្នុងរឿងក្តីព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញាជាអ្នកចាប់ផ្តើមបណ្តឹងអាជ្ញាការធ្វើបណ្តឹងអាជ្ញានេះគឺ ក្នុងគោលបំណងការពារផលប្រយោជន៍សាធារណៈ។ ទោះបីជាស្ថាប័នអយ្យការ និងស្ថាប័នតុលាការស្ថិតនៅក្នុងអង្គការតុលាការតែមួយក៏ដោយ ប៉ុន្តែស្ថាប័នទាំងពីរនេះនៅដាច់ដោយឡែកពីគ្នា និងមានតួនាទីខុសគ្នា។ អយ្យការជាភាគីនៃរឿងក្តីព្រហ្មទណ្ឌក្នុងការផ្តើមគំនិតធ្វើបណ្តឹងអាជ្ញាចំពោះបទល្មើសទាំងឡាយណាដែលប៉ះពាល់ដល់រដ្ឋ ឬ ប្រយោជន៍សាធារណៈ ដែលខុសពីស្ថាប័នតុលាការដែលជាមានតួនាទីក្នុងការជម្រះក្តី។ ដើម្បីឲ្យអយ្យការអនុវត្តនូវមុខងាររបស់ខ្លួនបានឆាប់រហ័សនិងធានាឲ្យបានប្រសិទ្ធភាពផងនោះ អយ្យការតម្រូវឲ្យមានអ្នកតំណាងរបស់ខ្លួនឲ្យមានគ្រប់នៅតាមសាលាជម្រះក្តីនីមួយៗ ហើយអ្នកតំណាងនោះជាមន្ត្រីដែលបម្រើការងារក្នុងស្ថាប័នដែលគេហៅថា ព្រះរាជអាជ្ញា ឬ តំណាងអយ្យការ។ ការរៀបចំនៃអង្គការអយ្យការត្រូវគោរពតាមគោលការណ៍សំខាន់ៗមួយចំនួនរួមមានៈ គោលការណ៍ឯកភាព គោលការណ៍អវិភាគ គោលការណ៍ឯករាជ្យ គោលការណ៍នៃការកត់សំគាល់ដោយសេរីដោយផ្ទាល់មាត់នៅពេលសវនាការ គោលការណ៍នៃការមិនទទួលខុសត្រូវ។

ក្នុងការជ្រើសរើសប្រធានបទតួនាទីព្រះរាជអាជ្ញាក្នុងការអនុវត្តសាលក្រមព្រហ្មទណ្ឌ ដើម្បីធ្វើជាសារណាបញ្ចប់ឆ្នាំសិក្សានេះដោយសារយើងខ្ញុំ ចង់ស្វែងយល់ពីគោលគំនិតសំខាន់ៗនៅក្នុងការអនុវត្តបណ្តឹងអាជ្ញាក៏ដូចជាការអនុវត្តទោសរបស់ព្រះរាជអាជ្ញាផងដែរ។ មួយវិញទៀតយើងខ្ញុំសង្ឃឹមថាសារណានេះអាចជួយផ្តល់ជាពុទ្ធិ និងអាចជាមូលដ្ឋានក្នុងការស្រាវជ្រាវសម្រាប់អ្នកជំនាន់ក្រោយ និង អ្នកសិក្សាដទៃទៀតផងដែរ។

ទន្ទឹមនឹងគ្នានេះ ចំពោះការតាក់តែងចងក្រងនូវសារណាមួយនេះគឺជៀសមិនផុតនូវភាពខ្វះចន្លោះទាំង អត្ថន័យខ្លឹមសារ ក៏ដូចជាពាក្យពេចន៍ និងអក្ខរាវិរុទ្ធ មួយចំនួនផងដែរ។

ជាចុងក្រោយ យើងខ្ញុំសូមការអភ័យទោសទុកជាមុននូវកំហុសខុសឆ្គងដែលកើតមានឡើងដោយអចេតនាក្នុងសារណាមួយនេះ និងសូមទទួលយកនូវរាល់ការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ លោក លោកស្រី ដែលជាអ្នកប្រកបវិជ្ជាជីវៈច្បាប់ សិស្សច្បង មិត្តភក្តិ និងសិស្សប្អូនដែលជាអ្នកសិក្សាច្បាប់ជំនាន់ក្រោយផងដែរ។

## មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ............ ១

**ជំពូកទី១៖**
**លំហូរនីតិវិធីនៃការចាប់ផ្តើមបណ្តឹងអាជ្ញា**

**ផ្នែកទី១៖ សញ្ញាណទូទៅនៃអង្គការអយ្យការ** ............ ៣

**កថាខណ្ឌទី១៖ ស្ថាប័នអយ្យការ** ............ ៣

១.១.មហាអយ្យការអមតុលាការកំពូល ............ ៣

១.២. មហាអយ្យការអមសាលាឧទ្ធរណ៍ ............ ៣

១.៣. អយ្យការអមសាលាដំបូងរាជធានី ខេត្ត ............ ៤

**កថាខណ្ឌទី២៖ គោលការណ៍ និងតួនាទីនៃស្ថាប័នអយ្យការ** ............ ៤

២.១. គោលការណ៍នៃស្ថាប័នអយ្យការ ............ ៤

២.១.១. គោលការណ៍ឯកភាព (គោលការណ៍ឋានានុក្រម) ............ ៤

២.១.២. គោលការណ៍អវិភាគ ............ ៥

២.១.៣. គោលការណ៍ឯករាជ្យ ............ ៥

២.១.៤. គោលការណ៍នៃការកត់សំគាល់ដោយសេរីដោយផ្ទាល់មាត់នៅពេលសវនាការ ............ ៥

២.១.៥. គោលការណ៍នៃការមិនទទួលខុសត្រូវ ............ ៥

២.២. តួនាទីរបស់ព្រះរាជអាជ្ញា ............ ៥

**កថាខណ្ឌទី៣៖ នីតិវិធីនៃការចោទប្រកាន់របស់អយ្យការ** ............ ៦

**ផ្នែកទី២៖ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់របស់អយ្យការ** ............ ៧

**កថាខណ្ឌទី១៖ ការធ្វើការចោទប្រកាន់របស់អយ្យការ** ............ ៧

១.១. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់(CD) ............ ៧

១.១.១. លក្ខខណ្ឌនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ............ ៧

១.១.១.១. ប្រភេទនៃបទល្មើសព្រហ្មទណ្ឌ ............ ៧

១.១.១.២. អត្តសញ្ញាណជនល្មើស ............ ៨

១.១.១.៣. ភាពសមល្មមដែលអាចជំនុំជម្រះបាននៃរឿងក្តី ............ ៨

១.១.២. អានុភាពនៃដីកាកោះហៅទៅជំនុំជម្រះផ្ទាល់ ............ ៩

១.១.២.១. ការផ្តាច់អាជ្ញាយុកាលនៃបទល្មើសព្រហ្មទណ្ឌ ............ ៩

១.១.២.២. ការផ្ទេរសមត្ថកិច្ចតុលាការ ............ ៩

១.១.២.៣. ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងជនជាប់ចោទ......................... ៩
១.១.២.៤. ការបង្ហាញខ្លួនរបស់ជនជាប់ចោទ........................................................ ១០
១.១.៣. លក្ខខណ្ឌសុពលភាពនៃដីកាកោះហៅទៅជំនុំជម្រះផ្ទាល់.......................................១០
១.២. នីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម (CI)........................................................ ១០
១.២.១. លក្ខខណ្ឌនៃនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម..................................................១១
១.២.១.១. បទល្មើសត្រូវតែជាបទល្មើសជាក់ស្តែង........................................................១១
១.២.១.២. អតិបរមានៃការផ្តន្ទាទោស .................................................................... ១១
១.២.១.៣. ជនជាប់ចោទជានីតិជន ......................................................................... ១១
១.២.១.៤. រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន..................................... ១២
១.២.២. អានុភាពនៃនិតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម .............................................. ១២
១.២.២.១. ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស .......................................................១៣
១.២.២.២. ការផ្ទេរសមត្ថកិច្ចទៅតុលាការ ..............................................................១៣
១.២.២.៣. ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុនិងជនជាប់ចោទ .......................១៣
១.២.៣. ការបង្វិលសំណុំរឿងពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមទៅជាការបើកការស៊ើបសួរ... ១៣
១.២.៣.១. មូលហេតុនៃការបង្វិលសំណុំរឿង...........................................................១៣
១.២.៣.២. នីតិវិធីនៃការបង្វិលសំណុំរឿង ............................................................. ១៤
១.៣. ការបើកការស៊ើបសួរ (RI) .............................................................................. ១៤
១.៣.១. លក្ខខណ្ឌនៃការបើកការស៊ើបសួរ ................................................................ ១៤
១.៣.២. អានុភាពដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ......................................................១៥
១.៣.២.១. ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស........................................................ ១៥
១.៣.២.២. ការផ្ទេរសមត្ថកិច្ចឱ្យចៅក្រមស៊ើបសួរបើកកិច្ចស៊ើបសួរ.............................. ១៥
១.៣.២.៣. ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងបុគ្គល................................ ១៦
១.៣.៣. ទម្រង់ចាំបាច់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ............................................១៦
១.៣.៣.១. ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ........................................ ១៦
១.៣.៣.២. អានុភាពនៃការមិនគោរពទម្រង់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ............ ១៧
**កថាខណ្ឌទី២៖ ការតម្កល់រឿងទុកឥតចាត់ការ**............................................................ ១៧
២.១. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលមិនមែនជាបទល្មើស.......................... ១៧
២.១.១. កង្វះធាតុផ្សំនៃបទល្មើស........................................................................... ១៧
២.១.២. អវត្តមាននៃបទល្មើស.................................................................................១៨

២.១.៣. អំពើល្មើសជាប្រភេទអំពើល្មើសតូចតាច ........ ១៨
២.១.៤. ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍ ........ ១៨
២.១.៥. មិនស្គាល់អត្តសញ្ញាណរបស់ជនល្មើស ........ ១៨
២.១.៦. អនិយ័តភាពនៃនីតិវិធី ........ ១៨
២.២. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជាបទល្មើស ........ ១៩
២.២.១. មរណភាពនៃជនល្មើស ........ ១៩
២.២.២. ការផុតអាជ្ញាយុកាលនៃបទល្មើស ........ ១៩
២.២.៣. ការលើកលែងទោសជាទូទៅ ........ ១៩
២.២.៤. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ........ ១៩
២.២.៥. អាជ្ញាអស់ជំនុំ ........ ២០

## ជំពូកទី២៖
## ការអនុវត្តសាលក្រមរបស់អយ្យការ

**ផ្នែកទី១៖ គោលការណ៍ទូទៅនៃអនុវត្តសាលក្រម** ........ ២១
**កថាខណ្ឌទី១៖ អំពីសាលក្រមព្រហ្មទណ្ឌ** ........ ២១
១.១. ការប្រកាសសាលក្រម ........ ២១
១.១.១. និយមន័យសាលក្រម ........ ២១
១.១.២. ការប្រកាសសាលក្រម ........ ២១
១.២. ប្រភេទសាលក្រមព្រហ្មទណ្ឌ(សាលក្រមអង្គសេចក្តី) ........ ២១
១.២.១. សាលក្រមចំពោះមុខ ........ ២១
១.២.២. សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ ........ ២១
១.២.៣. សាលក្រមកំបាំងមុខ ........ ២២
**កថាខណ្ឌទី២៖ ការជូនដំណឹងអំពីសាលក្រម** ........ ២២
២.១. ដីកាឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ........ ២២
២.១.១. កម្មវត្ថុនៃដីកាឱ្យដំណឹង ........ ២២
២.១.២. និទ្ទេសដែលត្រូវចុះលើដីកាឱ្យដំណឹង ........ ២២
២.២. ការទទួលបន្ទុកជូនដំណឹងអំពីសាលក្រម ........ ២២
២.២.១. ការជូនដំណឹងដែលធ្វើឡើងដោយព្រះរាជអាជ្ញា ........ ២២
២.២.២. ការជូនដំណឹងដែលធ្វើឡើងដោយអាជ្ញាសាលា ........ ២៣
២.៣. របៀបផ្សេងទៀតនៃការជូនដំណឹង ........ ២៤

**ផ្នែកទី២៖ ការអនុវត្តសាលក្រមរបស់ព្រះរាជអាជ្ញា** ........ ២៤
**កថាខណ្ឌទី១៖ ការអនុវត្តមូលទោស** ........ ២៥
១.១. ការអនុវត្តទោសពន្ធនាគារ ........ ២៥
១.១.១. វិធានទាក់ទងនឹងការឃុំខ្លួន ........ ២៥
១.១.១.១. ការគណនាចិរវេលានៃការដាក់ពន្ធនាគារ ........ ២៦
១.១.១.២. ការគិតបញ្ចូលចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ........ ២៦
១.១.១.៣. បញ្ជីជនជាប់ឃុំ និងលិខិតឃុំខ្លួន ........ ២៦
១.១.១.៣.១. បញ្ជីជនជាប់ឃុំ ........ ២៦
១.១.១.៣.២. លិខិតឃុំខ្លួន ........ ២៧
១.១.២. ដំណើរការអនុវត្តទោសនៅពន្ធនាគារ ........ ២៧
១.១.២.១. ការទទួលឱ្យចូលឃុំខ្លួន ........ ២៧
១.១.២.២. ការបែងចែកទីកន្លែងឃុំខ្លួនតាមប្រភេទទណ្ឌិត ........ ២៨
១.១.២.៣. ការផ្ទេរ ឬផ្លាស់ប្ដូរទីកន្លែងឃុំខ្លួន ........ ២៩
១.១.២.៤. សិទ្ធិ និងកាតព្វកិច្ចរបស់ទណ្ឌិត ........ ៣០
១.១.៣. ការធ្វើអធិការកិច្ចពន្ធនាគារ ........ ៣១
១.២. ការអនុវត្តទោសពិន័យជាប្រាក់ ........ ៣២
១.២.១. ការប្រមូលប្រាក់ពិន័យ និងពន្ធនីតិវិធី ........ ៣២
១.២.២. ការបង្ខំដល់រូបកាយ ........ ៣២
**កថាខណ្ឌទី២៖ ការអនុវត្តទោសបន្ថែម និងទោសជំនួស** ........ ៣៣
២.១. ការអនុវត្តទោសបន្ថែម ........ ៣៣
២.១.១. ប្រភេទនៃទោសបន្ថែម ........ ៣៤
២.១.២. ការអនុវត្តទោសបន្ថែម ........ ៣៥
២.១.៣. ការកែប្រែ ឬ ការលុបចោលទោសបន្ថែមខ្លះៗ ........ ៣៥
២.២. ការអនុវត្តទោសជំនួស ........ ៣៦
២.២.១. ការអនុវត្តការងារសហគមន៍ ........ ៣៦
២.២.២. ការអនុវត្តការស្ដីបន្ទោស ........ ៣៧
**សេចក្ដីសន្និដ្ឋាន** ........ ៣៨
**អនុសាសន៍** ........ ៣៩
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហា

ការសិក្សាមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ គឺពិតជាមានសារៈសំខាន់ និងចាំបាច់ណាស់សម្រាប់អ្នកសិក្សាជំនាញនីតិសាស្ត្រ និងអ្នកប្រកបវិជ្ជាជីវៈច្បាប់។ ដើម្បីយល់អំពីដំណើរការនៃរឿងក្ដីព្រហ្មទណ្ឌទាមទារឲ្យអ្នកសិក្សា ក៏ដូចជាអ្នកអនុវត្តត្រូវយល់ពីមួយដំណាក់កាលទៅមួយដំណាក់កាលនៃដំណើរការរឿងក្ដីព្រហ្មទណ្ឌ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក៏ដូចជាច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាក៏បានបញ្ញត្តិផងដែរថាមានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា។ ក្នុងនោះផងដែរព្រះរាជអាជ្ញាគឺជាតួអង្គមួយដ៏សំខាន់ដែលមិនអាចខ្វះបាន និងត្រូវបំពេញភារកិច្ចយ៉ាងសកម្មក្នុងដំណើរការនៃរឿងក្ដីព្រហ្មទណ្ឌរួមមាន៖ ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ការពិនិត្យលើនីត្យានុកូលភាពនៃការចោទប្រកាន់ ជាពិសេសការអនុវត្តសាលក្រម និងតួនាទីផ្សេងៗទៀតក្នុងនាមជាអ្នកតំណាង និងការពារផលប្រយោជន៍សាធារណៈ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីឲ្យយល់កាន់តែស៊ីជម្រៅនូវខ្លឹមសារនៃប្រធានបទសារណាដែលបានលើកឡើងនេះ បង្ហាញឱ្យឃើញនូវបញ្ហាគតិយុត្តមួយចំនួនរួមមាន៖

១. អ្វីទៅជាគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់របស់អយ្យការ?

២.ការអនុវត្តសាលក្រមអង្គសេចក្ដីដែលសម្រេចអំពីទោស តើព្រះរាជអាជ្ញាអនុវត្តយ៉ាងដូចម្ដេច?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវ ប្រធានបទសារណាស្ដីអំពី **តួនាទីព្រះរាជអាជ្ញាក្នុងការអនុវត្តសាលក្រមព្រហ្មទណ្ឌ** គឺក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំង និង ផ្ដល់ជាពុទ្ធិក្នុងការអនុវត្តជាក់ស្ដែងដែលទាក់ទងទៅនឹងតួនាទីរបស់ព្រះរាជអាជ្ញានៅក្នុងការអនុវត្តសាលក្រមអង្គសេចក្ដីក្នុងរឿងក្ដីព្រហ្មទណ្ឌ។

## ៤.ដែនកំណត់នៃការស្រាវជ្រាវ និងវិធីសាស្ត្រនៃការស្វែងរកឯកសារ

ចំពោះដែនកំណត់នៃការសិក្សាស្រាវជ្រាវអំពីប្រធានបទសារណានេះគឺ ផ្ដោតសំខាន់ចំពោះតួនាទីរបស់ព្រះរាជអាជ្ញាក្នុងការអនុវត្តសាលក្រមអង្គសេចក្ដីក្នុងរឿងព្រហ្មទណ្ឌ (សាលក្រមអង្គសេចក្ដីដែលសម្រេចអំពីទោស)។ ដោយហេតុថាប្រធានបទស្ដីអំពី **តួនាទីរបស់ព្រះរាជអាជ្ញានៅក្នុងការអនុវត្តសាលក្រមព្រហ្មទណ្ឌ** គឺសិក្សាទៅលើការអនុវត្តទោសរបស់ព្រះរាជអាជ្ញាដែលជាចំណុចមួយនៅក្នុងខ្លឹមសារនៃសាលក្រមព្រហ្មទណ្ឌក្នុងរឿងអង្គសេចក្ដី។

ក្នុងការសិក្សាស្រាវជ្រាវនូវប្រធានបទនេះ គឺបានធ្វើការសិក្សាស្រាវជ្រាវទៅឯកសារបទដ្ឋានគតិយុត្តមួយចំនួនរួមមាន៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ច្បាប់ស្ដីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា

ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ក្រមព្រហ្មទណ្ឌ២០០៩ ជាឯកសារគោល ព្រមទាំងឯកសារច្បាប់ សារាចរ និងឯកសារជំនួយស្មារតីនានាដែលពាក់ព័ន្ធទៅនឹងប្រធានបទ។

## ៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ចំពោះការជ្រើសរើសប្រធានបទខាងលើ មកធ្វើការសិក្សាស្រាវជ្រាវ ព្រោះថាប្រធានបទមួយនេះ ពិតជាមានសារៈសំខាន់ណាស់ចំពោះបណ្ដាអ្នកច្បាប់ អ្នកសិក្សាស្រាវជ្រាវច្បាប់ និស្សិតដែលសិក្សាច្បាប់នៅមហាវិទ្យាល័យច្បាប់នានា ដោយបានផ្ដល់ជាគំនិតយោបល់ និងផ្ដល់ជាឯកសារសម្រាប់ការសិក្សាស្រាវជ្រាវឲ្យបានស៊ីជម្រៅនៅក្នុងការអនុវត្តជាក់ស្ដែងអំពីនីតិវិធីនៃ ការអនុវត្តទោសរបស់ព្រះរាជអាជ្ញា ។

## ៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីធ្វើការឆ្លើយតបទៅនឹងចំណោទបញ្ហាគតិយុត្តខាងលើ យើងខ្ញុំបានធ្វើការបែងចែកជាដំណាក់កាលនីមួយៗច្បាស់លាស់គឺ **ជំពូកទី១៖ លំហូរនីតិវិធីនៃការចាប់ផ្ដើមបណ្ដឹងអាជ្ញា ជំពូកទី២៖ ការអនុវត្តសាលក្រមរបស់អយ្យការ។**

ដោយជំពូកនីមួយៗនឹងមានការបកស្រាយយ៉ាងលំអិតនៅទំព័របន្ទាប់៖

# ជំពូកទី១៖ លំហូរនីតិវិធីនៃការចាប់ផ្តើមបណ្តឹងអាជ្ញា

## ផ្នែកទី១៖ សញ្ញាណទូទៅនៃអង្គភាពអយ្យការ

### កថាខណ្ឌទី១៖ ស្ថាប័នអយ្យការ

ស្ថាប័នអយ្យការមានតួនាទីសំខាន់ណាស់នៅក្នុងរឿងក្តីព្រហ្មទណ្ឌ និង យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថាមានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ នៅអមសាលាជម្រះក្តីនីមួយៗតែងមានស្ថាប័នអយ្យការដែលជាម្ចាស់បណ្តឹងអាជ្ញា។ តួនាទីជាទូទៅរបស់ស្ថាប័នអយ្យការគឺការពារផលប្រយោជន៍របស់សង្គមទាំងក្នុងដំណាក់កាលស៊ើបសួរទាំងក្នុងដំណាក់កាលជំនុំជម្រះក្តី។ ក្រៅពីនេះអយ្យការក៏មានតួនាទីអនុវត្តសេចក្តីសម្រេចរបស់តុលាការដែរ។ សមាសភាពរបស់ចៅក្រមតំណាងអយ្យការមានដូចតទៅៈ មហាអយ្យការអមតុលាការកំពូល(១.១) មហាអយ្យការអមសាលាឧទ្ធរណ៍(១.២) និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត(១.៣) ។

**១.១. មហាអយ្យការអមតុលាការកំពូល**

មហាអយ្យការអមតុលាការកំពូលមានសមាសភាព ដូចខាងក្រោម៖

-អគ្គព្រះរាជអាជ្ញា

-អគ្គព្រះរាជអាជ្ញារង

-ព្រះរាជអាជ្ញា

-ក្រឡាបញ្ជីជាជំនួយការរបស់មហាអយ្យការអមតុលាការកំពូល

-មន្ត្រីរដ្ឋបាល និង អាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅមហាអយ្យការអមតុលាការកំពូល។[1]

**១.២. មហាអយ្យការអមសាលាឧទ្ធរណ៍**

មហាអយ្យការអមសាលាឧទ្ធរណ៍មានសមាសភាព ដូចខាងក្រោម៖

-អគ្គព្រះរាជអាជ្ញា

-អគ្គព្រះរាជអាជ្ញារង

-ព្រះរាជអាជ្ញា

-ក្រឡាបញ្ជី

-មន្ត្រីរដ្ឋបាល និង អាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅមហាអយ្យការអមសាលាឧទ្ធរណ៍។[2]

---

[1] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤ , មាត្រា៦៨។

[2] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤ , មាត្រា៤៩។

### ១.៣. អយ្យការអមសាលាដំបូងរាជធានី ខេត្ត

អយ្យការអមសាលាដំបូងមានសមាសភាព ដូចខាងក្រោម៖

-ព្រះរាជអាជ្ញា

-ព្រះរាជអាជ្ញារង

-ក្រឡាបញ្ជី

-មន្ត្រីរដ្ឋបាល និង អាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅអយ្យការអមសាលាដំបូង។[3]

## កថាខណ្ឌទី២៖ គោលការណ៍ និងតួនាទីនៃស្ថាប័នអយ្យការ

### ២.១. គោលការណ៍នៃស្ថាប័នអយ្យការ

ទោះបីជាស្ថាប័នអយ្យការស្ថិតនៅក្រោមគោលការណ៍ឋានានុក្រមនៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែលស្ថិតក្នុងអំណាចនីតិប្រតិបត្តិក៏ដោយ ក៏ស្ថាប័ននេះឯករាជ្យពីស្ថាប័នតុលាការដែរ។

អង្គការអយ្យការមានគោលការណ៍សំខាន់ៗ ដូចខាងក្រោម៖

#### ២.១.១. គោលការណ៍ឯកភាព (គោលការណ៍ឋានានុក្រម)

អង្គការអយ្យការជាអង្គឯកភាព ដែលព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតនៅក្រោមការដឹកនាំនិងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យការហើយអាចធ្វើអធិបញ្ជាទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់។ ឋានានុក្រមនេះត្រូវបានបែងចែកដូចខាងក្រោម៖

- មហាអយ្យការអមតុលាការកំពូល

- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជានាយឋានានុក្រមនៃមហាអយ្យការអមតុលាការកំពូល

- ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមតុលាការកំពូល ត្រូវធ្វើការក្រោមការដឹកនាំនិងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

- មហាអយ្យការអមសាលាឧទ្ធរណ៍

- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជានាយឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍

- ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវធ្វើការក្រោមការដឹកនាំនិងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

- មហាអយ្យការអមសាលាដំបូង

- ព្រះរាជអាជ្ញាអមសាលាដំបូង គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង

[3] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ,លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា២៩។

- ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូងត្រូវធ្វើការក្រោមការដឹកនាំ និងទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។[4]

**២.១.២. គោលការណ៍អវិភាគ**

អង្គការអយ្យការគឺជាអង្គអវិភាគ មានន័យថាជាអង្គមួយដែលមិនអាចបំបែកបាន ដែលតម្រូវឲ្យព្រះរាជអាជ្ញាត្រូវបំពេញមុខងារនៅអមសាលាជម្រះក្តីណាមួយដែលកាតព្វកិច្ចរួមក្នុងមុខងារដូចគ្នា និងអាចជំនួសគ្នាទៅវិញទៅមកបាន។ តាមគោលការណ៍នេះ តំណាងអយ្យការច្រើនរូប អាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំងរបស់នាយឋានានុក្រម។[5]

**២.១.៣. គោលការណ៍ឯករាជ្យ**

ស្ថាប័នអយ្យការ គឺជាអង្គឯករាជ្យដែលមិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្តីដែលខ្លួននៅអមនោះទេ។ សាលាជម្រះក្តីនេះគ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញាឡើយ។ ទោះបីក្នុងករណីដែលព្រះរាជអាជ្ញាមានកំហុសឆ្គងក្នុងការបំពេញមុខងារក៏ដោយ ក៏សាលាជម្រះក្តីមិនត្រូវចុះក្នុងសេចក្តីសម្រេចរបស់ខ្លួនយកការស្តីបន្ទោសអ្វីចំពោះព្រះរាជអាជ្ញាឡើយ។ ការហាមឃាត់នេះត្រូវអនុវត្តទាំងក្នុងរឿងព្រហ្មទណ្ឌទាំងក្នុងរឿងក្តីផ្សេងទៀត។ ប៉ុន្តែសាលាជម្រះក្តីអាចលើកសំណើទៅនាយឋានានុក្រមរបស់ព្រះរាជអាជ្ញា អំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញាបាន។[6]

**២.១.៤. គោលការណ៍នៃការកត់សំគាល់ដោយសេរីដោយផ្ទាល់មាត់នៅពេលសវនាការ**

ចៅក្រមអយ្យការធ្វើការកត់សំគាល់ផ្ទាល់មាត់ដោយសេរី តាមការដែលខ្លួនយល់ឃើញថា ស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះចៅក្រមអយ្យការដោយសារតែវាចារបស់ខ្លួនដែលបានបញ្ចេញនៅពេលសវនាការសោះឡើយ។[7]

**២.១.៥. គោលការណ៍នៃការមិនទទួលខុសត្រូវ**

ចៅក្រមខាងអយ្យការមិនទទួលខុសត្រូវទេ ប្រសិនបើខ្លួនចាញ់រឿងក្តីព្រហ្មទណ្ឌនោះ។ ចៅក្រមអយ្យការជាអ្នកតំណាងឱ្យផលប្រយោជន៍សាធារណៈ ដូច្នេះបើខ្លួនចាញ់ក្តីនោះមិនមាននរណាម្នាក់អាចទាមទារឱ្យទទួលខុសត្រូវបានទេ។[8]

**២.២.តួនាទីរបស់ព្រះរាជអាជ្ញា**

---

[4] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, លេខ នស/រកម/០៧១៤/០១៦, ១៦ កក្កដា ២០១៤, មាត្រា៧៥ កថាខណ្ឌទី១។

[5] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា៧៥ កថាខណ្ឌទី២។

[6] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា៧៥ កថាខណ្ឌទី៣។

[7] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៣០។

[8] សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ,ចាំង ស៊ីណាត ឆ្នាំ២០១៥-២០១៦ ទំព័រទី១០។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិថា មានតែអង្គអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។[9] បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ។[10] នោះមានន័យថាព្រះរាជអាជ្ញាគឺជាម្ចាស់បណ្តឹងអាជ្ញា ដែលដើរតួនាទីជាភាគីនៃបណ្តឹងតំណាងឲ្យផលប្រយោជន៍សាធារណៈនៅក្នុងរឿងក្តីព្រហ្មទណ្ឌចំពោះមុខតុលាការ។ ព្រះរាជអាជ្ញាដើរតួនាទីយ៉ាងសកម្មក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ [....] ដោយតំណាងឱ្យផលប្រយោជន៍សាធារណៈ។[11] ក្នុងការតំណាងឲ្យផលប្រយោជន៍សាធារណៈព្រះរាជអាជ្ញាមានតួនាទីរួមដូចខាងក្រោម៖ "អង្គការអយ្យការ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន"។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួនចៅក្រមអយ្យការ មានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ។ ចៅក្រមអយ្យការ ត្រូវមានវត្តមាននៅក្នុងពេលសវនាការរឿងព្រហ្មទណ្ឌ។[12] យោងតាមខ្លឹមសារខាងលើយើងអាចកំណត់ពីតួនាទីរបស់អយ្យការរួមមាន៖

- ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។[13] មានន័យថាជាអ្នកទទួលបណ្តឹងពីគ្រប់មជ្ឈដ្ឋាន និងធ្វើការថ្លឹងថ្លែងថាតើគួរចោទប្រកាន់ដែរឬទេ?
- ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។[14]
- អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។[15]
- អយ្យការធ្វើការអនុវត្តទោស នៅពេលដែលសេចក្តីសម្រេចរបស់តុលាការបានក្លាយទៅជាស្ថាពរ។[16]

**កថាខណ្ឌទី៣៖ នីតិវិធីនៃការចោទប្រកាន់របស់អយ្យការ**

បន្ទាប់ពីទទួលបានពាក្យបណ្តឹងទាមទារ បណ្តឹងបរិហារ ឬបណ្តឹងផ្សេងទៀតតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ក្តី តាមរយៈជនរងគ្រោះក្តី តាមរយៈជនអនាមិកក្តី ឬតាមបណ្តាញសារព័ត៌មានក្តី គឺស្ថាប័នអយ្យការត្រូវតែ

---

[9]រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៤/០១៦, ២៤ កញ្ញា ២០០៤, មាត្រា១៣១។

[10]ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤។

[11]គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា, អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី ស្តីពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស នាទីក្រុង ហាវ៉ាណា ប្រទេសគុយបា, ២៧ សីហា ដល់ថ្ងៃទី ៧ កញ្ញា ឆ្នាំ១៩៩០, ចំណុចទី១១។

[12]ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា២៧។

[13]ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤០ កថាខណ្ឌទី១។

[14]ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៥៨ កថាខណ្ឌទី១ ។

[15]ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤ កថាខណ្ឌទី២ ។

[16] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤៩៧ កថាខណ្ឌទី១ ។

ថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្ដឹងនោះ។ ប៉ុន្តែមុននឹងសម្រេចព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋមឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម។[17] មានន័យថាពាក្យប្ដឹង ឬ ព័ត៌មានដែលទទួលបានជូនកាលមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីជាមូលដ្ឋានក្នុងការដែលអយ្យការធ្វើការសម្រេចហេតុនេះអយ្យការត្រូវពិនិត្យចំពោះស្ថានភាពនោះ បើសិនជាខ្វះខាតត្រូវបង្គាប់ឱ្យមានការស្រាវជ្រាវរកព័ត៌មានបន្ថែម។ ព័ត៌មាននោះនឹងក្លាយជាមូលដ្ឋានសម្រាប់ធ្វើការពិចារណាថា៖

- តើអំពើដែលកើតឡើងនោះជាបទល្មើសព្រហ្មទណ្ឌឬក៏មិនមែន?
- ក្រោយពីប្រមូលបានព័ត៌មានហើយព្រះរាជអាជ្ញាត្រូវធ្វើការពិនិត្យសិក្សាជាបឋមទៅលើស្ថានភាពនៃបណ្ដឹងអាជ្ញាថាតើគាត់អាចអនុវត្តបណ្ដឹងអាជ្ញាបានដែរឬទេក្នុងស្ថានភាពនោះ។[18] ទោះបីជារឿងក្ដីជារឿងព្រហ្មទណ្ឌក៏ដោយក៏គេទុករយៈពេលដើម្បីធ្វើបណ្ដឹងអាជ្ញាដែរ ពោលគឺធ្វើការចោទប្រកាន់។ ចំពោះការចោទប្រកាន់នេះដែរគឺទាក់ទងទៅនឹងចិរវេលានៃអាជ្ញាយុកាលនៃបទល្មើស ដែលក្នុងនោះ ៖

- ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម
- ១ (មួយ) ឆ្នាំ ចំពោះបទលហុ។[19]

## ផ្នែកទី២៖ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់របស់អយ្យការ

ក្រោយពីបានពិនិត្យ និងប្រមូលព័ត៌មានគ្រប់គ្រាន់ហើយអយ្យការអាចធ្វើការសម្រេចចំពោះពាក្យប្ដឹងនោះបាន។ ការសម្រេចនោះមានជម្រើសពីរគឺ៖ ទី១ ការធ្វើការចោទប្រកាន់របស់អយ្យការ និង ទី២ ការតម្កល់រឿងទុកឥតចាត់ការ។

### កថាខណ្ឌទី១៖ ការធ្វើការចោទប្រកាន់របស់អយ្យការ

ការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌអាចធ្វើតាមបីជម្រើស៖ (១.១) ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ (CD) (១.២) នីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម (CI) និង (១.៣) ការបើកធ្វើការស៊ើបសួរ (RI) ។[20]

**១.១. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់**(CD)

**១.១.១. លក្ខខណ្ឌនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់**

ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជាជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាក្នុងរឿងក្ដីព្រហ្មទណ្ឌ។[21] ព្រះរាជអាជ្ញាអាចបញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់នៅសាលាដំបូងបាន ប្រសិនបើគ្រប់លក្ខខណ្ឌកំណត់ចំនួន៣ដូចខាងក្រោម៖

[17]ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤០ កថាខណ្ឌទី២វាក្យខណ្ឌទី២ ។

[18]ទូរទស្សន៍ជាតិកម្ពុជា(ទទក), កម្មវិធីផ្សព្វផ្សាយច្បាប់ស្ដីពីក្រមនីតិវិធីព្រហ្មទណ្ឌ, ឆ្នាំ២០០៨។

[19]ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា១០។

[20]ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤៣។

[21]ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤៣។

### ១.១.១.១. ប្រភេទនៃបទល្មើសព្រហ្មទណ្ឌ

នៅក្នុងក្រមព្រហ្មទណ្ឌបានកំណត់នូវបទល្មើសព្រហ្មទណ្ឌចំនួន៣រួមមាន បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។ មានតែបទល្មើសមជ្ឈិម និងបទលហុទេដែលប្រើនីតិវិធីនេះសម្រាប់ការចោទប្រកាន់។ ចំពោះបទមជ្ឈិមអាចប្រើការចោទប្រកាន់តាមទំរង់ជាដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់[22] រីឯបទលហុចាំបាច់ត្រូវតែធ្វើការចោទប្រកាន់តាមទំរង់ជាដីការបញ្ជូនទៅជំនុំជម្រះផ្ទាល់ជាដាច់ខាត។[23] ការកំណត់បែបនេះគឺបទល្មើសទាំងពីរនេះមានភាពខុសគ្នា៖

-បទមជ្ឈិមអាចចោទប្រកាន់តាមទំរង់ជាដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌបញ្ញត្តិថា មិនមែនគ្រប់បទមជ្ឈិមទាំងអស់សុទ្ធតែត្រូវធ្វើនីតិវិធីចោទប្រកាន់បែបនេះទេ។ បទមជ្ឈិមអាចជាកម្មវត្ថុនៃការចោទប្រកាន់តាមទំរង់ជាការបើកការស៊ើបសួរ និងការបង្ហាញខ្លួនភ្លាមក៏បានដែរ ព្រោះមានស្ថានភាពបទល្មើសមជ្ឈិមមួយចំនួនត្រូវបានចោទប្រកាន់ដោយនីតិវិធីផ្សេងទៀត។ ស្ថានភាពនៃបទល្មើសមជ្ឈិមនោះអាចមានករណីមួយចំនួនវាស្មុគស្មាញ ឬ ស្ថានភាពដោយឡែកផ្សេងទៀតដែលតម្រូវឱ្យអនុវត្តនីតិវិធីផ្សេងខុសពីនេះដូចជាមិនទាន់រកមិនឃើញភស្តុតាងគ្រប់គ្រាន់ មិនទាន់ស្គាល់អត្តសញ្ញាណជនល្មើសជាដើម។ដើម្បីជៀសវាងការផុតអាជ្ញាយុកាលនៃបទល្មើសព្រះរាជអាជ្ញា គប្បីប្រើនីតិវិធីជំនុំជម្រះដែលលឿនជាងនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ក៏បានដែរ។

-ចំពោះបទលហុ ជាប្រភេទបទល្មើសដែលស្រាល ចំពោះការចោទប្រកាន់វិញគឺមិនអាចប្រើនីតិវិធីផ្សេងពីនីតិវិធីនេះទេ ព្រោះវាអាចបណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ជននោះ។

### ១.១.១.២. អត្តសញ្ញាណជនល្មើស

អត្តសញ្ញាណជនល្មើសក៏ជាលក្ខខណ្ឌចាំបាច់មួយដែរ ព្រោះជាស្នូរតីក្នុងការធ្វើបណ្ដឹងអាជ្ញា។ គោលបំណងនៃបណ្ដឹងអាជ្ញាមិនត្រឹមតែស្វែងរកអត្ថិភាពនៃបទល្មើសប៉ុណ្ណោះទេ តែអ្វីដែលសំខាន់នោះគឺបង្ហាញឱ្យឃើញពីពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់។ចំពោះការចោទប្រកាន់តាមទំរង់ជាដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺធ្វើចំពោះតែជនដែលស្គាល់អត្តសញ្ញាណតែប៉ុណ្ណោះ។ មួយវិញទៀតក្រមនីតិវិធីព្រហ្មទណ្ឌទទួលស្គាល់វិសាលភាពនៃបណ្តឹងចំពោះជនជាប់ចោទ[24] មានន័យថាតុលាការនឹងជំនុះជម្រះ តែចំពោះជនណាដែលមានក្នុងបណ្តឹងតែប៉ុណ្ណោះ។ សរុបមកអត្តសញ្ញាណជនជាប់ចោទជាលក្ខខណ្ឌចាំបាច់ដែលត្រូវតែមាននៅក្នុងនីតិវិធីនេះ។

[22] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤,១០សីហា២០០៧, មាត្រា៤៥ កថាខណ្ឌទី២។

[23] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤៩ ។

[24] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៣៤៩។

#### ១.១.១.៣. ភាពសមល្មមដែលអាចជំនុំជម្រះបាននៃរឿងក្ដី

ព្រះរាជអាជ្ញានឹងធ្វើការគិតគូរអំពីលក្ខខណ្ឌមួយនេះ ព្រោះបើសំណុំរឿងមិនទាន់គ្រប់គ្រាន់សម្រាប់ធានានូវការចោទប្រកាន់ទេនោះ ព្រះរាជអាជ្ញាចាំបាច់ត្រូវតែធ្វើការស៊ើបសួរបន្ថែមទៀតដើម្បីប្រមូលភស្តុតាងឱ្យបានគ្រប់គ្រាន់មុននឹងធ្វើការចោទប្រកាន់។ ព្រះរាជអាជ្ញាមិនត្រូវប៉ាន់ស្មានថានឹងមានការស៊ើបបន្ថែមណាមួយដោយតុលាការក្នុងពេលជំនុំជម្រះទេ[25] ព្រោះអាចជាឱកាសដល់ជនត្រូវចោទក្នុងករណីដែលមានសេចក្ដីសម្រេចស្ថាពរឱ្យជនត្រូវចោទបានរួចខ្លួន នាំឱ្យរលត់បណ្ដឹងអាជ្ញាដោយមូលហេតុអាជ្ញាអស់ជំនុំ។

### ១.១.២. អានុភាពនៃដីកាកោះហៅទៅជំនុំជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជាដីកាដែលចេញដោយព្រះរាជអាជ្ញាក្នុងការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌ។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់មានអានុភាពដូចតទៅ៖

#### ១.១.២.១. ការផ្ដាច់អាជ្ញាយុកាលនៃបទល្មើសព្រហ្មទណ្ឌ

បណ្ដឹងអាជ្ញាមិនអាចធ្វើបានជាដាច់ខាត កាលបើផុតអាជ្ញាយុកាលសម្រាប់ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌ ហើយអាជ្ញាយុកាលនៃបទល្មើសនឹងត្រូវបានផ្ដាច់ កាលណាមានកិច្ចនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាកើតឡើង។[26] អាជ្ញាយុកាលនៃបទល្មើសត្រូវគិតចាប់ពីពេលប្រព្រឹត្តបទល្មើស ឬ គិតចាប់ពីពេលចាប់ផ្ដើមកិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរ។ ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានបញ្ញត្តិអំពីអាជ្ញាយុកាលនៃបទល្មើសនេះផងដែរគឺ៖

- ១៥ (ដប់ប្រាំ)ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ (ប្រាំ)ឆ្នាំ ចំពោះបទមជ្ឈិម
- ១ (មួយ)ឆ្នាំ ចំពោះបទលហុ។[27]

#### ១.១.២.២. ការផ្ទេរសមត្ថកិច្ចតុលាការ

ជាទូទៅតុលាការមានសមត្ថកិច្ចជំនុំជម្រះបានលុះត្រាតែមានបណ្ដឹងមកខ្លួនតែប៉ុណ្ណោះ។ ក្នុងរឿងព្រហ្មទណ្ឌសាលាដំបូងត្រូវបានទទួលបណ្ដឹងដោយ ដីកាបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា។[28] កិច្ចជំនុំជម្រះដែលបើកដោយគ្មានបណ្ដឹងនោះជាការបើកការជំនុំជម្រះដោយខុសច្បាប់ ជនដែលច្បាប់បានប្រគល់សិទ្ធិឱ្យអាចៈ ធ្វើបណ្ដឹងឧទ្ធរណ៍បានចំពោះសាលក្រមរបស់សាលាដំបូងធ្វើបណ្ដឹងសារទុក្ខចំពោះសាលដីការបស់សាលាឧទ្ធរណ៍ និង អាចធ្វើបណ្ដឹងសើរើបើសេចក្ដីសម្រេចតុលាការចូលជាស្ថាពរ។

#### ១.១.២.៣. ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុនិងជនជាប់ចោទ

តុលាការអាចសម្រេចសេចក្ដីបានតែទៅលើ អំពើទាំងឡាយណាដែលមានបង្ហាញនៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់តែប៉ុណ្ណោះ។ តុលាការមិនអាចលើកយកអង្គហេតុទាំងឡាយណាដែលមិនមាននៅក្នុង

[25] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៣៣៩។

[26] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា១១ ។

[27] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា១០។

[28] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា២៩១។

ដីកានោះមកជំនុំជម្រះបានទេ។ ទោះបីជាមានការកំណត់អំពីអង្គហេតុរួចហើយក៏ដោយ តែជួនកាលក្នុងករណីដែលតុលាការសម្រេចដោយមានចៅក្រមតែម្នាក់គត់ ហើយយល់ឃើញថាអង្គហេតុដែលបានប្តឹងនោះបង្កើតបានជាបទឧក្រិដ្ឋតុលាការនឹងបង្គាប់ឱ្យបង្វិលសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរវិញ។[29]

**១.១.២.៤. ការបង្ហាញខ្លួនរបស់ជនជាប់ចោទ**

ដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់គ្មានអានុភាពបង្ខំឱ្យជនជាប់ចោទចូលសវនាការទេ។ មានន័យថាជនជាប់ចោទមានសេរីភាពក្នុងការទៅបង្ហាញខ្លួនដោយឯកឯងនៅពេលសវនាការ។[30]

**១.១.៣. លក្ខខណ្ឌសុពលភាពនៃដីកាកោះហៅទៅជំនុំជម្រះផ្ទាល់**

ដើម្បីធានាថាជនជាប់ចោទមានរយៈពេលសមរម្យក្នុងការរៀបចំខ្លួនត្រៀមឡើងសវនាការសម្រាប់ស្ថានភាព ឬ ទីតាំងដែលជនជាប់ចោទស្នាក់នៅ។ ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានបញ្ញត្តិអំពីការកំណត់រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការចូលបង្ហាញខ្លួនរបស់ជនជាប់ចោទនៅមុខតុលាការផងដែររួមមានៈ

- ១៥ (ដប់ប្រាំ)ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការជាន់ដំបូង
- ២០ (ម្ភៃ)ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ
- ២ (ពីរ)ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- ៣ (បី)ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត។[31]

ក្នុងករណីជនជាប់ចោទមិនចូលបង្ហាញខ្លួនទេ តុលាការពិនិត្យមោឃភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ ដីកាកោះហៅឱ្យចូលបង្ហាញខ្លួនទេ តុលាការបង្គាប់ឱ្យចេញដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ ដីកាកោះហៅឱ្យចូលបង្ហាញខ្លួនជាថ្មីម្តងទៀត លើកលែងតែបណ្តឹងអាជ្ញាត្រូវផុតរលត់។ ប៉ុន្តែប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការតុលាការអាចពិនិត្យមើលរឿង ប្រសិនបើជនជាប់ចោទយល់ព្រមយ៉ាងជាក់លាក់ឱ្យជំនុំជម្រះភ្លាម។ ប្រសិនបើជនជាប់ចោទ មិនព្រមឱ្យជំនុំជម្រះភ្លាមទេតុលាការបង្គាប់ឱ្យលើករឿងនេះទៅជំនុំជម្រះនៅពេលសវនាការក្រោយទៀត។[32]

**១.២. នីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម** (CI)

ជម្រើសក្នុងការចោទប្រកាន់មួយទៀតរបស់ព្រះរាជអាជ្ញា គឺនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។ ចំពោះការចូលបង្ហាញខ្លួនភ្លាមរបស់ជនជាប់ចោទនៅមុខតុលាការជាន់ដំបូង គឺត្រូវធ្វើឡើងតាមរយៈកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។[33]

---

[29]ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា២៩១។

[30] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៣០២។

[31] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤៦៦។

[32] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤៩១។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា២៩១។

### ១.២.១. លក្ខខណ្ឌនៃនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង ប្រសិនបើមានគ្រប់លក្ខខណ្ឌដូចតទៅ៖

#### ១.២.១.១. បទល្មើសត្រូវតែជាបទល្មើសជាក់ស្តែង

បទល្មើសជាក់ស្តែង សំដៅដល់បទល្មើសដែលបានកំណត់ក្នុងមាត្រា៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) និងមាត្រា៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង)៖

- មាត្រា៨៦និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងគឺបទល្មើសដែលកំពុងប្រព្រឹត្ត បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម និងត្រូវចាត់ទុកជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងដែរកាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក ជនដែលគេសង្ស័យត្រូវបានដេញប្រដាប់ចាប់ប្រភឹង បុគ្គលដែលត្រូវបានគេរកឃើញមានវត្ថុ ឬ ស្លាកស្នាម ឬ តម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬ បានចូលរួមប្រព្រឹត្តបទល្មើស។[34]
- មាត្រា៨៨ ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង គឺត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងផងដែរ បើទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងមាត្រា៨៦(និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង)ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬ បទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬ ភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តធម៌នៅកន្លែងនោះ។ ក្នុងករណីចុងក្រោយនេះភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌។[35]

#### ១.២.១.២. អតិបរមានៃការផ្តន្ទាទោស

បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច១ (មួយ)ឆ្នាំ និងយ៉ាងច្រើន៥ (ប្រាំ)ឆ្នាំ។ ចិរវេលានៃការផ្តន្ទាទោសនេះយើងត្រូវមើលទៅលើអតិបរមានៃទោសដែលបានចែងក្នុងច្បាប់។ ក្នុងនោះគេផ្តោតចំពោះតែបទមជ្ឈិមតែប៉ុណ្ណោះ។[36]

#### ១.២.១.៣. ជនជាប់ចោទជានីតិជន

នីតិវិធីនៃការបង្ហាញខ្លួនភ្លាម គឺជានីតិវិធីមួយដែលការជំនុំជម្រះមានភាពឆាប់រហ័សជាងនីតិវិធីដទៃទៀត។ ក្នុងនីតិវិធីនេះ តុលាការក៏អាចសម្រេចឱ្យមានការឃុំខ្លួនបណ្តោះអាសន្នចំពោះជនជាប់ចោទផងដែរ។ យើងឃើញថាបើអនុវត្តនីតិវិធីនេះចំពោះអនីតិជន ហាក់បីដូចជាមិនគោរពចំពោះគោលការណ៍នៃការយកចិត្តទុកដាក់ និងការពារចំពោះអនីតិជន។ ហេតុនេះច្បាប់តម្រូវឱ្យអនុវត្តនីតិវិធីនេះចំពោះតែនីតិជនប៉ុណ្ណោះ។

[34] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /១១០៩/ ០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៨៦។

[35] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /១១០៩/ ០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៨៨។

[36] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤៧។

**១.២.១.៤. រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន**

ចំនុចនេះគឺដូចគ្នាទៅនឹងនីតិវិធីកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដែរ ប្រសិនបើគ្មានបន្ទុកភស្តុតាងគ្រប់គ្រាន់ទេព្រះរាជអាជ្ញាមិនគួរធ្វើការចោទប្រកាន់តាមនីតិវិធីនេះទេ។ ព្រះរាជអាជ្ញាចាំបាច់ត្រូវតែធ្វើការស៊ើបសួរបន្ថែមទៀតដើម្បីប្រមូលភស្តុតាងឱ្យបានគ្រប់គ្រាន់ មុននឹងធ្វើការចោទប្រកាន់។ ព្រះរាជអាជ្ញាមិនត្រូវប៉ាន់ស្មានថានឹងមានការស៊ើបសួរបន្ថែមណាមួយដោយតុលាការក្នុងពេលជំនុំជម្រះទេ ព្រោះអាចជាឱកាសដល់ជនជាប់ចោទក្នុងករណីដែលមានសេចក្តីសម្រេចស្ថាពរឱ្យជនជាប់ចោទបានរួចខ្លួន នាំឱ្យរលត់បណ្តឹងអាជ្ញាដោយមូលហេតុអាជ្ញាអស់ជំនុំ។

កាលណាព្រះរាជអាជ្ញាសម្រេចថាត្រូវប្រើនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមព្រះរាជអាជ្ញាត្រូវ៖

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួន
- ឱ្យដំណឹងដល់ជននោះ អំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស
- ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្តីអំពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។[37]

ព្រះរាជអាជ្ញាប្រាប់ជនជាប់ចោទថា ខ្លួនមានសិទ្ធិសុំពឹងមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬ ចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

មេធាវីជ្រើសរើស ឬ ចាត់តាំងត្រូវបានទទួលដំណឹងភ្លាម។ មេធាវីអាចពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទបាន។ និទ្ទេសនៃទម្រង់ការទាំងនេះ ត្រូវចុះក្នុងកំណត់ហេតុបើពុំដូច្នោះទេនីតិវិធីត្រូវទុកជាមោឃៈ។[38] ចំពោះនីតិវិធីនៃការបង្ហាញខ្លួនភ្លាមតុលាការអាច៖ ឃុំខ្លួនជនត្រូវចោទ ឬ ដោះលែងជនត្រូវចោទបានតែត្រូវចេញដីកាឃុំខ្លួនបណ្តោះអាសន្ន។

ចំពោះការផ្តន្ទាទោសវិញគឺ ទោសដែលតុលាការប្រកាសនោះ៖

-បើតុលាការសម្រេចផ្តន្ទាទោស១(មួយ) ឆ្នាំឡើងទៅទើបអាចឃុំខ្លួនបាន

-បើតុលាការសម្រេចផ្តន្ទាទោសក្រោម១(មួយ)ឆ្នាំនោះត្រូវដោះលែងជននោះឱ្យមានសេរីភាព។[39]

**១.២.២. អានុភាពនៃនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម**

ការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមជានីតិវិធីចោទប្រកាន់ដែលស្តែងឡើង ដោយកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម កំណត់ហេតុនេះមានអានុភាពដូចខាងក្រោម៖

**១.២.២.១. ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស**

---

[37] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤៨។

[38] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤៨។

[39] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៣៥៣។

ការចេញកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមដោយព្រះរាជអាជ្ញា គឺជាកិច្ចនៃការចោទប្រកាន់ចំពោះជនជាប់ចោទ មូលហេតុដែលនាំឱ្យមានការបង្អាក់អាជ្ញាយុកាលនៃបទល្មើសគឺដូចគ្នាទៅនឹងដីកាកោះហៅទៅជំនុំជម្រះផ្ទាល់។[40]

**១.២.២.២. ការផ្ទេរសមត្ថកិច្ចទៅតុលាការ**

តុលាការព្រហ្មទណ្ឌទទួលបានបណ្តឹងតាមរយៈកំណត់ហេតុបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា។ តុលាការនឹងគ្មានសមត្ថកិច្ចជំនុំជម្រះបានដរាបណាមិនមានកិច្ចចោទប្រកាន់មកខ្លួន។

**១.២.២.៣. ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុនិងជនជាប់ចោទ**

កំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា គឺមានការកំណត់អំពីអង្គហេតុ និងកំណត់ពីបុគ្គលដែលព្រះរាជអាជ្ញាចង់ធ្វើការចោទប្រកាន់។ តុលាការអាចធ្វើការជំនុំជម្រះតែទៅលើអង្គហេតុដែលមានចែងក្នុងកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម និងអាចជំនុំជម្រះចំពោះបុគ្គលដែលបញ្ជូនទៅចំពោះមុខខ្លួនក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ។[41]

**១.២.៣. ការបង្វិលសំណុំរឿងពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមទៅជាការបើកការស៊ើបសួរ**

**១.២.៣.១. មូលហេតុនៃការបង្វិលសំណុំរឿង**

ប្រសិនបើតុលាការដែលបានទទួលពាក្យបណ្តឹងតាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមយល់ឃើញថា សំណុំរឿងមិនអាចធ្វើតាមនីតិវិធីនេះបានទេ នោះអាចធ្វើការបង្វិលសំណុំរឿងបានដោយសារមូលហេតុ៖

- មិនបានគោរពលក្ខខណ្ឌនៃមាត្រា ៤៧(ការបង្ហាញខ្លួនភ្លាម) ចៅក្រមអាចបង្វិលសំណុំរឿងឱ្យព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ
- ភាពសាំញ៉ាំនៃសំណុំរឿង តម្រូវជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវឱ្យបានជ្រាលជ្រៅបន្ថែមទៀតតុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ។[42]

មូលហេតុខាងលើមិនបានកំណត់ជាក់លាក់ថាព្រះរាជអាជ្ញា ត្រូវតែបើកការស៊ើបសួរក្នុងករណីនេះទេ ព្រះរាជអាជ្ញានៅតែអាចប្រើជម្រើសក្នុងការចោទប្រកាន់តាមការថ្លឹងថ្លែងរបស់ខ្លួនបាន លើកលែងតែស្ថានភាពមួយចំនួនដែលបានកំណត់ថាព្រះរាជអាជ្ញាត្រូវតែគោរពជាដាច់ខាត។

**១.២.៣.២. នីតិវិធីនៃការបង្វិលសំណុំរឿង**

នៅពេលតុលាការសម្រេចបង្វិលសំណុំរឿងទៅព្រះរាជអាជ្ញាវិញនោះ ព្រះរាជអាជ្ញាត្រូវបញ្ជូនជនជាប់ចោទទៅបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរនៅថ្ងៃនោះតែម្តង បើពុំដូច្នោះទេជនជាប់ចោទត្រូវតែដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង។[43]

[40] សូមមើលអានុភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ចំណុច១.១.២.១, ទំព័រទី១១។

[41] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៣៨៩។

[42] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤៨ កថាខណ្ឌទី១១។

[43] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤៨ កថាខណ្ឌទី១១។

ចំពោះនីតិវិធីនៃការបង្ហាញខ្លួនភ្លាមតុលាការអាច៖ ឃុំខ្លួនជនត្រូវចោទ ឬ ដោះលែងជនត្រូវចោទបានតែត្រូវចេញដីកាឃុំខ្លួនបណ្ដោះអាសន្ន។ ចំពោះការផ្ដន្ទាទោសវិញគឺ ទោសដែលតុលាការប្រកាស ៖

-បើតុលាការសម្រេចផ្ដន្ទាទោស ១(មួយ) ឆ្នាំឡើងទៅទើបអាចឃុំខ្លួនបាន

-បើតុលាការសម្រេចផ្ដន្ទាទោសក្រោម ១(មួយ) ឆ្នាំ នោះត្រូវដោះលែងជននោះឱ្យមានសេរីភាព។

**១.៣. ការបើកការស៊ើបសួរ** (RI)

ការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដោយតំណាងអយ្យការ គឺជានីតិវិធីធម្មតាមួយដែលមុននឹងបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរធ្វើការស៊ើបសួរទាំងភស្តុតាងដាក់បន្ទុក និង ភស្តុតាងដោះបន្ទុកដើម្បីស្វែងរកនូវភាពយុត្តិធម៌ជូនភាគីទាំងសងខាង ខុសគ្នាពីអយ្យការដែលជាអ្នកតំណាងនូវផលប្រយោជន៍សាធារណៈ។[44] ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬ ច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬ ប្រឆាំងទៅលើអញ្ញាតជន។

**១.៣.១. លក្ខខណ្ឌនៃការបើកការស៊ើបសួរ**

ការបើកការស៊ើបសួរអាចធ្វើបានតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយព្រះរាជអាជ្ញាបញ្ជូនទៅឱ្យចៅក្រមស៊ើបសួរដើម្បីបើកការស៊ើបសួរ។ នៅក្នុងការចោទប្រកាន់ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់ទៅលើបទល្មើស២គឺ បទឧក្រិដ្ឋ និងបទមជ្ឈិម។

- **បទឧក្រិដ្ឋ**

គ្រប់បទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ មានន័យថាព្រះរាជអាជ្ញានឹងបើកការស៊ើបសួរជាកាតព្វកិច្ចចំពោះគ្រប់បទឧក្រិដ្ឋ។ ការកំណត់បែបនេះដោយសារតែបទឧក្រិដ្ឋជាប្រភេទបទល្មើសដែលធ្ងន់ធ្ងរដោយការផ្ដន្ទាទោសដាក់ពន្ធនាគារមានរយៈលើសពី ៥(ប្រាំ) ឆ្នាំ និងក្រោម ឬ ស្មើនឹង ៣០(សាមសិប)ឆ្នាំ ឬអាចដាក់ពន្ធនាគារអស់មួយជីវិត។ កម្រិតទោសនេះគឺមានភាពធ្ងន់ធ្ងរខ្លាំងណាស់ ដូចនេះទាមទារឱ្យមានការស្រាវជ្រាវឱ្យបានម៉ត់ចត់ ជៀសវាងមានការភ័ន្តច្រឡំចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះ។[45]

- **បទមជ្ឈិម**

ចំពោះបទមជ្ឈិម ព្រះរាជអាជ្ញាអាចធ្វើការបើកការស៊ើបសួរ ឬមិនបើកការស៊ើបសួរ ក៏បាន។ បទមជ្ឈិមជាសិទ្ធិរបស់ព្រះរាជអាជ្ញាក្នុងការជ្រើសរើសថាគួរបើកការស៊ើបសួរ ឬមិនបើកការស៊ើបសួរ ព្រោះរយៈពេលនៃការផ្ដន្ទាទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិមមានរយៈពេល លើសពី៦(ប្រាំមួយ) ថ្ងៃ និងក្រោម ឬ ស្មើនឹង៥(ប្រាំ) ឆ្នាំ។[46] បើយើងមើលលើរយៈពេលនៃការផ្ដន្ទាទោសគឺបទល្មើសមានភាពសមល្មម ពោលគឺមិនធ្ងន់ពេក ហើយក៏មិនស្រាលពេកដែរ។ ប៉ុន្តែមានស្ថានភាពមួយចំនួនដែលបទមជ្ឈិមត្រូវតែបើកការស៊ើបសួរនោះរួមមាន៖

[44] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា១២៧។

[45] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /១១០៩/ ០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៦។

[46] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /១១០៩/ ០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៧។

- គ្មានអត្តសញ្ញាណជនល្មើស មានន័យថាព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ចំពោះតែជនដែលស្គាល់អត្តសញ្ញាណតែប៉ុណ្ណោះ។
- ភស្តុតាងមិនទាន់គ្រប់គ្រាន់ កាលណាភស្តុតាងមិនទាន់មានភាពពេញលេញទេព្រះរាជអាជ្ញាត្រូវស្វែងរកភស្តុតាងឱ្យបានគ្រប់គ្រាន់ជាមុនសិនចាំធ្វើការចោទប្រកាន់តាមក្រោយ។
- ភាពដែលមិនដឹងថានៅទីណា ក្នុងករណីដែលដឹងអត្តសញ្ញាណជននោះតុលាការអាចធ្វើការជំនុំជម្រះដោយកំបាំងមុខជនជាប់ចោទបាន តែបញ្ហានេះព្រះរាជអាជ្ញាត្រូវបើកកិច្ចស៊ើបសួរដើម្បីចាប់ខ្លួនជននោះមកផ្តន្ទាទោសតាមច្បាប់។
- ចំពោះករណីដែលជនល្មើសមានច្រើន ជាទូទៅតុលាការមិនធ្វើការជំនុំជម្រះច្រើនដងចំពោះបទល្មើសតែមួយប៉ុន្តែមានជនល្មើសច្រើននោះទេ ព្រោះអាចបណ្តាលឱ្យមានការប៉ះពាល់ចំពោះការផ្តន្ទាទោសករណីដែលតុលាការយល់ឃើញខុសគ្នា។

**១.៣.២. អានុភាពដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មានអានុភាពដូចតទៅ៖

**១.៣.២.១. ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស**

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជាកិច្ចចោទប្រកាន់របស់អយ្យការ ហើយកិច្ចចោទប្រកាន់នេះនាំឱ្យមានការផ្តាច់អាជ្ញាយុកាលនៃបទល្មើស។[47]

**១.៣.២.២. ការផ្ទេរសមត្ថកិច្ចឱ្យចៅក្រមស៊ើបសួរបើកកិច្ចស៊ើបសួរ**

គ្រប់កិច្ចស៊ើបសួរអាចបើកការស៊ើបសួរបានលុះត្រាតែមានការចោទប្រកាន់របស់អយ្យការ លើកលែងតែការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ។ កិច្ចស៊ើបសួរដែលបើកដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ កិច្ចស៊ើបសួរនោះត្រូវទុកជាមោឃៈ។ ការប្តឹងមោឃភាពនៃកិច្ចស៊ើបសួរត្រូវប្តឹងទៅសភាស៊ើបសួរ ព្រោះមានតែសភាស៊ើបសួរទេដែលមានសមត្ថកិច្ចដើម្បីពិនិត្យមោឃភាពនៃលិខិតនៃនីតិវិធី។[48]
ការចូលជាស្ថាពរនៃដីកាដំណោះស្រាយមានអានុភាពលុបលាងមោឃភាពនៃនីតិវិធី គ្មានមោឃភាពណាមួយនៃនីតិវិធីមុនអាចត្រូវបានលើកឡើងនៅចំពោះមុខ តុលាការជំនុំជម្រះបានទៀតឡើយ។[49]

**១.៣.២.៣. ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងបុគ្គល**

ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ មានន័យថាជាគោលការណ៍ចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរលុះត្រាតែមានដីកា

[47] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា១១។
[48] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា២៥៣។
[49] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា២៥៦។

សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចស៊ើបសួរត្រឹមតែអង្គហេតុដែលចង្អុលបង្ហាញក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ។ ប្រសិនបើមានលេចអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចប្ដឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។ ប៉ុន្តែ ចៅក្រមស៊ើបសួរមិនចាំបាច់រាយការណ៍ជូនព្រះរាជអាជ្ញាដើម្បីឱ្យព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសទៅលើអង្គហេតុដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង។ ចៅក្រមស៊ើបសួរមានអំណាចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូប ដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថាបានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ។[50]

### ១.៣.៣. ទម្រង់ចាំបាច់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

#### ១.៣.៣.១. ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាដីកាដែលព្រះរាជអាជ្ញាប្ដឹងទៅចៅក្រមស៊ើបសួរឱ្យធ្វើការស៊ើបសួរលើអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវមាននិទ្ទេសដូចខាងក្រោម៖

- សេចក្ដីសង្ខេបនៃអង្គហេតុ

ចំណុចនេះមានភាពសំខាន់ ព្រោះចៅក្រមស៊ើបសួរធ្វើការស៊ើបសួរតែអង្គហេតុដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់មកខ្លួនតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ។បើគ្មានអង្គហេតុក៏គ្មានការចោទប្រកាន់ដែរ។

- ការកំណត់ឈ្មោះបទល្មើស

នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរព្រះរាជអាជ្ញាត្រូវតែកំណត់អំពីឈ្មោះបទល្មើសឱ្យច្បាស់ កាលបើមិនបានកំណត់ឈ្មោះបទល្មើសទេវានឹងមានការលំបាកចំពោះចៅក្រមស៊ើបសួរក្នុងការបើកការស៊ើបសួរ។ ការកំណត់ឈ្មោះបទល្មើសជាជំហានដំបូងក្នុងការបើកការស៊ើបសួរ ព្រោះចៅក្រមស៊ើបសួរមិនអាចកំណត់ថាអង្គហេតុដែលទទួលបាននោះជាបទល្មើសអ្វី។

- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស

ចំពោះការបង្ហាញអត្ថបទច្បាប់ដែលកំណត់ គឺជាការចាំបាច់មួយដែរដើម្បីធានានូវការចោទប្រកាន់ឱ្យកាន់តែរឹងមាំ ប្រសិនបើព្រះរាជអាជ្ញាធ្វើការចោទប្រកាន់តែមិនបានយោងបទបញ្ញត្តិគតិយុត្តមកអះអាងទេ ការចោទប្រកាន់នោះហាក់បីដូចជាមិនមានមូលដ្ឋានច្បាស់លាស់។

- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន

[50] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា១២៥។

នៅក្នុងករណីដែលមិនអាចកំណត់បានតំណាងអយ្យការអាចបើកការស៊ើបសួរប្រឆាំងនឹងអញ្ញាត្រជនបាន ពោលគឺជនមិនស្គាល់អត្តសញ្ញាណ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចាំបាច់ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ដើម្បីឱ្យដីកានេះមានអានុភាពអនុវត្ត បើគ្មានការចុះហត្ថលេខាទេយើងមិនដឹងថាព្រះរាជអាជ្ញាទទួលស្គាល់ចំពោះដីកានោះឬក៏អត់នោះទេ នាំឱ្យដីកានោះគ្មានអានុភាព។[51]

**១.៣.៣.២. អានុភាពនៃការមិនគោរពទម្រង់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**

ទម្រង់នៃដីកានេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើមិនដូច្នោះទេដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនឹងត្រូវទុកជាមោឃៈ។ ការទុកជាមោឃៈនៃដីកានេះ មានន័យថាកិច្ចចោទប្រកាន់តាមដីកានេះនឹងគ្មានអានុភាពចោទប្រកាន់ទេ។ ប្រសិនបើមិនមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ កិច្ចស៊ើបសួរទាំងអស់សុទ្ធតែជាកម្មវត្ថុនៃការប្តឹងមោឃភាព។

## កថាខណ្ឌទី២៖ ការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ គឺជានីតិវិធីជម្រើសនៃការចោទប្រកាន់មួយដែលកើតចេញពីគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ដែលគោលការណ៍នេះផ្តល់អំណាចសម្រាប់ព្រះរាជអាជ្ញាក្នុងការថ្លឹងថ្លែងអំពីបទល្មើសក្នុងនាមជានិយ័តករនៃសង្គម។[52] ទន្ទឹមនឹងនេះព្រះរាជអាជ្ញាអាចធ្វើការតម្កល់រឿងទុកឥតចាត់ការតាមវិធី២យ៉ាងគឺ៖ (២.១) ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលមិនមែនជាបទល្មើស និង (២.២) ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជាបទល្មើស។

**២.១. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលមិនមែនជាបទល្មើស**

ករណីដែលអំពើមួយកើតឡើងហើយមិនត្រូវបានគេចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌកាលណាអំពើនោះ៖

**២.១.១. កង្វះធាតុផ្សំនៃបទល្មើស**

ដើម្បីចាត់ទុកអំពើមួយថាជាបទល្មើសព្រហ្មទណ្ឌដាច់ខាតត្រូវមានធាតុផ្សំ៣សំខាន់គឺ៖

- ធាតុផ្សំនីត្យានុកូលភាព(ធាតុច្បាប់) នីត្យានុកូលភាពបែងចែកជា២គឺ៖
  - នីត្យានុកូលភាពនៃបទល្មើសគឺ មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។
  - នីត្យានុកូលភាពនៃទោសគឺ មានតែទោសដែលមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន។[53]

---

[51] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤៤។

[52] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤, ១០ សីហា ២០០៧, មាត្រា៤០។

[53] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /១១០៩/ ០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣។

- ធាតុផ្សំសត្យានុម័ត(ធាតុសម្ភារៈ) ច្បាប់បានបញ្ញត្តិថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គមជាបទល្មើស។ បទល្មើសត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុទៅតាមទម្ងន់នៃបទល្មើសនោះ។[54]
- ធាតុផ្សំអត្តនោម័ត(ធាតុចេតនា) ពុំមានបទល្មើសទេប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ ប៉ុន្តែនៅក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ។[55]

**២.១.២. អវត្តមាននៃបទល្មើស**

តុលាការអាចផ្តន្ទាទោសចំពោះបុគ្គលដែលប្រព្រឹត្តអំពើល្មើសបាន លុះត្រាតែ អំពើនោះជាបទល្មើសព្រហ្មទណ្ឌ។ ប្រសិនបើអំពើល្មើសនោះជាវិវាទការងារ វិវាទរដ្ឋប្បវេណី ឬវិវាទរដ្ឋបាល នោះតុលាការមិនអាចផ្តន្ទាទោសបុគ្គលនោះតាមច្បាប់ព្រហ្មទណ្ឌបានទេ។

**២.១.៣. អំពើល្មើសជាប្រភេទអំពើល្មើសតូចតាច**

មុននឹងធ្វើការចោទប្រកាន់ព្រះរាជអាជ្ញា តែងតែធ្វើការថ្លឹងថ្លែងអំពីចរឹកគ្រោះថ្នាក់នៃអំពើដែលប្រព្រឹត្តជាមួយព្យសនកម្មដែលកើតឡើងថាតើមានធ្ងន់ធ្ងរឬតូចតាច។ បើអំពើនោះបង្កព្យសនកម្មតិចតួចដល់ជនរងគ្រោះហើយមិនមានផលប៉ះពាល់ដល់សង្គមទេនោះព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការបាន។

**២.១.៤. ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍**

អំពើដែលកើតឡើងមិនមានផ្តល់ផលប៉ះពាល់ដល់សង្គម ហើយជនរងគ្រោះក៏មិនមានការខូចខាតដែលបណ្តាលមកពីអំពើនោះដែរ បើធ្វើការចោទប្រកាន់ទៅមិនមានផលប្រយោជន៍ចំពោះភាគីណាមួយឡើយ។

**២.១.៥. មិនស្គាល់អត្តសញ្ញាណរបស់ជនល្មើស**

បុគ្គលដែលប្រព្រឹត្តអំពើល្មើសមិនត្រូវបានគេស្គាល់អត្តសញ្ញាណ ទោះបីជាមានការស្រាវជ្រាវយ៉ាងណាក៏មិនឃើញ ហើយព្យសនកម្មនៃអំពើក៏មិនធ្ងន់ធ្ងរប៉ះពាល់ដល់សង្គមដែរ។

**២.១.៦. អនិយ័តភាពនៃនីតិវិធី**

អនិយ័តភាពនៃនីតិវិធី គឺជានីតិវិធីពិសេសមួយដែលព្រះរាជអាជ្ញាអាចធ្វើការតម្កល់រឿងទុកឥតចាត់ការបានកាលបើការស៊ើបអង្កេតមិនបានគោរពនូវវិធាន ឬទម្រង់ណាមួយដែលច្បាប់ចែង ដូចជា ការចុះឆែកឆេរ ការឃាត់ខ្លួន ការចាប់យកវត្ថុតាង-ល-។

[54] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /១១០៩/ ០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២។
[55] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /១១០៩/ ០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤។

## ២.២. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជាបទល្មើស

អំពើល្មើសមួយកើតឡើង កាលបើបានបំពេញគ្រប់លក្ខខណ្ឌធាតុផ្សំនៃបទល្មើសនោះអយ្យការនឹងចាប់ដំណើរការបណ្តឹងអាជ្ញាចំពោះអំពើល្មើសនោះ។ ប៉ុន្តែព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការចំពោះអំពើមួយដែលជាបទល្មើសក៏បានកាលណាអំពើនោះបានផុតរលត់នូវបណ្តឹងអាជ្ញារួមមាន៖

### ២.២.១. មរណភាពនៃជនល្មើស

គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ មានន័យថាបុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ។[56] បុគ្គលដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌត្រូវតែជាមនុស្សមានជីវិតរស់នៅ ហើយបើបុគ្គលដែលប្រព្រឹត្តនោះបានទទួលមរណភាព នាំឱ្យការចោទប្រកាន់របស់ព្រះរាជអាជ្ញាក៏មិនអាចកើតបានដែរ។

### ២.២.២. ការផុតអាជ្ញាយុកាលនៃបទល្មើស

អាជ្ញាយុកាលនៃបទល្មើស ឬអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា សំដៅលើរយៈពេលដែលច្បាប់បានកំណត់ដើម្បីងាយស្រួលគិតរយៈពេលនៃការចោទប្រកាន់ ដោយចិរវេលានោះបានកំណត់ដូចខាងក្រោម៖

- ១៥(ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥(ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម
- ១(មួយ) ឆ្នាំ ចំពោះបទលហុ។[57]

លើកលែងតែបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមមិនអាចផុតអាជ្ញាយុកាលទេ។[58]

### ២.២.៣. ការលើកលែងទោសជាទូទៅ

កាលបើច្បាប់ស្តីពីការលើកលែងទោសជាទូទៅបានបញ្ញត្តិថាបទល្មើស ឬស្ថានភាពកំណត់ណាមួយត្រូវបានលើកលែងការចោទប្រកាន់ ឬកំណត់ឱ្យរួចទោសនោះព្រះរាជអាជ្ញាមិនត្រូវធ្វើការចោទប្រកាន់ទេ ហើយបើកំពុងអនុវត្តទោសត្រូវបានដោះលែងជននោះឱ្យមានសេរីភាព។ អានុភាពនៃការកំណត់នេះមិនមានអានុភាពចំពោះប្រាក់ពិន័យ និងប្រាក់ពន្ធនីតិវិធីដែលបានបង់រួចហើយ។[59]

### ២.២.៤. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ សំដៅលើការច្រានចោលបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌចាស់ហើយដែលត្រូវបានជំនួសមកវិញនូវបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌថ្មី។ ជាគោលការណ៍អំពើដែលបានប្រព្រឹត្តនៅមុនពេលបទប្បញ្ញត្តិថ្មី

---

[56] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /១១០៩/ ០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៤។

[57] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤,១០ សីហា ២០០៧, មាត្រា១០។

[58] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤,១០ សីហា ២០០៧, មាត្រា៩។

[59] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /១១០៩/ ០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៤៩។

ចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទៀតឡើយ។ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះត្រូវបញ្ចប់។ ប្រសិនបើការផ្តន្ទាទោសជាស្ថាពរត្រូវបានប្រកាសរួចហើយទោសដែលចេញពីការផ្តន្ទាទោសនេះមិនត្រូវអនុវត្តទេ ឬត្រូវតែឈប់អនុវត្ត។[60]

**២.២.៥. អាជ្ញាអស់ជំនុំ**

ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរ ហើយជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។[61]

មូលហេតុផ្សេងទៀតនៃការផុតរលត់បណ្តឹងអាជ្ញា៖

- ការសម្របសម្រួលជាមួយរដ្ឋ
- ការដកពាក្យបណ្តឹងក្នុងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ
- ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល។[62]
- អភ័យឯកសិទ្ធិគ្រួសារ[63]
- ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនល្មើស។[64]

[60] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /១១០៩/ ០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៩។
[61] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /១១០៩/ ០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៩។
[62] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤,១០ សីហា ២០០៧, មាត្រា៨។
[63] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /១១០៩/ ០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៥។
[64] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /១១០៩/ ០២២,៣០ វិច្ឆិកា ២០០៩, ចាប់ពីមាត្រា៣១ ដល់មាត្រា៣៩។

# ជំពូកទី២៖ ការអនុវត្តសាលក្រមរបស់អយ្យការ

## ផ្នែកទី១៖ គោលការណ៍ទូទៅនៃការអនុវត្តសាលក្រម

### កថាខណ្ឌទី១៖ អំពីសាលក្រមព្រហ្មទណ្ឌ

**១.១. ការប្រកាសសាលក្រម**

**១.១.១. និយមន័យសាលក្រម**

សាលក្រមព្រហ្មទណ្ឌ(សាលក្រមអង្គសេចក្តី) គឺជាសេចក្តីសម្រេចរបស់តុលាការជាន់ដំបូងដែលសម្រេចអំពីភាពមានពិរុទ្ធ ឬ គ្មានពិរុទ្ធរបស់ជនជាប់ចោទ។

**១.១.២. ការប្រកាសសាលក្រម**

សាលក្រមត្រូវសម្រេចចេញនៅពេលសវនាការ ដែលធ្វើការពិភាក្សាដេញដោល ឬ នៅពេលសវនាការលើកក្រោយ ដែលកាលបរិច្ឆេទត្រូវកំណត់ដោយប្រធានសវនាការ។ គ្រប់សាលក្រមត្រូវតែប្រកាសនៅពេលសវនាការសាធារណៈ។ ផ្នែកនៃសេចក្តីសម្រេចត្រូវអានដោយសម្លេងខ្លាំងៗ ដោយប្រធានសវនាការ។[65]

**១.២. ប្រភេទសាលក្រមព្រហ្មទណ្ឌ(សាលក្រមអង្គសេចក្តី)**

**១.២.១. សាលក្រមចំពោះមុខ**

សំដៅលើសាលក្រមដែលធ្វើចំពោះមុខជនជាប់ចោទ និងមានវត្តមាននៅក្នុងបន្ទប់សវនាការផ្ទាល់តែម្តង។ ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការ នោះសាលក្រមជាសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមចំពោះមុខជនជាប់ចោទមិនត្រូវឱ្យដំណឹងដល់ជននោះទេ។ សាលក្រមក៏នៅតែជាសាលក្រមចំពោះមុខដដែលទោះបីជាជនជាប់ចោទចាកចេញពីបន្ទប់សវនាការក៏ដោយ។ ប្រសិនបើជនជាប់ចោទមិនអាចចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការ ដោយមូលហេតុស្ថានភាពសុខភាព ឬដោយមូលហេតុធ្ងន់ធ្ងរ ហើយតុលាការបានធ្វើការសួរចម្លើយជនជាប់ចោទនៅទីកន្លែងដែលជននោះនៅ សាលក្រមនោះក៏ទុកជាសាលក្រមចំពោះមុខដែរ។ សាលក្រមចំពោះមុខជនជាប់ចោទមិនត្រូវជូនដំណឹងដល់ដល់ជននោះទេ។[66]

**១.២.២. សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ**

សាលក្រមដែលចាត់ទុកថាចំពោះមុខ សំដៅសេចក្តីសម្រេចបន្ទាប់ពីការប្រកាសសាលក្រមហើយតុលាការបានជូនដំណឹងទៅដល់ផ្ទះ ឬសាច់ញាតិរបស់ជនជាប់ចោទនោះ។ ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ប៉ុន្តែសាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ឬបានដឹងពីការកោះហៅហើយនោះ

[65] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤,១០ សីហា ២០០៧, មាត្រា៣៤៧។

[66] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤,១០ សីហា ២០០៧, មាត្រា៣៦០។

សាលក្រមត្រូវចាត់ទុកថាជាសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមចាត់ទុកថាចំពោះមុខនេះត្រូវឱ្យដំណឹងដល់ ជនជាប់ចោទនោះ។[67]

**១.២.៣. សាលក្រមកំបាំងមុខ**

សំដៅដល់សាលក្រមដែលសម្រេចសេចក្តីដោយពុំមានគូភាគីណាម្ខាង ឬគ្មានវត្តមានភាគីណាមួយក្នុងពេលកាត់សេចក្តី។

ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ និងប្រសិនបើគ្មានភស្តុតាងបង្ហាញឱ្យឃើញថាសាមីខ្លួនដឹងពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងអំពីការកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងមុខជនជាប់ចោទត្រូវឱ្យដំណឹងដល់ជនជាប់ចោទនោះ។ សាលក្រមនេះអាចត្រូវប្តឹងទាស់បាន។[68]

**កថាខណ្ឌទី២៖ ការជូនដំណឹងអំពីសាលក្រម**

**២.១. ដីកាឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ**

**២.១.១. កម្មវត្ថុនៃដីកាឱ្យដំណឹង**

ដីកាឱ្យដំណឹងគឺជា លិខិតដែលឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ដែលបញ្ញត្តិច្បាប់តម្រូវឱ្យជូនដំណឹងដល់ភាគីពាក់ព័ន្ធ ដើម្បីឱ្យភាគីពាក់ព័ន្ធទទួលបានដំណឹងអំពីសេចក្តីសម្រេចនោះដោយតុលាការទុកសិទ្ធិដើម្បីប្តឹងឧទ្ធរណ៍ ។ ដីកាឱ្យដំណឹងត្រូវធ្វើតាមគំនិតផ្តួចផ្តើមរបស់ព្រះរាជអាជ្ញា របស់អគ្គព្រះរាជអាជ្ញា ឬរបស់ភាគី។[69]

**២.១.២. និទ្ទេសដែលត្រូវចុះលើដីកាឱ្យដំណឹង**

ចំពោះដីកាឱ្យដំណឹងត្រូវចុះនិទ្ទេសដូចតទៅ៖

- ប្រភេទ និងការយោងនៃសេចក្តីសម្រេចដែលត្រូវជូនដំណឹង
- អត្តសញ្ញាណ និងលំនៅឋាននៃភាគីដែលត្រូវទទួលដំណឹងអំពីសេចក្តីសម្រេច
- កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកដែលធ្វើការជូនដំណឹង

ដីកាឱ្យដំណឹងបញ្ជាក់ប្រាប់អំពីផ្លូវតវ៉ាដែលអាចធ្វើទៅបាន ប្រឆាំងទៅនឹងសេចក្តីសម្រេចដែលត្រូវបានជូនដំណឹង។ លិខិតចម្លងនៃសេចក្តីសម្រេចដែលត្រូវជូនដំណឹង ត្រូវភ្ជាប់ទៅនឹងដីកាឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ។[70]

**២.២. ការទទួលបន្ទុកជូនដំណឹងអំពីសាលក្រម**

**២.២.១. ការជូនដំណឹងដែលធ្វើឡើងដោយព្រះរាជអាជ្ញា**

ការជូនដំណឹងដល់ភាគីពាក់ព័ន្ធអាចត្រូវធ្វើដោយព្រះរាជអាជ្ញា។ ក្នុងករណីនេះព្រះរាជអាជ្ញាប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចរបស់តុលាការឱ្យដល់ភាគីពាក់ព័ន្ធ។ ព្រះរាជអាជ្ញាចុះនិទ្ទេសលើសេចក្តីសម្រេចដើមអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់លិខិតចម្លង។ ភាគីពាក់ព័ន្ធចុះហត្ថលេខានៅលើសេចក្តីសម្រេចដើមនេះ។

---

[67] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤,១០ សីហា ២០០៧, មាត្រា៣៦១។

[68] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤,១០ សីហា ២០០៧, មាត្រា៣៦២។

[69] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤,១០ សីហា ២០០៧, មាត្រា៤៨២។

[70] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤,១០ សីហា ២០០៧, មាត្រា៤៨៣។

### ២.២.២. ការជូនដំណឹងដែលធ្វើឡើងដោយអាជ្ញាសាលា

ការជូនដំណឹងក៏អាចត្រូវធ្វើឡើងដោយអាជ្ញាសាលាផងដែរ។ អាជ្ញាសាលាប្រើគ្រប់មធ្យោបាយ ដើម្បីជូនដំណឹងដល់បុគ្គលពាក់ព័ន្ធអំពីសេចក្តីសម្រេចរបស់តុលាការ។

ការប្រគល់ការជូនដំណឹងធ្វើតាមមធ្យោបាយដូចតទៅៈ

- ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់ភាគីពាក់ព័ន្ធ

ប្រសិនបើអាជ្ញាសាលាជួបប្រទះភាគីពាក់ព័ន្ធនៅក្នុងលំនៅឋាន ឬនៅទីកន្លែងដទៃទៀតអាជ្ញាសាលាត្រូវប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់ភាគីពាក់ព័ន្ធ។ អាជ្ញាសាលាត្រូវចារលើសេចក្តីសម្រេចដើមថាលិខិតចម្លងត្រូវបានប្រគល់ឱ្យភាគីពាក់ព័ន្ធដោយផ្ទាល់ដៃ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់លិខិតចម្លង។ ភាគីពាក់ព័ន្ធចុះហត្ថលេខាលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមនេះត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញជាបន្ទាន់។[71]

- ករណីអវត្តមានភាគីពាក់ព័ន្ធ

ប្រសិនបើភាគីពាក់ព័ន្ធអវត្តមានពីលំនៅឋានអាជ្ញាសាលា ត្រូវប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចឱ្យបុគ្គលជានីតិជនដែលមានវត្តមាននៅក្នុងលំនៅឋាន។ អាជ្ញាសាលាត្រូវចារលើសេចក្តីសម្រេចដើមថាលិខិតចម្លងនៃសេចក្តីសម្រេចត្រូវបានប្រគល់ឱ្យដល់ដៃបុគ្គលដែលមានវត្តមាននៅក្នុងលំនៅឋាន។ អាជ្ញាសាលាត្រូវចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនោះ កាលបរិច្ឆេទប្រគល់លិខិតចម្លងនៃសេចក្តីសម្រេច។បុគ្គលដែលទទួលលិខិតត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមនេះត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញភ្លាម។

បុគ្គលដែលទទួលលិខិតចម្លងនៃសេចក្តីសម្រេចត្រូវសន្យាថានឹង ប្រគល់ឱ្យដល់ភាគីពាក់ព័ន្ធក្នុងរយៈពេលដ៏ខ្លីបំផុត។ ក្នុងករណីនេះ លិខិតចម្លងនៃសេចក្តីសម្រេចត្រូវដាក់ក្នុងស្រោមសំបុត្របិទជិតដោយមានចុះនិទ្ទេសដូចតទៅៈ ឈ្មោះ និងអាសយដ្ឋានរបស់សាមីខ្លួនដែលត្រូវទទួលដីកានៅផ្នែកខាងមុខស្រោមសំបុត្រ ត្រារបស់អ្នកប្រគល់ដីកានៅផ្នែកខាងក្រោយស្រោមសំបុត្រ។[72]

- ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់មេឃុំ ឬ ចៅសង្កាត់

អាជ្ញាសាលាប្រគល់លិខិតនៃសេចក្តីសម្រេចទៅមេឃុំ ឬចៅសង្កាត់ ឬទៅជំទប់ ឬចៅសង្កាត់រងណាមួយនៅក្នុងករណីដូចតទៅៈ

- ភាគីពាក់ព័ន្ធមិនព្រមទទួលសេចក្តីសម្រេច
- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធទេ
- គ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធ យល់ព្រមទទួលសេចក្តីសម្រេចនោះទេ។

---

[71] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤,១០ សីហា ២០០៧, មាត្រា៤៨៦។

[72] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤,១០ សីហា ២០០៧, មាត្រា៤៨៧។

អាជ្ញាសាលាចុះនិទ្ទេសនៅលើសេចក្តីសម្រេចដើមអំពីអត្តសញ្ញាណ និង ឋានៈរបស់បុគ្គលដែលបានទទួលលិខិតចម្លងនៃសេចក្តីសម្រេច ព្រមទាំងកាលបរិច្ឆេទនៃការប្រគល់។ បុគ្គលដែលទទួលលិខិតចម្លងចុះហត្ថលេខានៅលើសេចក្តីសម្រេចដើម។ សេចក្តីសម្រេចដើមត្រូវបង្វិលជូនទៅព្រះរាជអាជ្ញាវិញភ្លាម។
បុគ្គលដែលទទួលលិខិតចម្លងនៃសេចក្តីសម្រេចត្រូវសន្យាថានឹងប្រគល់ឱ្យដល់ភាគីពាក់ព័ន្ធក្នុងរយៈពេលដ៏ខ្លីបំផុត។ ក្នុងករណីនេះ លិខិតចម្លងនៃសេចក្តីសម្រេចត្រូវដាក់ក្នុងស្រោមសំបុត្របិទជិតដោយមានចុះនិទ្ទេសដូចតទៅៈ ឈ្មោះ និងអាសយដ្ឋានរបស់សាមីខ្លួនដែលត្រូវទទួលដីកានៅផ្នែកខាងមុខស្រោមសំបុត្រ ត្រារបស់អ្នកប្រគល់ដីកានៅផ្នែកខាងក្រោយស្រោមសំបុត្រ។[73]

- ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចចំពោះភាគីដែលពុំមានលំនៅឋាន ឬទីសំណាក់ដែលគេស្គាល់

ប្រសិនបើភាគីពាក់ព័ន្ធគ្មានលំនៅឋាន ឬទីសំណាក់ទេ ឬ ប្រសិនបើភាគីពាក់ព័ន្ធនេះរស់នៅក្រៅដែនដីជាតិ សេចក្តីសម្រេចរបស់តុលាការក៏អាចត្រូវជូនដំណឹងដល់សាមីខ្លួនបានដែរ។ ក្នុងករណីនេះកាលបរិច្ឆេទនៃសេចក្តីសម្រេចតុលាការត្រូវចាត់ទុកថាជាកាលបរិច្ឆេទនៃការជូនដំណឹង។

ក្នុងករណីដែលការប្រគល់ការជូនដំណឹងត្រូវបានធ្វើតាមវិធីដូចដែលបានរៀបរាប់ខាងលើ គឺមានន័យថាការជូនដំណឹងត្រូវបានធ្វើត្រឹមត្រូវតាមនីតិវិធីរួចហើយ។[74]

### ២.៣. របៀបផ្សេងទៀតនៃការជូនដំណឹង

ក្រៅពីព្រះរាជអាជ្ញា និងអាជ្ញាសាលា ការជូនដំណឹងក៏អាចប្រគល់ឱ្យផងដែរៈ

- ដោយក្រឡាបញ្ជី
- តាមផ្លូវរដ្ឋបាល
- ដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទដទៃផ្សេងទៀត
- តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។

## ផ្នែកទី២៖ ការអនុវត្តសាលក្រមរបស់ព្រះរាជអាជ្ញា

ការអនុវត្តសាលក្រមព្រហ្មទណ្ឌ គឺជាការអនុវត្តនូវខ្លឹមសារនៃសាលក្រម ហើយនៅក្នុងសាលក្រមព្រហ្មទណ្ឌគឺមានសម្រេចអំពីទណ្ឌកម្មផ្នែកព្រហ្មទណ្ឌដែលជាទោសព្រហ្មទណ្ឌ។ ដូចនេះបើនិយាយនៅក្នុងវិសាលភាពនៃសាលក្រមព្រហ្មទណ្ឌលើអង្គសេចក្តីត្រង់ចំណុចដែលសម្រេចអំពីទោស មានន័យថាជាការអនុវត្តទៅលើទោសព្រហ្មទណ្ឌ។ អង្គការអយ្យការជានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងជានាយកចិត្ត

[73] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤,១០ សីហា ២០០៧, មាត្រា៤៨៨។
[74] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /០៨០៧/ ០២៤,១០ សីហា ២០០៧, មាត្រា៤៩០។

ទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។[75] នៅក្នុងរឿងព្រហ្មទណ្ឌទោសព្រហ្មទណ្ឌត្រូវបានបែងចែកជាបីប្រភេទរួមមាន៖ មូលទោស ទោសបន្ថែម និងទោសជំនួស។ អង្គការអយ្យការធ្វើការអនុវត្តទោស នៅពេលដែលសេចក្ដីសម្រេចរបស់តុលាការបានក្លាយទៅជាស្ថាពរ។[76] ការអនុវត្តទោស និងការបង្ខំដល់រូបកាយត្រូវធ្វើតាមគំនិតផ្ដើមរបស់អយ្យការ។[77]

**កថាខណ្ឌទី១៖ ការអនុវត្តមូលទោស**

យោងតាមក្រមព្រហ្មទណ្ឌ មាត្រា៤៣ បានកំណត់មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ការអនុវត្តមូលទោសគឺសំដៅទៅលើ **ការអនុវត្តនូវទោសពន្ធនាគារ** (១.១) និង**ការអនុវត្តទោសពិន័យជាប្រាក់**(១.២)។

**១.១. ការអនុវត្តទោសពន្ធនាគារ**

ពន្ធនាគារ គឺជាកន្លែងដែលបង្កើតឡើងស្របច្បាប់ សម្រាប់ឃុំអ្នកទោសតាមអំណាច នៃសាលក្រម ឬ ការវិនិច្ឆ័យសម្រេចត្រឹមត្រូវតាមច្បាប់ពីតុលាការមានសមត្ថកិច្ច។ ពន្ធនាគារមិនមែនជាកន្លែងសម្រាប់ស៊ើបអង្កេតស្រាវជ្រាវ សួរចម្លើយ ឬធ្វើទារុណកម្ម និងមិនមែនជាកន្លែងសម្រាប់ប្រើប្រាស់ឃុំខ្លួនជនសង្ស័យរយៈពេល ៤៨ម៉ោងនោះដែរ។[78] ការអនុវត្តមូលទោសក៏ត្រូវអនុវត្តចំពោះការព្យួរទោសផងដែរ ដោយព្រះរាជអាជ្ញាត្រូវធ្វើការត្រួតពិនិត្យទៅលើវិធានការដែលតម្រូវទៅលើទណ្ឌិតមានដូចតទៅ៖

- ចេញដីកាកោះចំពោះទណ្ឌិតដែលត្រូវបានព្យួរទោស
- ពិនិត្យឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ
- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការផ្លាស់ប្ដូរអាសយដ្ឋានរបស់ខ្លួន
- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការផ្លាស់ប្ដូរមុខរបររបស់ខ្លួន
- ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស។[79]

**១.១.១. វិធានទាក់ទងនឹងការឃុំខ្លួន**

គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួនដោយបំពានឡើយ។[80] គ្មានជនណាម្នាក់ត្រូវទទួលទារុណកម្ម ឬទណ្ឌកម្ម ឬប្រព្រឹត្តិកម្មកាចសាហាវ ឥតមនុស្សធម៌ ឬថោកទាបបានឡើយ។[81] ជាគោលការណ៍

---

[75] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ឆ្នាំ២០០៧, មាត្រា២៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

[76] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ឆ្នាំ២០០៧, មាត្រា៤៩៧ កថាខណ្ឌទី១។

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ឆ្នាំ២០០៧, មាត្រា៤៩៦។

[78] ប្រកាសស្ដីពីការគ្រប់គ្រងពន្ធនាគារ, លេខ៦១៧ ប្រក,៣១ មិនា ឆ្នាំ១៩៩៨, ប្រការ១ ចំណុច១-ក។

[79] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /១១០៩/ ០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១១៩។

[80] សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិឆ្នាំ១៩៤៨, មាត្រា៩។

[81] សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិឆ្នាំ១៩៤៨, មាត្រា៥។

ការឃុំខ្លួនបុគ្គលណាម្នាក់ដាច់ខាតត្រូវតែមានលិខិតដែលចេញដោយអាជ្ញាធរតុលាការ មានន័យថាមុនពេលដែលទទួលយកជនជាប់ឃុំ ឬ ទណ្ឌិតចូលពន្ធនាគារ ប្រធានពន្ធនាគារ ឬ មន្ត្រីពន្ធនាគារដែលទទួលបានការចាត់តាំង ត្រូវត្រួតពិនិត្យអត្តសញ្ញាណជនជាប់ឃុំ ឬ ទណ្ឌិតនោះឱ្យបានត្រឹមត្រូវតាមលិខិតឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការ។ ក្នុងច្បាប់ក៏បានបញ្ញត្តិផងដែរ គ្មានភ្នាក់ងាររដ្ឋបាលពន្ធនាគារណា អាចទទួល និងឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតចេញដោយអាជ្ញាធរតុលាការបានឡើយ។ ភ្នាក់ងាររដ្ឋបាលពន្ធនាគារណាដែលបានទទួល និងឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតចេញដោយអាជ្ញាធរតុលាការទេនោះ ត្រូវជាប់ពិរុទ្ធពីបទបង្ខាំងមនុស្សដោយខុសច្បាប់។ [82]

**១.១.១.១. ការគណនាថិរវេលានៃការដាក់ពន្ធនាគារ**

ថិរវេលានៃការដាក់ពន្ធនាគារត្រូវគោរពនូវថិរវេលាដូចខាងក្រោម៖

- ទោសដាក់ពន្ធនាគារក្នុង ១ (មួយ) ថ្ងៃ មានថិរវេលា ២៤ (ម្ភៃបួន) ម៉ោង។
- ទោសដាក់ពន្ធនាគារក្នុង ១ (មួយ) ខែ មានថិរវេលា ៣០ (សាមសិប) ថ្ងៃ។
- ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែងដែលមាននៅក្នុងខែនោះ។
- ទោសដាក់ពន្ធនាគារ ១(មួយ) ឆ្នាំត្រូវគិត១២ (ដប់ពីរ)ខែ។[83]
- ទណ្ឌិតដែលបានអនុវត្តទោសរបស់ខ្លួនរួចហើយ ត្រូវដោះលែងនៅក្នុងចន្លោះពីម៉ោង៦ ព្រឹក ដល់ម៉ោង ១៨ ល្ងាច។[84]

**១.១.១.២. ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន**

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដែលបានប្រកាស ឬ ជាយថាហេតុនៃថិរវេលាសរុបនៃទោសដែលត្រូវទទួលរងបន្ទាប់ពីការស្រូបទោសបញ្ចូលគ្នា។[85] នេះជាការការពារនូវផលប្រយោជន៍របស់ទណ្ឌិត ដែលត្រូវបានដកហូតសេរីភាពនៅក្នុងដំណើរការនីតិវិធីមុនសាលក្រមស្ថាពរ។

**១.១.១.៣. បញ្ជីជនជាប់ឃុំ និងលិខិតឃុំខ្លួន**

**១.១.១.៣.១. បញ្ជីជនជាប់ឃុំ**

គ្រប់ពន្ធនាគារ និងមណ្ឌលឃុំខ្លួនទាំងអស់ ត្រូវមានបញ្ជីមួយដែលចុះនិទ្ទេសអំពីអត្តសញ្ញាណបុគ្គលឃុំខ្លួន កាលបរិច្ឆេទឃុំខ្លួន និងកាលបរិច្ឆេទដោះលែង។ បញ្ជីនេះត្រូវបានត្រួតពិនិត្យជារឿយៗដោយអយ្យការ។ ទំព័រនីមួយៗ ត្រូវតែចុះទិដ្ឋាការដោយអយ្យការ។ គ្រប់ភ្នាក់ងារនៃរដ្ឋបាលពន្ធនាគារ និងមណ្ឌលឃុំខ្លួន ត្រូវតែជូនបញ្ជីទៅចៅក្រមពិនិត្យមើលតាមការស្នើសុំ ព្រមទាំងបង្ហាញដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលបំពេញភារកិច្ចតាមការ

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ឆ្នាំ២០០៧, មាត្រា៥០៦។

[83] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, នស/ រកម /១១០៩/ ០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៩។

[84] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ឆ្នាំ២០០៧, មាត្រា៥០២។

[85] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ឆ្នាំ២០០៧, មាត្រា៥០៣។

ប្រគល់អំណាចពីអាជ្ញាធរតុលាការ។[86] បញ្ជីជនជាប់ឃុំ ឬបញ្ជីឈ្មោះអ្នកទោស ក៏មានកំណត់ផងដែរនៅក្នុងប្រកាសស្ដីពី ការគ្រប់គ្រងពន្ធនាគារ។ ពន្ធនាគារនីមួយៗ ត្រូវរក្សាបញ្ជីឈ្មោះអ្នកទោស។ បញ្ជីនោះត្រូវមានលេខរៀងជាបន្តបន្ទាប់លើទំព័រនីមួយៗ ហើយត្រូវមានព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់អ្នកទោសម្នាក់ៗ មូលហេតុនៃការឃុំខ្លួន សេចក្ដីលម្អិតពីការកាត់ទោស និងការដោះលែង ព្រមទាំងព័ត៌មានផ្សេងៗទៀតដែលតំរូវដោយនាយកដ្ឋានពន្ធនាគារ។[87] ចំពោះជនជាប់ឃុំជាស្ត្រីភេទ និងជនជាប់ឃុំជាអនីតិជន ត្រូវមានបញ្ជីដោយឡែក ហើយត្រូវយកចិត្តទុកដាក់ជាពិសេសដល់ការគ្រប់គ្រងជនជាប់ឃុំទាំងពីរប្រភេទនេះ។[88]

#### ១.១.១.៣.២. លិខិតឃុំខ្លួន

គ្មានភ្នាក់ងាររដ្ឋបាលពន្ធនាគារណា អាចទទួល និងឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតចេញដោយអាជ្ញាធរតុលាការបានឡើយ។ ភ្នាក់ងាររដ្ឋបាលពន្ធនាគារណាដែលបានទទួល និងឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតចេញដោយអាជ្ញាធរតុលាការទេនោះ ត្រូវជាប់ពិរុទ្ធពីបទបង្ខាំងមនុស្សដោយខុសច្បាប់។[89] គ្មានទោសណាមួយដែលត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការទេ។[90] ពន្ធនាគារនីមួយៗ ត្រូវទទួលយកតែអ្នកទោសណា ដែលបញ្ជូនមក ដោយមានដីកាឃុំខ្លួន ឬសាលក្រម ឬការវិនិច្ឆ័យសម្រេចត្រឹមត្រូវតាមផ្លូវច្បាប់ពីតុលាការមានសមត្ថកិច្ច។[91] មុនពេលទទួលយកជនជាប់ឃុំចូលក្នុងពន្ធនាគារ ប្រធានពន្ធនាគារ ឬមន្ត្រីពន្ធនាគារដែលបានទទួលការចាត់តាំង ត្រូវត្រួតពិនិត្យអត្តសញ្ញាណរបស់ជនជាប់ឃុំឲ្យបានត្រឹមត្រូវ តាមលិខិតឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការ។[92]

### ១.១.២. ដំណើរការនៃការអនុវត្តទោសនៅពន្ធនាគារ

ការទទួល ឬការឃុំខ្លួនជនណាម្នាក់នៅក្នុងពន្ធនាគារបាន លុះត្រាតែមានលិខិតឃុំខ្លួនដែលចេញពីអាជ្ញាធរតុលាការ។[93] ជាគោលការណ៍ ការអនុវត្តសេចក្ដីសម្រេចរបស់តុលាការគឺជាតួនាទីរបស់អយ្យការ ប៉ុន្តែដើម្បីឲ្យការអនុវត្តសេចក្ដីសម្រេចនេះ មានដំណើរការល្អនិងគ្រប់ជ្រុងជ្រោយ គឺត្រូវមានការចូលរួមពីស្ថាប័នពាក់ព័ន្ធជាច្រើន មានដូចជាមន្ត្រីពន្ធនាគារជាដើម ដែលមានតួនាទីក្នុងការគ្រប់គ្រងទណ្ឌិតជាអាទិ៍។

#### ១.១.២.១. ការទទួលឱ្យចូលឃុំខ្លួន

**ក.** ពន្ធនាគារនីមួយៗ ត្រូវទទួលយកតែអ្នកទោសណា ដែលបញ្ជូនមកដោយមានដីកាឃុំខ្លួន ឬសាលក្រម ឬការវិនិច្ឆ័យសម្រេចត្រឹមត្រូវតាមច្បាប់ពីតុលាការមានសមត្ថកិច្ច។

---

[86] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ឆ្នាំ២០០៧, មាត្រា៥០៥។
[87] ប្រកាសស្ដីពីការគ្រប់គ្រងពន្ធនាគារ, លេខ៦១៧ ប្រក,៣១ មិនា ឆ្នាំ១៩៩៨, ប្រការ៤ ចំណុចទី១ ចំណុចខ។
[88] ច្បាប់ស្ដីពីពន្ធនាគារ, លេខ នស/រកម/១២១១/០២១,២១ ធ្នូ ឆ្នាំ២០១១, មាត្រា២១ កថាខណ្ឌទី២។
[89] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ឆ្នាំ២០០៧, មាត្រា៥០៦។
[90] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ឆ្នាំ២០០៩។
[91] ប្រកាសស្ដីពីការគ្រប់គ្រងពន្ធនាគារ, លេខ៦១៧ ប្រក,៣១ មិនា ឆ្នាំ១៩៩៨, ប្រការ៤ ចំណុចទី១ ចំណុចក។
[92] ច្បាប់ស្ដីពីពន្ធនាគារ, លេខ នស/រកម/១២១១/០២១,២១ ធ្នូ ឆ្នាំ២០១១, មាត្រា១៨។
[93] ច្បាប់ស្ដីពីពន្ធនាគារ, លេខ នស/រកម/១២១១/០២១,២១ ធ្នូ ឆ្នាំ២០១១, មាត្រា១៧។

**ខ.** ពន្ធនាគារនីមួយៗ ត្រូវរក្សាបញ្ជីឈ្មោះអ្នកទោស។ បញ្ជីនោះត្រូវមានលេខរៀងបន្តបន្ទាប់លើទំព័រនីមួយៗ ហើយត្រូវមានព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់អ្នកទោសម្នាក់ៗ មូលហេតុនៃការឃុំខ្លួន សេចក្តីលំអិតស្តីពីការកាត់ទោស និងការដោះលែង ព្រមទាំងព័ត៌មានផ្សេងៗទៀតដែលតម្រូវដោយនាយកដ្ឋានពន្ធនាគារ។

**គ.** អ្នកផ្តល់ការថែទាំសុខភាព ត្រូវពិនិត្យឡើងវិញនូវលក្ខណៈសុខភាពរបស់អ្នកទោសទាំងអស់ឱ្យបានឆាប់បំផុត បន្ទាប់ពីការទទួលយកអ្នកទោសចូលក្នុងពន្ធនាគារ។ បើសិនជាអ្នកទោសណាម្នាក់មានជំងឺ ឬមានរបួសនៅពេលទទួលយកចូលក្នុងពន្ធនាគារ ប្រធានពន្ធនាគារត្រូវរៀបចំព្យាបាលសុខភាពឱ្យបានឆាប់បំផុត បើអាចធ្វើទៅបាន ហើយត្រូវសរសេរលំអិតពីរបួស ឬជំងឺនីមួយៗនៅក្នុងឯកសារផ្ទាល់ខ្លួនរបស់អ្នកទោស។

**ឃ.** បន្ទាប់ពីទទួលយកចូលក្នុងពន្ធនាគារអ្នកទោសគ្រប់រូបត្រូវបានអនុញ្ញាតឱ្យរកមេធាវី ក្នុងគោលបំណងប្តឹងឧទ្ធរណ៍ ឬដោះស្រាយបញ្ហាពាក់ព័ន្ធរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ដែលមិនទាន់ដោះស្រាយរួចនៅឡើយ។

**ង.** ត្រូវថតរូបអ្នកទោសជាបន្ទាន់ បន្ទាប់ពីការយកចូលពន្ធនាគាររួចមក ហើយត្រូវថតរូបអ្នកទោសនោះជាបន្តបន្ទាប់ទៀត បើសិនជារូបកាយរបស់គេ មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់។

**ច.** អ្នកទោសទាំងអស់ត្រូវបានអនុញ្ញាតឱ្យផ្តល់ព័ត៌មានទៅគ្រួសារ ឬសាច់ញាតិរបស់ខ្លួន អំពីការជាប់ពន្ធនាគារ បន្ទាប់ពីទទួលយកចូលក្នុងពន្ធនាគារ។

**ឆ.** នៅពេលទទួលយកចូលអ្នកទោស ជាជនបរទេសត្រូវបានគេផ្តល់ព័ត៌មានជាភាសាណាមួយដែលគេអាចយល់បានអំពីសិទ្ធិ ជូនដំណឹងទៅស្ថានទូត ស្ថានកុងស៊ុល ឬអង្គការពាក់ព័ន្ធដទៃទៀតរបស់ខ្លួនអំពីការជាប់ពន្ធនាគារ និងត្រូវបានផ្តល់ឱកាសដ៏សមហេតុផលដើម្បីធ្វើការងារនេះបន្ទាប់ពីទទួលយកចូលក្នុងពន្ធនាគារ។ បើសិនជាអ្នកទោសជាជនបរទេស មិនអាចផ្តល់ព័ត៌មានជូន ស្ថានទូត ស្ថានកុងស៊ុល ឬអង្គការពាក់ព័ន្ធរបស់ខ្លួនបានទេនោះ ប្រធានពន្ធនាគារត្រូវបំពេញការងារនេះជាបន្ទាន់ជំនួសអ្នកទោសដោយអនុលោមតាមនីតិវិធីពន្ធនាគារ។

**ជ.** នៅពេលទទួលយកចូលក្នុងពន្ធនាគារ អ្នកទោសគ្រប់រូបត្រូវបានគេណែនាំពីសិទ្ធិរបស់ខ្លួន និងត្រូវរៀនសូត្រពីបទបញ្ជាផ្ទៃក្នុងពន្ធនាគារ និងនីតិវិធីផ្សេងៗដែលបានអនុញ្ញាតដើម្បីស្វែងរកព័ត៌មាន ឬធ្វើការប្តឹងតវ៉ាដោយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ ប៉ុន្តែត្រូវស្ថិតក្នុងទម្រង់ និងភាសាណាមួយដែលអ្នកទោសអាចយល់បាន។[94]

**១.១.២.២. ការបែងចែកទីកន្លែងឃុំខ្លួនតាមប្រភេទទណ្ឌិត**

**ក.** អ្នកទោសស្ត្រី និងអ្នកទោសបុរសត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីគ្នា

**ខ.**ប្រសិនបើអគារពន្ធនាគារអាចធានាបានត្រូវដាក់ឱ្យនៅដោយឡែកពីគ្នានូវប្រភេទអ្នកទោសដូចខាងក្រោម៖

- ត្រូវដាក់អ្នកទោសដែលមានអាយុក្រោម១៨ឆ្នាំ ឱ្យនៅដោយឡែកពីអ្នកទោសដែលមានវ័យចាស់
- ត្រូវដាក់ពិរុទ្ធជន ឱ្យនៅដោយឡែកពីទណ្ឌិត

---

[94] ប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ, លេខ៦១៧ ប្រក,៣១ មិនា ឆ្នាំ១៩៩៨, ប្រការ៤ ចំណុចទី១។

- អ្នកទោសដែលរត់គេចខ្លួនពីពន្ធនាគារ ឬបានប្រព្រឹត្តផ្ទុយនឹងសន្តិសុខសណ្តាប់ធ្នាប់ល្អក្នុងពន្ធនាគារ

- អ្នកទោសកម្រិតធ្ងន់ឱ្យនៅដោយឡែកពីអ្នកទោសកម្រិតស្រាល

- អ្នកទោសដែលមានជំងឺផ្លូវកាយ ផ្លូវចិត្ត ឬរបួសដែលប៉ះពាល់ដល់សុខភាព ឬសុខុមាលភាពរបស់ខ្លួន ឬអ្នកទោសដទៃទៀត។[95]

### ១.១.២.៣. ការផ្ទេរ ឬផ្លាស់ប្តូរទីកន្លែងឃុំខ្លួន

**ក.** ការផ្ទេរអ្នកទោសណាម្នាក់ជាលក្ខណៈរដ្ឋបាលអាចធ្វើទៅបាន នៅពេលដែលមានសំណើសុំជាលាយលក្ខណ៍អក្សរតាមរយៈប្រធានពន្ធនាគារ

**ខ.** នៅពេលផ្ទេរអ្នកទោសទៅកាន់ពន្ធនាគារណាមួយ ប្រធានពន្ធនាគារត្រូវរៀបចំបញ្ជូនសំណុំឯកសារទាំងអស់របស់អ្នកទោស របាយការណ៍ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ពួកគេទៅឱ្យប្រធានពន្ធនាគារដែលត្រូវផ្ទេរទៅ។ បញ្ជីផ្ទេរអ្នកទោសត្រូវចុះហត្ថលេខាទទួលដោយប្រធានពន្ធនាគារ ហើយត្រូវប្រគល់អត្ថបទចម្លងមួយច្បាប់ទៅមន្ត្រីទទួលបន្ទុកការផ្ទេរវិញ។ អ្នកទោសទាំងឡាយដែលបានផ្ទេរទៅកាន់ពន្ធនាគារមួយទៀតត្រូវបានគេផ្តល់ឱកាសដើម្បីជូនដំណឹងទៅក្រុមគ្រួសារ ឬសាច់ញាតិភ្លាមៗបន្ទាប់ពីការផ្ទេរនោះ។

**គ.** ក្នុងការយកអ្នកទោសចេញ ប្រធានពន្ធនាគារត្រូវមានលិខិតជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីមូលហេតុដូចខាងក្រោម៖

-បន្ទាប់ពីអ្នកថែទាំសុខភាពពិនិត្យឃើញថាអ្នកទោសណាម្នាក់មានជំងឺ ឬ របួសដែលតម្រូវឱ្យពិនិត្យព្យាបាលនៅមណ្ឌលសុខភាពខាងក្រៅ ដូចជាមន្ទីរពេទ្យជាដើម

-នៅពេលដែលអ្នកទោសណាម្នាក់ត្រូវបានអនុញ្ញាតឱ្យធ្វើការនៅក្រៅពន្ធនាគារ។

**ឃ.** ត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីតុលាការ ក្នុងការយកអ្នកទោសចេញទៅបង្ហាញខ្លួនដូចខាងក្រោម៖

-ពេលឡើងសវនាការ

-ពេលឡើងឧទ្ធរណ៍

-ពេលស៊ើបសួរព័ត៌ ឬស៊ើបអង្កេត

-ពេលផ្តល់វត្តុតាង។

**ង.** នៅពេលអ្នកទោសត្រូវបានផ្លាស់ប្តូរទៅពន្ធនាគារ ឬមកពីពន្ធនាគារមួយផ្សេងទៀត ការផ្លាស់ប្តូរនោះត្រូវធ្វើឡើងដោយសេចក្តីថ្លៃថ្នូរ និងការពារសុវត្ថិភាពឱ្យបានត្រឹមត្រូវ។

**ច.** អ្នកទោសដែលតម្រូវឱ្យបង្ហាញខ្លួនចំពោះមុខតុលាការ ត្រូវបអនុញ្ញាតឱ្យស្លៀកសម្លៀកបំពាក់ស្អាតបាត និងសមរម្យផ្ទាល់ខ្លួនរបស់គេ។

---

[95] ប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ, លេខ៦១៧ ប្រក,៣១ មិនា ឆ្នាំ១៩៩៨, ប្រការ៤ ចំណុចទី៣។

**ឆ.** គ្មានអ្នកទោសណាម្នាក់ត្រូវបានគេអនុញ្ញាតឱ្យស្នាក់នៅខាងក្រៅពន្ធនាគារ ឬត្រូវបានគេអនុញ្ញាតឱ្យចេញក្រៅពន្ធនាគារនៅពេលយប់បានឡើយ លើកលែងតែមានករណីសង្គ្រោះបន្ទាន់ណាមួយតែប៉ុណ្ណោះ។

**ជ.** គ្មានអ្នកទោសណាម្នាក់អាចត្រូវបានគេផ្លាស់ប្តូរ ឬផ្ទេរពីពន្ធនាគារ ក្នុងករណីបន្ទាន់ណាមួយឡើយ លើកលែងតែមានហេតុផលមួយចំនួនដូចខាងក្រោម៖

- ពន្ធនាគារមានចំនួនអ្នកទោសច្រើនលើសលប់
- សន្តិសុខពន្ធនាគារមិនអាចធានាបាន
- គ្រោះមហន្តរាយ( រួមមានគ្រោះធម្មជាតិ ដែលបានកើតឡើងក្នុងពន្ធនាគារ)

**ឈ.** បើសិនជាគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីនាយកដ្ឋានពន្ធនាគារទេ ក្នុងការយកចេញ ឬផ្ទេរអ្នកទោសណាម្នាក់ ក្នុងករណីសង្គ្រោះបន្ទាន់ ប្រធានពន្ធនាគារមានសិទ្ធិសម្រេចបាន ប៉ុន្តែត្រូវរាយការណ៍ជាបន្ទាន់នូវមូលហេតុនោះជូនប្រធាននាយកដ្ឋានពន្ធនាគារ។[96]

#### ១.១.២.៤. សិទ្ធិ និងភារកិច្ចរបស់ទណ្ឌិត

អ្នកទោសត្រូវទទួលបានសិទ្ធិដូចខាងក្រោម៖

- សិទ្ធិត្រូវបានគេថែទាំ ក្នុងសភាពថ្លៃថ្នូរ និងមានតម្លៃជាមនុស្ស
- សិទ្ធិមិនត្រូវបានគេធ្វើទារុណកម្ម អំពើព្រៃផ្សៃអមនុស្សធម៌ ឬបន្ទាបបន្ថោក និង ដាក់ទណ្ឌកម្ម
- សិទ្ធិលំហែកាយយ៉ាងហោចណាស់ឱ្យបាន១ម៉ោងក្នុងមួយថ្ងៃតាមអាកាសធាតុផ្តល់ឱ្យ ក្នុងករណីគ្មានការអនុញ្ញាតឱ្យចេញទៅធ្វើការនៅខាងក្រៅ មានរយៈពេលដូចគ្នា។
- មានសិទ្ធិទទួលដឹងឮពីកំហុសរបស់ខ្លួនមុនពេលទទួលវិន័យ។
- សិទ្ធិទទួលម្ហូបអាហារ និងទឹកស្អាតគ្រប់គ្រាន់ ដើម្បីថែរក្សាសុខភាព ។
- សិទ្ធិទទួលនូវអាហារពិសេសប្រចាំថ្ងៃ នៅពេលណាប្រធានពន្ធនាគារយល់ឃើញថាចំណីអាហារនេះត្រូវការចាំបាច់តាមវេជ្ជបញ្ជា ឬតាមជំនឿសាសនារបស់ពួកគេ។
- សិទ្ធិទទួលបានសម្លៀកបំពាក់ស្អាត ស្របតាមអាកាសធាតុ និងការងារឱ្យបានគ្រប់គ្រាន់ដើម្បីរក្សាសុខភាពរបស់ពួកគេ។
- សិទ្ធិទទួលការថែទាំ និងព្យាបាលចាំបាច់ផ្សេងទៀត ផ្នែកសុខភាព និងធ្មេញ។
- សិទ្ធិទទួលការថែទាំ និងព្យាបាលពិសេស បើមានជំងឺផ្នែកស្មារតី និងផ្លូវចិត្ត។
- សិទ្ធិជ្រើសរើសជំនឿសាសនា សមស្របនឹងសន្តិសុខសណ្តាប់ធ្នាប់ល្អក្នុងពន្ធនាគារ។
- សិទ្ធិចូលរួមជំនឿសាសនាជាមួយអ្នកទោសផ្សេងទៀត។

---

[96] ប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ, លេខ៦១៧ ប្រក,៣១ មិនា ឆ្នាំ១៩៩៨, ប្រការ៤ ចំណុចទី៥។

- សិទ្ធិស្នើសុំ ឬប្តឹងតវ៉ា ក្នុងការថែទាំរូបកាយតាមលក្ខណៈធម្មជាតិ។
- សិទ្ធិក្នុងការជូនដំណឹងនានា ទៅកាន់ក្រុមគ្រួសាររបស់ពួកគេភ្លាមបន្ទាប់ពីជាប់ពន្ធនាគារ ឬ ផ្លាស់ប្តូរទៅកាន់ពន្ធានាគារផ្សេងទៀត ក្នុងករណីអ្នកទោសជាជនបរទេសគឺមានសិទ្ធិជូនដំណឹងទៅកាន់ស្ថានទូតស្ថានកុងស៊ុល និងអង្គការពាក់ព័ន្ធ។
- សិទ្ធិទទួលជួបសួរសុខទុក្ខ ពីគ្រួសារ និងមិត្តភក្តិ យ៉ាងហោចណាស់១ម៉ោងក្នុង១សប្តាហ៍
- សិទ្ធិទទួលការបែងចែកចំណាត់ថ្នាក់ជាបន្ទាន់ បន្ទាប់ពីមានការកាត់ទោស ហើយត្រូវពិនិត្យសើរើឡើងវិញជាប្រចាំ។
- ការទាក់ទងតាមសំបុត្រស្នាម និងការពិគ្រោះយោបល់ជាមួយមេធាវីត្រូវធ្វើឡើងដោយគ្មានការផ្លាស់ប្តូរខ្លឹមសារ ពន្យាពេល និងរក្សាការសម្ងាត់។ ការទាក់ទង ពិគ្រោះយោបល់នេះត្រូវស្ថិតក្នុងលក្ខខណ្ឌសមហេតុផល ដើម្បីធានាសន្តិសុខ និងសណ្តាប់ធ្នាប់ល្អក្នុងពន្ធនាគារ។
- សិទ្ធិផ្ញើ និងទទួលលិខិតពីគ្រួសារ និងមិត្តភក្តិ។
- សិទ្ធិចូលរួមក្នុងកម្មវិធីវប្បធម៌ អប់រំ រៀនសូត្រ កំសាន្ត និងវិជ្ជាជីវៈក្នុងពន្ធនាគារ ហើយមានសិទ្ធិប្រើប្រាស់សម្ភារៈគ្រប់គ្រាន់ និងសមរម្យ ដើម្បីអនុវត្តកម្មវិធីសិក្សាឱ្យមានប្រសិទ្ធភាព។[97]

### ១.១.៣. ការធ្វើអធិការកិច្ចពន្ធនាគារ

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ប្រធានសភាស៊ើបសួរ និងចៅក្រមស៊ើបសួរត្រូវធ្វើអធិការកិច្ចលើពន្ធនាគារជាប្រចាំ។[98] យន្តការបង្ការថ្នាក់ជាតិត្រូវបានអនុញ្ញាតឱ្យធ្វើទស្សនកិច្ចតាមពន្ធនាគារនានាគ្រប់ពេលវេលា និងធ្វើសម្ភាសន៍ជាសម្ងាត់ជាមួយជនជាប់ឃុំ ដើម្បីត្រួតពិនិត្យមើលលក្ខខណ្ឌនៃការឃុំខ្លួន និងការប្រព្រឹត្តចំពោះជនជាប់ឃុំ ផ្តល់អនុសាសន៍កែលម្អ សំដៅបង្ការទារុណកម្ម អំពើឃោរឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោក។

ការធ្វើអធិការកិច្ចនេះគឺផ្តោតសំខាន់ទៅលើ សុខភាព ការរស់នៅ វត្តមាន អវត្តមានរបស់ជនជាប់ឃុំ ជាពិសេសគឺចំនួនជនជាប់ទោសតែម្តងជៀសវាងមានការលួចដោះលែងជនជាប់ទោសនោះដោយគ្មានការអនុញ្ញាត។ នៅពេលពិនិត្យចំនួនជនជាប់ទោសព្រះរាជអាជ្ញាត្រូវធ្វើការផ្ទៀងផ្ទាត់តាមបញ្ជីឈ្មោះ ដែលប្រធានពន្ធនាគារផ្តល់ឱ្យដោយហៅឈ្មោះម្តងម្នាក់រហូតដល់អស់។

---

[97] ប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ, លេខ៦១៧ ប្រក,៣១ មិនា ឆ្នាំ១៩៩៨, ប្រការ៤ ចំណុចទី៧។

[98] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ឆ្នាំ២០០៧, មាត្រា៥០៩។

### ១.២. ការអនុវត្តទោសពិន័យជាប្រាក់

#### ១.២.១. ការប្រមូលប្រាក់ពិន័យ និងពន្ធនីតិវិធី

ប្រសិនបើទណ្ឌិតមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធីទេ អង្គភាពរតនាគារជូនដំណឹងដល់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញាកំណត់រយៈពេលចុងក្រោយដល់ទណ្ឌិត ដើម្បីបង់ប្រាក់នោះ ហើយឱ្យដំណឹងថាប្រសិនបើមិនបង់ទេនោះសាមីខ្លួនអាចត្រូវបង្ខំដល់រូបកាយ។ រយៈពេលនេះមិនអាចតិចជាង១០ (ដប់) ថ្ងៃទេ។ ការឱ្យដំណឹងត្រូវធ្វើ៖

- ដោយផ្ទាល់មាត់
- តាមផ្លូវរដ្ឋបាល
- តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។

ត្រូវតែមានធ្វើកំណត់ហេតុស្តីពីការឱ្យដំណឹងនេះ។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយទណ្ឌិត។ ប្រសិនបើទណ្ឌិតមិនចេះចុះហត្ថលេខាទេ ទណ្ឌិតត្រូវផ្តិតម្រាមដៃ។[99]

#### ១.២.២. ការបង្ខំដល់រូបកាយ

ការបង្ខំរូបកាយគឺជាការអនុវត្តដោយពេញលក្ខណៈច្បាប់ ទៅលើបុគ្គលដែលត្រូវផ្តន្ទាទោសដោយតុលាការព្រហ្មទណ្ឌ ដែលមិនបង់ ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី ប្រាក់សំណង និងជម្ងឺចិត្តដែលត្រូវបង់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី។ នៅពេលផុតរយៈពេលកំណត់ ប្រសិនបើទណ្ឌិតមិនបានបង់ប្រាក់នោះទេព្រះរាជអាជ្ញាចេញបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួនទណ្ឌិតនោះ ដោយមានចុះហត្ថលេខាដោយព្រះរាជអាជ្ញាផ្ទាល់ និងមានបោះត្រាផងដែរ។ ព្រះរាជអាជ្ញាអាចបង្អង់សេចក្តីសម្រេចនេះបានដោយមូលហេតុមនុស្សធម៌ជាអាទិ៍ ដូចជាស្ថានភាពនៃសុខភាពរបស់ទណ្ឌិត។ ព្រះរាជអាជ្ញាអាចសុំឱ្យកម្លាំងសាធារណៈ និងឃុំខ្លួនទណ្ឌិត។ ក្នុងនោះថិរវេលានៃការបង្ខំរូបកាយត្រូវកំណត់ដូចខាងក្រោម៖

- ១០(ដប់) ថ្ងៃ កាលណាទឹកប្រាក់ដែលមិនបង់នោះមានចំនួនមិនលើសពី២៥០.០០០ (ពីរសែនប្រាំម៉ឺន) រៀល។
- ២០(ម្ភៃ) ថ្ងៃ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២៥០.០០១(ពីរសែនប្រាំម៉ឺនមួយ)រៀល ដល់ ៥០០.០០០ (ប្រាំសែន)រៀល។
- ១(មួយ) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ៥០០.០០១(ប្រាំសែនមួយ)រៀល ដល់ ១.០០០.០០០ (មួយលាន) រៀល។
- ២(ពីរ) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ១.០០០.០០១(មួយលានមួយ) រៀល ដល់ ២.៥០០.០០០ (ពីរលានប្រាំសែន) រៀល។

---

[99] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ឆ្នាំ២០០៧, មាត្រា៥២៥។

- ៣(បី) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២.៥០០.០០១ (ពីរលានប្រាំសែនមួយ)រៀល ដល់ ៥.០០០.០០០ (ប្រាំលាន)រៀល។
- ៦(ប្រាំមួយ) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ៥.០០០.០០១ (ប្រាំលានមួយ)រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល។
- ១(មួយ) ឆ្នាំ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ១០.០០០.០០១ (ដប់លានមួយ)រៀល ដល់ ២០.៥០០.០០០ (ម្ភៃលានប្រាំសែន)រៀល។
- ១៨(ដប់ប្រាំបី) ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២០.៥០០.០០១ (ម្ភៃលានប្រាំសែនមួយ) ដល់ ៥០.០០០.០០០(ហាសិបលាន)រៀល។
- ២(ពីរ) ឆ្នាំ ប្រសិនបើទឹកប្រាក់នេះមានចំនួនលើសពី ៥០.០០០.០០០(ហាសិបលាន)រៀល។

កាលណាការបង្ខំដល់រូបកាយធានាការប្រមូលឥណទេយ្យច្រើននោះ ចិរវេលានៃការបង្ខំនេះ ត្រូវកំណត់ដោយគិតគូរតាមចំនួនសរុបនៃទណ្ឌកម្ម។[100]

ការរួចផុតពីការបង្ខំរូបកាយ មិនអាចធ្វើទៅលើទណ្ឌិតជាអនីតិជននៅពេលប្រព្រឹត្តបទល្មើសទៅលើស្ត្រីដែលមានអាយុចាប់ពី៦៥ឆ្នាំ ឡើងទៅ និងទៅលើបុរសអាយុចាប់ពី៧០ឆ្នាំឡើងទៅបានឡើយ។ ការបង្ខំដល់រូបកាយមិនអាចធ្វើបានព្រមជាមួយគ្នាទៅលើប្តី និងប្រពន្ធបានទេ ទោះបីជាការបង្ខំនេះធ្វើឡើង ដើម្បីប្រមូលធនទណ្ឌផ្សេងគ្នាក៏ដោយ។[101]

## កថាខណ្ឌទី២៖ ការអនុវត្តទោសបន្ថែម និងទោសជំនួស

នៅក្នុងពេលបច្ចុប្បន្នពុំមានបទដ្ឋានគតិយុត្តណាមួយដែលកំណត់ឱ្យបានជាក់លាក់ទាក់ទងនឹងរបៀបរបបក៏ដូចជានីតិវិធីនៅក្នុងការអនុវត្តទោសបន្ថែមទេ ដូចនេះការអនុវត្តទោសបន្ថែមគឺត្រូវពឹងផ្អែកទាំងស្រុងលើសេចក្តីសម្រេចរបស់យុត្តាធិការជំនុំជម្រះ ថាតើចេញសេចក្តីសម្រេចដែលសម្រេចអំពីទោសនេះយ៉ាងដូចម្តេច ដូច្នេះយុត្តាធិការជំនុំជម្រះសម្រេចអំពីទោសបន្ថែម ឬទោសជំនួសបែបណានោះព្រះរាជអាជ្ញាធ្វើការអនុវត្តទៅតាមខ្លឹមសារនៃសេចក្តីសម្រេចនោះ។

### ២.១. ការអនុវត្តទោសបន្ថែម

ព្រះរាជអាជ្ញាធ្វើការអនុវត្តទោសបន្ថែមតាមរយៈសាលក្រមដែលសម្រេចដោយយុត្តាធិការជំនុំជម្រះ មានន័យថានៅពេលដែលតុលាការចេញសាលក្រមដែលសម្រេចអំពីទោសបន្ថែម ដូចនេះព្រះរាជអាជ្ញាធ្វើការអនុវត្តនូវទោសបន្ថែមដោយផ្អែកលើខ្លឹមសារនៃសាលក្រម។ ទោសបន្ថែម សំដៅលើទោសដែលត្រូវបន្ថែមលើមូលទោស។ ទោសបន្ថែមអាចនឹងប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ

[100] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ឆ្នាំ២០០៧, មាត្រា៥៣០។

[101] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤,១០ សីហា ឆ្នាំ២០០៧, មាត្រា៥៣១។

ដែលត្រូវចោទប្រកាន់។ ទោសបន្ថែមអាចប្រកាសក៏បាន មិនប្រកាសក៏បាន ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់។[102]

### ២.១.១. ប្រភេទនៃទោសបន្ថែម

ទោសបន្ថែមរួមមាន៖

- ការដកសិទ្ធិខ្លះជាពលរដ្ឋ
- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ
- ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ
- ការព្យួរលិខិតបើកបរ
- ការហាមឃាត់ចំពោះការស្នាក់នៅ
- ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា
- ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិតដែលជាបរទេស
- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់នៅក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស
- ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស
- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស
- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត
- ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត
- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ
- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ
- ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស
- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថានដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន។
- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន

[102] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា៥៤។

- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍។[103]

**២.១.២. ការអនុវត្តទោសបន្ថែម**

ព្រះរាជអាជ្ញាធ្វើការអនុវត្តទោសបន្ថែមតាមខ្លឹមសារនៃសាលក្រមដែលប្រកាសដោយតុលាការ។ ការប្រកាស ទោសបន្ថែមធ្វើបានតាម២របៀបគឺៈ

- ការប្រកាសទោសបន្ថែមលើមូលទោស កាលណាបទល្មើសមួយត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬ ច្រើនទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបទបញ្ញត្តិនៃមាត្រា១០០(ការជំនួស មូលទោសដោយទោសបន្ថែម) នៃក្រមនេះចេញ។[104]
- ការជំនួសមូលទោសដោយទោសបន្ថែម តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬ ច្រើននៅក្នុងករណីណាមួយដូចខាងក្រោមៈ

- កាលណាជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់
- កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង៣(បី) ឆ្នាំ។[105]

កាលណាតុលាការសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬ ច្រើនតុលាការមិនអាចប្រកាស ទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ។

ទោសបន្ថែមទាំងឡាយ ដែលមានចែងនៅក្នុងចំណុច ១, ២, ៣, ៤, ៥, ៦ និង៧ នៃមាត្រា៥៣ (ប្រភេទនៃ ទោសបន្ថែម)នៃក្រមនេះ ត្រូវអនុវត្តនៅពេលផុតទោសពន្ធនាគារលើកលែងតែមានសេចក្តីសម្រេចផ្ទុយរបស់តុលាការ។

**២.១.៣. ការកែប្រែ ឬ ការលុបចោលទោសបន្ថែមខ្លះៗ**

តុលាការអាចបង្គាប់ឱ្យរៀបចំកែប្រែ ឬ លុបចោលទោសមួយ ឬច្រើនប្រសិនបើៈ

- ភាពច្របូកច្របល់ដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបានបញ្ឈប់
- ព្យសនកម្មត្រូវបានជួសជុល
- សេចក្តីសម្រេចរៀបចំកែប្រែ ឬលុបចោលមានលក្ខណៈអនុគ្រោះឱ្យធ្វើការបញ្ចូលជនល្មើសទៅរស់នៅ ក្នុងសង្គមវិញ។ តុលាការទទួលពាក្យបណ្តឹងពីអយ្យការតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ឬតាមពាក្យ ប្តឹងរបស់ទណ្ឌិត។ តុលាការសម្រេចក្នុងពេលសវនាការសាធារណៈក្រោយពីបានស្តាប់យោបល់របស់ តំណាងអយ្យការ ទណ្ឌិត និងជាយថាហេតុមេធាវីរបស់ជននោះ។[106]

---

[103] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា៥៤។

[104] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា៩៩។

[105] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា១០០។

[106] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា១៥២។

### ២.២. ការអនុវត្តទោសជំនួស

ទោសជំនួស គឺជាទោសដែលតុលាការយកមកជំនួសឱ្យមូលទោសក្នុងករណីនេះតុលាការមិនអាចប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ។ ទោសជំនួសមាន២ប្រភេទគឺ៖

#### ២.២.១. ការអនុវត្តការងារសហគមន៍

បែបបទនៃការអនុវត្តទោសការងារសហគមន៍ ត្រូវកំណត់ដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាចង្អុលឈ្មោះនីតិបុគ្គលដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ។ ទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា។[107]ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០(សាមសិប)ម៉ោង ទៅ២០០(ពីររយ) ម៉ោង នូវការងារគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀតដល់សមាគម ឬ ដល់អង្គការមិនមែនរដ្ឋាភិបាល។

កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាតិចជាង ឬ ស្មើនឹង ៣(បី) ឆ្នាំតុលាការអាចប្រកាសទោសការងារសហគមន៍។[108]

❖ វិធានដោយឡែកសម្រាប់ការប្រកាសទោសការងារសហគមន៍

ទោសការងារសហគមន៍អាចនឹងប្រកាសបានលុះត្រាតែ ជនជាប់ចោទមានវត្តមាននៅពេលសវនាការហើយយល់ព្រមធ្វើការងារនេះ។ តុលាការនៅមុនពេលប្រកាសសាលក្រម ឬសាលដីកា ត្រូវប្រាប់ជនជាប់ចោទថាសាមីខ្លួនមានសិទ្ធិប្រកែក មិនព្រមធ្វើការងារនេះ។ ចម្លើយរបស់ជនជាប់ចោទ ត្រូវតែមានចុះនៅក្នុងសាលក្រម ឬសាលដីកា។[109]

❖ ចិរវេលា និងអំឡុងពេលនៃការងារសហគមន៍

តុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវកំណត់អំពីចិរវេលានៃការងារ និងរយៈពេលដែលត្រូវបំពេញ។ រយៈពេលនេះមិនអាចលើសពី១(មួយ) ឆ្នាំទេ។[110]

❖ បែបបទនៃការអនុវត្តទោសការងារសហគមន៍

បែបបទនៃការអនុវត្តទោសការងារសហគមន៍ ត្រូវកំណត់ដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាចង្អុលប្រាប់ឈ្មោះនីតិបុគ្គលដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ។ ទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា។[111]

---

[107] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា១០៣។

[108] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា៧២។

[109] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា១០១។

[110] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា១០២។

[111] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា១០៣។

### ២.២.២. ការអនុវត្តការស្តីបន្ទោស

ការស្តីបន្ទោសអនុវត្តជំនួសឱ្យមូលទោស។ តុលាការដែលប្រកាសការស្តីបន្ទោស មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ។[112]

កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬស្មើនឹង៣(បី) ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌទាំង៣ដូចខាងក្រោម៖

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់
- ការខូចខាតត្រូវបានជួសជុលរួចហើយ និង
- ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ។[113]

បន្ទាប់ពីទណ្ឌិតអនុវត្តទោសចប់សព្វគ្រប់រួចហើយ ព្រះរាជអាជ្ញាត្រូវចេញដីកាបង្គាប់ឱ្យដោះលែងជននោះជាបន្ទាន់ ប្រសិនបើជននេះមិនត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ។

[112] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា៩៨ កថាខណ្ឌទី២។

[113] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ឆ្នាំ២០០៩, មាត្រា១៥២ កថាខណ្ឌទី១។

# សេចក្តីសន្និដ្ឋាន

ជារួមមកព្រះរាជអាជ្ញាដែលជាតំណាងឲ្យអង្គការអយ្យការ ក្រៅពីមានតួនាទីជាអ្នកអនុវត្តនូវបណ្តឹងអាជ្ញាដើម្បីធានានូវផលប្រយោជន៍សាធារណៈ ព្រះរាជអាជ្ញាក៏មានតួនាទីនៅក្នុងការអនុវត្តនូវសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌផងដែរ ដែលមានកំណត់នៅក្នុងមាត្រា២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ការអនុវត្តសាលក្រមព្រហ្មទណ្ឌ គឺសំដៅទៅដល់ការអនុវត្តនូវខ្លឹមសារនៃសាលក្រមព្រហ្មទណ្ឌដែលបានចូលជាស្ថាពរ យោងទៅលើមាត្រា៤៩៧ នៃក្រមនីតិព្រហ្មទណ្ឌហើយខ្លឹមសារនៃសាលក្រមព្រហ្មទណ្ឌគឺជា ទោសព្រហ្មទណ្ឌដែលជាទណ្ឌកម្មព្រហ្មទណ្ឌចំពោះបទល្មើសដែលចារីបានប្រព្រឹត្ត។ យោងទៅលើក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ទោសព្រហ្មទណ្ឌត្រូវបានបែងចែកជាបីប្រភេទគឺ មូលទោស ទោសបន្ថែម និងទោសជំនួស។ ដើម្បីធានាដល់ការអនុវត្តទោស គឺចាំបាច់ត្រូវមានការចូលរួមពីស្ថាប័នដែលពាក់ព័ន្ធមួយចំនួនដូចជា អគ្គនាយកដ្ឋានពន្ធនាគារ មន្ត្រីពន្ធនាគារចំពោះទោសពន្ធនាគារ ភ្នាក់ងាររតនាគារចំពោះទោសពិន័យជាប្រាក់ជាអាទិ៍។ មុនពេលអនុវត្តសាលក្រមព្រហ្មទណ្ឌ នៅពេលដែលសាលក្រមត្រូវបានប្រកាសដោយតុលាការ សាលក្រមនេះគឺត្រូវជូនដំណឹងទៅដល់ភាគីដែលពាក់ព័ន្ធចំពោះសាលក្រមដែលច្បាប់តម្រូវអោយមានការជូនដំណឹង។ នៅកំឡុងពេលនៃការអនុវត្តសាលក្រមព្រហ្មទណ្ឌចំពោះទោសពន្ធនាគារ ព្រះរាជអាជ្ញា ក៏មានតួនាទីនៅក្នុងការធ្វើអធិការកិច្ចពន្ធនាគារផងដែរដូចមានចែងនៅក្នុងមាត្រា៥០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ការធ្វើអធិការកិច្ចពន្ធនាគារនេះគឺដើម្បីពិនិត្យអំពីចំនួនរបស់ទណ្ឌិត ពិនិត្យអំពីសុខភាព និងស្ថានភាពការរស់នៅរបស់ទណ្ឌិត ជាអាទិ៍។ ចំពោះការនុវត្តទោសពិន័យជាប្រាក់ និងពន្ធនីតិវិធី គឺត្រូវធ្វើឡើងដោយភ្នាក់ងារ រតនាគារ នៅក្រោមឱវាទរបស់អយ្យការ។ នៅក្នុងករណីដែលទណ្ឌិតមិនបានបង់ប្រាក់ពិន័យ ឬពន្ធនីតិវិធី ឬបង់មិនគ្រប់ចំនួន ឬមិនបានបង់ប្រាក់សំណងជម្ងឺចិត្តដែលត្រូវបង់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី គឺត្រូវអនុវត្តវិធានស្តីពីការបង្ខំដល់រូបកាយ ដែលមានចែងនៅក្នុងមាត្រា៥២៣ ដល់មាត្រា៥៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះការអនុវត្តនៅទោសបន្ថែមនិងទោសជំនួសគឺត្រូវអនុវត្តតាមវិធានដែលមានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អយ្យការ។

# អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ និងជ្រើសយកប្រធានបទស្តីពី**តួនាទីព្រះរាជអាជ្ញាក្នុងការអនុវត្តសាលក្រមព្រហ្មទណ្ឌ**ដើម្បីជាការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្ររួចមក។ យើងខ្ញុំមានអនុសាសន៍និងសំណូមពរនូវបញ្ហាខ្លះៗទាក់ទងនឹងប្រធានបទនេះផងដែរ។

## អនុសាសន៍មួយចំនួនទាក់ទងនឹងប្រធានបទ

**១. មន្ត្រីនគរបាលយុត្តិធម៌**

- ត្រូវស្វែងរកភស្តុតាងឱ្យបានល្អិតល្អន់
- ត្រូវគោរពតាមនីតិវិធីដែលចែងក្នុងច្បាប់ឱ្យបានខ្ជាប់ខ្ជួន
- ចៀសវាងការបង្ខិតបង្ខំឱ្យសាក្សីឆ្លើយដោយការប្រើហិង្សា
- មិនត្រូវបំផ្លើសអង្គហេតុ
- ការស៊ើបអង្កេតត្រូវធ្វើឱ្យបានឆាប់រហ័ស។

**២. ចៅក្រមអយ្យការ**

- ត្រូវអនុវត្តតួនាទីរបស់ខ្លួនដោយឯករាជ្យ
- ត្រូវស្រាវជ្រាវនូវអង្គហេតុឱ្យបានគ្រប់ជ្រុងជ្រោយ មិនត្រូវជឿជាក់ចំពោះកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ទាំងស្រុងទេ។
- គោរពតាមនីតិវិធីដែលច្បាប់ចែងទុកឱ្យបានម៉ឺងម៉ាត់ និងអស់ពីសតិសម្បជញ្ញៈរបស់ខ្លួន
- ការចោទប្រកាន់ត្រូវតែមានសុក្រឹត្យភាព និងស្មើភាពគ្នាចំពោះគ្រប់បុគ្គល
- មិនត្រូវខ្លាចអំណាចរបស់បុគ្គលមានអំណាចណាមួយឡើយត្រូវចោទប្រកាន់តាមអ្វីដែលខ្លួនយល់ថាត្រឹមត្រូវតាមច្បាប់។

**៣. ចៅក្រមស៊ើបសួរ**

- ការស៊ើបសួរត្រូវស៊ើបស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក
- ត្រូវគោរពនីតិវិធីដែលច្បាប់ចែងចៀសវាងគេប្តឹងមោឃភាពនីតិវិធី
- ការស៊ើបសួរត្រូវតែឆាប់រហ័ស និងគ្រប់ជ្រុងជ្រោយ។

**៤.ចៅក្រមជំនុំជម្រះ**

- ត្រូវកាត់សេចក្តីប្រកបដោយយុត្តិធម៌ទាំងជនល្មើស និងជនរងគ្រោះ
- ការជំនុំជម្រះត្រូវតែយុត្តិធម៌ និងឆាប់រហ័ស
- ត្រូវកំណត់កាលបរិច្ឆេទជំនុំជម្រះឱ្យបានច្បាស់លាស់ចៀសវាងមានការភ័ន្តច្រឡំ
- ត្រូវពិចារណា និងថ្លឹងថ្លែងអំពីអំពើ និងទំហំព្យសនកម្មដែលបានកើតឡើង

- វៀរចាកនូវអគតិទាំង៤ ក្នុងពេលបំពេញមុខងារ
- ក្នុងនាមជាអ្នកផ្តល់នូវភាពយុត្តិធម៌ ការសម្រេចសេចក្តីត្រូវឈរលើឧត្តមគតិរបស់ខ្លួន។

**ក្រោយពីអនុសាសន៍មួយចំនួនខាងលើយើងខ្ញុំសូមសំណូមពរដូចខាងក្រោម៖**

- សូមឱ្យអ្នកអនុវត្តច្បាប់ទាំងអស់អនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់
- មានឆន្ទៈជារួមគឺយុត្តិធម៌ជាធំ
- ការពារ និងផ្តល់យុត្តិធម៌ជូនបុគ្គលស្លូតត្រង់
- ដាក់ទណ្ឌកម្មចំពោះបុគ្គលដែលល្មើសច្បាប់ឱ្យសមនឹងទង្វើដែលគេបានប្រព្រឹត្ត
- លុបបំបាត់ឱ្យបាននូវអំពើពុករលួយ និងភាពអយុត្តិធម៌នៅក្នុងសង្គម
- គោរពច្បាប់ឱ្យបានតឹងរ៉ឹង ផ្តល់ទំនុកចិត្តដល់ប្រជាពលរដ្ឋដើម្បីឱ្យពួកគាត់មានជំនឿលើប្រព័ន្ធយុត្តិធម៌។

# ឯកសារយោង

## ក.លិខិតបទដ្ឋានគតិយុត្តៈ

១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា  ប្រកាសឱ្យប្រើកាលពីថ្ងៃទី២១ កញ្ញា ឆ្នាំ១៩៩៣។

២.ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើកាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

៣.ក្រមព្រហ្មទណ្ឌ ប្រកាសឱ្យប្រើកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

៤.ច្បាប់ស្តីពីការរៀបចំអង្គតុលាការ ប្រកាសឱ្យប្រើកាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

៥.ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ប្រកាសឱ្យប្រើកាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

៦.ច្បាប់ស្តីពីពន្ធនាគារ ប្រកាសឱ្យប្រើកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។

៧.ប្រកាសស្តីពីពន្ធនាគារ អនុវត្តថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៣។

៨.សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ថ្ងៃទី១០ ខែធ្នូ  ឆ្នាំ១៩៤៥។

## ខ.ឯកសារជំនួយស្មារតីៈ


១. រុន ពណ្ណារិទ្ធិ និងចាំង ស៊ីណាត, រៀបរៀង. ២០១៥-២០១៦. នីតិវិធីព្រហ្មទណ្ឌ។

២. រុន ពណ្ណារិទ្ធិ និងចាំង ស៊ីណាត, រៀបរៀង. ២០១២. នីតិព្រហ្មទណ្ឌទូទៅ។

៣. សុខ រឿន, រៀបរៀង. ២០១០-២០១១. មេរៀនស្តីពីនីតិវិធីព្រហ្មទណ្ឌ។

៤. អាត ច័ន្ទដារា និងសុង ប៊ុនយៀង, រៀបរៀង. ២០១៤. គោលការណ៍ទូទៅនៃនីតិក្រមទាំងបួន។

៥. គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា, អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបីស្តីពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស នាទីក្រុង ហាវ៉ាណា ប្រទេសគុយបា, ២៧ សីហា ដល់ថ្ងៃទី ៧ កញ្ញា ឆ្នាំ១៩៩០។

៦. របាយការណ៍កម្មសិក្សា **ការតម្កល់រឿងទុកឥតចាត់ការ** របស់លោក **អ្នក លឹមអេង** ជាសិស្សក្រឡាបញ្ជីជំនាន់ទី៥ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

## បញ្ជីឧបសម្ព័ន្ធ

១.ដីកាសន្និដ្ឋានចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់
២.ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ
៣.ដីកាសម្រេចដាក់រឿងទៅជំនុំជម្រះ
៤.ដីកាបញ្ជូន
៥.ដីកាសម្រេចយកជនជាប់ចោទមកជំនុំជម្រះ
៦.ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់
៧.ដីកាកោះហៅជនជាប់ចោទឱ្យចូលរួមសវនាការ
៨.ដីកាបង្គាប់ឱ្យនាំជនជាប់ចោទទៅតុលាការ
៩.ដីកាកោះហៅសាក្សីឱ្យចូលរួមសវនាការ
១០.ដីកាកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីឱ្យចូលរួមសវនាការ
១១.លិខិតអញ្ជើញអ្នកជំនាញឱ្យចូលរួមសវនាការ
១២.ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះ
១៣.ដីកាអញ្ជើញឱ្យចូលសវនាការ (មន្ត្រីនគរបាលយុត្តិធម៌)
១៤.ដីកាកោះហៅជនរងគ្រោះឱ្យចូលរួមសវនាការ
១៥.កំណត់ហេតុស្ដីពីការធ្វើសម្បថ
១៦.បញ្ជីវត្តមានពេលសវនាការ
១៧.កំណត់ហេតុសវនាការ
១៨.លិខិតជូនដំណឹងពីសាលក្រមកំបាំងមុខ
១៩.លិខិតឱ្យដំណឹងពីការអនុវត្តប្រាក់ពិន័យ
២០.ដីកាបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួន
២១.ដីកាបង្គាប់ឱ្យដោះលែង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់

លេខ៖ ...២៨១...ក.ស./១៧

# ដីកាសន្និដ្ឋានចោទប្រកាន់
# ជូនរឿងទៅជំនុំជម្រះផ្ទាល់[១]

**យើង ឆាយ ហុង តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់**

- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ៖៤០០ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦។
- បានឃើញមាត្រា ៤៦, ៤៩, ២៤១, ៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

**ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ឃើញថា[២]**

| | |
|---|---|
| នាមត្រកូល | ៖ [redacted] នាមខ្លួន ៖ [redacted] ភេទស្រី |
| អាយុ | ៖ ៥៥ឆ្នាំ |
| ទីកន្លែងកំណើត | ៖ ភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល។ |
| លំនៅបច្ចុប្បន្ន | ៖ ភូមិអូរថ្កូវ ឃុំរលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ។ |
| មុខរបរ | ៖ ធ្វើចំការ |
| សញ្ជាតិ | ៖ ខ្មែរ |
| នៅលីវ | ឬ ☑រៀបការ ប្តីឈ្មោ[redacted]ានកូនចំនួន ០១នាក់។ |
| ឪពុកឈ្មោះ | ៖ [redacted] "ស្លាប់" ម្តាយឈ្មោះ ៖ [redacted] "ស្លាប់" ។ |
| អនីតិជន☐ | ឬ ជានីតិជន☑ ទោសពីមុន ៖ គ្មាន ។ |

[១] ដីកានេះ ប្រើសំរាប់ព្រះរាជអាជ្ញា ធ្វើដីកាសន្និដ្ឋានចោទប្រកាន់ជូនរឿងទៅជំនុំជម្រះផ្ទាល់ ចំពោះបទល្មើសជាក់ស្តែង ឬមិនជាក់ស្តែង ដែលមានទណ្ឌកម្មកំណត់ក្នុងច្បាប់មិនលើសពីមួយឆ្នាំ ហើយដែលមានភស្តុតាង និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់។

[២] រៀបរាប់អំពីដំណើររឿង ឬអង្គហេតុសង្ខេបតាមសំណុំរឿង ក្រោយពីបញ្ចប់ការស៊ើបអង្កេត។
សំគាល់ ត្រូវធ្វើការកោះហៅភាគីឱ្យចូលទៅបង្ហាញខ្លួននៅមុខតុលាការនាពេលសវនាការ (មាត្រា៤៥៧)

**យល់ឃើញថា**[៤] ៖

-អង្គហេតុបទល្មើសខាងលើ កើតឡើងនៅ ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អយ្យការ និងសាលាដំបូងខេត្តពោធិ៍សាត់ តាមមាត្រា ៣៩ និងមាត្រា ២៩០ នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ**។

-គិតចាប់ពីពេលដែលបទល្មើសកើតឡើងកាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ មកដល់ពេលនេះ អាជ្ញាយុកាលនៃបទល្មើសមិនទាន់ផុតរលត់នៅឡើយទេ ដូច្នេះអយ្យការ និងសាលាដំបូងខេត្តពោធិ៍សាត់ នៅតែមានសមត្ថកិច្ចចាត់ការលើសំណុំរឿងនេះ យោងតាមមាត្រា ១០ និងមាត្រា ១១ នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ**។

-ផ្អែកតាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ប្រាប់ថានៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង១០ព្រឹក ដើមបណ្តឹងបានជិះម៉ូតូជាមួយឈ្មោះ [redacted] និងឈ្មោះ [redacted] ទៅមើលដីស្ថិតនៅក្នុងភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ពេលទៅដល់ទីតាំងដី ស្រាប់តែមានជនជាប់ចោទឈ្មោះ [redacted] បានដើរមកចង្អុលផ្អែករបស់ដើមបណ្តឹង ហើយស្រែកជេរថា៖ "ដីជីដូនជី តាអ្អែងនៅទីនេះ កន្ទុយម៉ែអ្អែងដីនេះជាដីម៉ែអ្អែងអី ដីនេះជាដីអញទេ អាចុយម្រាយគ្មានដីនៅចំនុចស្រែខ្នង ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ទីនោះទេ" ហើយបានចង្អុលមុខដើមបណ្តឹង ហើយជេរផង ជេរពាក្យដដែលៗ ហើយខ្លាំងៗ។ ចម្លើយខាងលើនេះគឺមានភាពស៊ីសង្វាក់ជាមួយចម្លើយរបស់សាក្សីឈ្មោះ [redacted] ភេទប្រុស, ឈ្មោះ [redacted] ភេទស្រី, ឈ្មោះ [redacted] ភេទស្រី, ឈ្មោះ [redacted] ភេទប្រុស បានលឺជនជាប់ចោទស្រែកជេរទៅលើដើមបណ្តឹង ដែលអាចបញ្ជាក់បានថាជនជាប់ចោទគឺពិតជាបានធ្វើសកម្មភាពស្រែកជេរទៅដើមបណ្តឹងប្រាកដមែន។

-ជនជាប់ចោទឈ្មោះ [redacted] ជានីតិជន មានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ហើយមានចេតនាពិតប្រាកដក្នុងការប្រព្រឹត្តអំពើខាងលើ ។

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ប៉ះពាល់ដល់បុគ្គលភាពរបស់អ្នកដទៃ ជាពិសេសច្បាប់បញ្ញត្តិអំពើនេះ ជា**បទជេរប្រមាថជាសាធារណៈ** ដែលចែងឲ្យផ្តន្ទាទោសតាមមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌ។

-មានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់លើឈ្មោះ [redacted] ភេទស្រី អាយុ៥៥ឆ្នាំ ពី**បទ ជេរប្រមាថជាសាធារណៈ** ប្រព្រឹត្តនៅ ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌ។

---

[៤] សន្និដ្ឋានវាយតម្លៃ ពីអំពើរបស់ជនត្រូវចោទ ទៅលើធាតុផ្សំនៃបទល្មើស សំរាប់បញ្ជាក់ថា មានឬគ្មានពិរុទ្ធភាពគ្រប់គ្រាន់ ឬស្លាប់ ឬគេចខ្លួនបាត់ មានឬគ្មានសាវជាតិគ្រប់គ្រាន់។

**យល់ឃើញថា**[៤]**៖**

-អង្គហេតុបទល្មើសខាងលើ កើតឡើងនៅ ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អយ្យការ និងសាលាដំបូងខេត្តពោធិ៍សាត់ តាមមាត្រា ៣៩ និងមាត្រា ២៩០ នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ**។

-គិតចាប់ពីពេលដែលបទល្មើសកើតឡើងកាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ មកដល់ពេលនេះ អាជ្ញាយុកាលនៃបទល្មើសមិនទាន់ផុតរលត់នៅឡើយទេ ដូច្នេះអយ្យការ និងសាលាដំបូងខេត្តពោធិ៍សាត់ នៅតែមានសមត្ថកិច្ចចាត់ការលើសំណុំរឿងនេះ យោងតាមមាត្រា ១០ និងមាត្រា ១១ នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ**។

-ផ្អែកតាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី បានបញ្ជាក់ប្រាប់ថានៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង១០ព្រឹក ដើមបណ្ដឹងបានជិះម៉ូតូជាមួយឈ្មោះ [redacted] និងឈ្មោះ [redacted] ទៅមើលដីស្ថិតនៅក្នុងភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ពេលទៅដល់ទីតាំងដី ស្រាប់តែមានជនជាប់ចោទឈ្មោះ [redacted] បានដើរមកចង្អុលភ្នែករបស់ដើមបណ្ដឹង ហើយស្រែកជេរថា៖ "ដីជីដូនជី តាអ្អែងនៅទីនេះ កន្ទួយម៉ែអ្អែងដីនេះជាដីម៉ែអ្អែងអី ដីនេះជាដីអញទេ អាចុយម្រាយគ្មានដីនៅចំនុចស្រែខ្ទង ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ទីនោះទេ" ហើយបានចង្អុលមុខដើមបណ្ដឹង ហើយជេរផង ជេរពាក្យដដែលៗ ហើយខ្លាំងៗ។ ចម្លើយខាងលើនេះគឺមានភាពស៊ីសង្វាក់ជាមួយចម្លើយរបស់សាក្សីឈ្មោះ [redacted] ភេទប្រុស, ឈ្មោះ [redacted] ភេទស្រី, ឈ្មោះ [redacted] ភេទស្រី, ឈ្មោះ [redacted] ភេទប្រុស បានលឺជនជាប់ចោទស្រែកជេរទៅលើដើមបណ្ដឹង ដែលអាចបញ្ជាក់បានថាជនជាប់ចោទគឺពិតជាបានធ្វើសកម្មភាពស្រែកជេរទៅដើមបណ្ដឹងប្រាកដមែន។

-ជនជាប់ចោទឈ្មោះ [redacted] ជានីតិជន មានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ហើយមានចេតនាពិតប្រាកដក្នុងការប្រព្រឹត្តអំពើខាងលើ ។

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្ដាប់ធ្នាប់ របៀបរៀបរយសង្គម ប៉ះពាល់ដល់បុគ្គលភាពរបស់អ្នកដទៃ ជាពិសេសច្បាប់បញ្ញត្តិអំពើនេះ ជា**បទជេរប្រមាថជាសាធារណៈ** ដែលចែងឲ្យផ្ដន្ទាទោសតាមមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌ។

-មានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់លើឈ្មោះ [redacted] ភេទស្រី អាយុ៥៥ឆ្នាំ ពី**បទ ជេរប្រមាថជាសាធារណៈ** ប្រព្រឹត្តនៅ ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌ។

---

[៤] សន្និដ្ឋានវាយតម្លៃ ពីអំពើរបស់ជនត្រូវចោទ ទៅលើធាតុផ្សំនៃបទល្មើស សំរាប់បញ្ជាក់ថា មានឬគ្មានពិរុទ្ធភាពគ្រប់គ្រាន់ ឬស្ពាប់ ឬគេចខ្លួនបាត់ មានឬគ្មានសាវជាតិគ្រប់គ្រាន់។

## ហេតុដូច្នេះ សម្រេច

១.ចោទប្រកាន់ឈ្មោះ [redacted] ភេទស្រី អាយុ៥៥ឆ្នាំ ទីកន្លែងកំណើតភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្ន ភូមិអូរថ្កូវ សង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] ពីបទ**ជេរប្រមាថជាសាធារណៈ** ប្រព្រឹត្តនៅ ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌ។

២.បញ្ជូនជនជាប់ចោទដូចមានឈ្មោះខាងលើ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ៤០០ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ព្រមទាំងបញ្ជីរាយនាមជនដែលជាប់ទាក់ទិនក្នុងសំណុំរឿងនេះ ទៅសាលាដំបូងខេត្តពោធិ៍សាត់ ដើម្បីជំនុំជម្រះតាមច្បាប់។

ធ្វើនៅពោធិ៍សាត់ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧

**តំណាងអយ្យការ**

[illegible]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តពោធិ៍សាត់

មន្ទីរស៊ើបសួរ( ៥ )

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៣៩៥

ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥

សំណុំរឿងស៊ើបសួរ

លេខ:២២៧

ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥

ដីកាដំណោះស្រាយ

លេខ: [illegible]

# ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

យើង ម៉ៅ ស៊ីណា ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តពោធិ៍សាត់ អមដោយលោក ប៉ុល វណ្ណា ជាក្រឡាបញ្ជី

-បានឃើញមាត្រា២៤៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ៣៩៥ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥។

-បានឃើញសំណុំរឿងស៊ើបសួរលេខ: ២២៧ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ: ៥៥៨ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦។

-បានឃើញពាក្យបណ្ដឹងរបស់ឈ្មោះ [redacted]។ (ឯកសារលេខ:១)

-បានឃើញចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]។ (ឯកសារលេខ:២១)

-បានឃើញចម្លើយសាក្សីឈ្មោះ [redacted]។ (ឯកសារលេខ:២១)

-បានឃើញចម្លើយជនត្រូវចោទឈ្មោះ [redacted]។ (ឯកសារលេខ:១១,១៦)

## សំអាងហេតុ

មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ មុខកសិករ ពីបទ: **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោសនាំឱ្យខូចប្រយោជន៍សំណង់គ្រឹះស្ថានសាធារណៈ** ប្រព្រឹត្តនៅភូមិអូរព្រាល ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា៤១១នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះ សម្រេច

បញ្ជូនសំណុំរឿងលេខ: ៣៩៥ និងជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ ទៅជំនុំជម្រះតាមច្បាប់។

ធ្វើនៅពោធិ៍សាត់,ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦

**ក្រឡាបញ្ជី**

ប៉ុល វណ្ណា

**ចៅក្រមស៊ើបសួរ**

ម៉ៅ ស៊ីណា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តពោធិ៍សាត់
លេខៈ ៧៤៧ ពភទ/១៧

# ដីកាសម្រេចដាក់រឿងជំនុំជំរះ

យើង **រស់ ផូរា** ចៅក្រមជំនុំជំរះនៃសាលាដំបូងខេត្តពោធិ៍សាត់ ។

ដោយមានលោក **ថុល ពិសិដ្ឋ** ជាក្រឡាបញ្ជីសវនាការសាលាដំបូងខេត្តពោធិ៍សាត់អមផង ។

-បានឃើញមាត្រា ២៩២ និងមាត្រា ២៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខៈនស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ខែសីហា ឆ្នាំ ២០០៧ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ៖ ២៣៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ។

-បានឃើញដីកាបញ្ជូនសំណុំរឿងទៅជំនុំរះលេខៈ ២៨៤ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តពោធិ៍សាត់។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ៖ ៧៨ ពស/១៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តពោធិ៍សាត់។

## ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

## សម្រេច

បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ២៣៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ទាំងមូលទៅព្រះរាជអាជ្ញាអមសាលាដំបូងខេត្តពោធិ៍សាត់ ដើម្បីចាត់ការតាមនីតិវិធី ដោយកំណត់កាលបរិច្ឆេទសវនាការនៅថ្ងៃទី០៧ ខែ**វិច្ឆិកា** ឆ្នាំ២០១៧ វេលាម៉ោង ៩ និង ០០ នាទីព្រឹក ។

## ចៅក្រមជំនុំជម្រះ

-លោកស្រី **រស់ ផូរា** ចៅក្រមនៃសាលាដំបូងខេត្តពោធិ៍សាត់។

## តំណាងអយ្យការ

-លោក **ឆាយ ហុង** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

## ក្រឡាបញ្ជីសវនាការ

-លោក **ថុល ពិសិដ្ឋ** ក្រឡាបញ្ជីនៃសាលាដំបូងខេត្តពោធិ៍សាត់។

ពោធិ៍សាត់, ថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៧

**ក្រឡាបញ្ជីសវនាការ**

ថុល ពិសិដ្ឋ

**ចៅក្រមជំនុំជម្រះ**

រស់_ផូរា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់
លេខ...៧២៣...ព.អ.ព/១៨

## ដីកាបញ្ជូន

### ផ្ញើជូន លោកស្នងការនគរបាលខេត្តពោធិ៍សាត់

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១ | ដីកាកោះហៅឲ្យចូលសវនាការឈ្មោះ [redacted] ភេទស្រី អាយុ ៤៤ ឆ្នាំ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ៥៖០០ នាទីព្រឹក | ០២ សន្លឹក | ដើម្បីចាត់ការតាមនីតិវិធី។ |
| ០២ | ដីកាកោះហៅឲ្យចូលសវនាការឈ្មោះ [redacted] ភេទស្រី អាយុ ៤៩ ឆ្នាំ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ៥៖០០ នាទីព្រឹក | ០២ សន្លឹក | |
| ០៣ | ដីកាកោះហៅឲ្យចូលសវនាការឈ្មោះ [redacted] ភេទស្រី អាយុ ៣៩ ឆ្នាំ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ៥៖០០ នាទីព្រឹក | ០២ សន្លឹក | |
| ០៤ | ដីកាកោះហៅឲ្យចូលសវនាការឈ្មោះ [redacted] ភេទស្រី អាយុ ៤៨ ឆ្នាំ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ៥៖០០ នាទីព្រឹក | ០២ សន្លឹក | |
| | សរុប | ០២ សន្លឹក | |

ថ្ងៃ......................ខែ..........ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ខេត្តពោធិ៍សាត់, ថ្ងៃទី......ខែ..........ឆ្នាំ២០១៧

តំណាងអយ្យការ

លី_តារ៉ា

10 - 01 - 2018

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់
លេខៈ ២៥៣ ដ.ស

# ដីកាសម្រេចបញ្ជូនជាប់ចោទមកជំនុំជម្រះ

យើង **ឆាយ ហុង** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ។

ក្រោយពីបានពិនិត្យសំណុំរឿងព្រហ្មទណ្ឌលេខ ២៣៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ភេទប្រុស អាយុ ២១ ឆ្នាំ រស់នៅភូមិកណ្តាល ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ ឃុំខ្លួននៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦។

២-ឈ្មោះ [redacted] ភេទប្រុស អាយុ ៣១ ឆ្នាំ រស់នៅភូមិកណ្តាល ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ ឃុំខ្លួននៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦។

ជាប់ចោទពីបទ លួច និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាកែវលើ ឃុំត្នោតជុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ ២៥ ឆ្នាំ រស់នៅភូមិកណ្តាល ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ ឃុំខ្លួននៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦។

ជាប់ចោទពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិតាកែវលើ ឃុំត្នោតជុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤២** និងមាត្រា **៤៥ នៃច្បាប់ស្តីពី**ការត្រួតពិនិត្យគ្រឿងញៀន។

## ហេតុដូច្នេះសម្រេច

ក-ឲ្យជនជាប់ចោទឈ្មោះ ៖

១-ឈ្មោះ [redacted] ភេទប្រុស អាយុ ២១ ឆ្នាំ

២-ឈ្មោះ [redacted] ភេទប្រុស អាយុ ៣១ ឆ្នាំ

៣-ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ ២៥ ឆ្នាំ

ទៅកាន់សាលាដំបូងខេត្ត ពោធិ៍សាត់ ទីកន្លែងជំនុំជម្រះសវនាការនៅថ្ងៃទី **២៧** ខែ កក្កដា ឆ្នាំ **២០១៧** វេលាម៉ោង ៨៖០០ នាទីព្រឹក ដើម្បីជំនុំជម្រះ ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តពោធិ៍សាត់**

សំណុំរឿងព្រហ្មទណ្ឌលេខ ៤០០
ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦

# ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

**យើង ឆាយ ហុង តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់**

**បានបញ្ជាឲ្យចូលទៅបង្ហាញខ្លួននៅសមនាការ:**

នាមត្រកូល ៖ [redacted] នាមខ្លួន ៖ [redacted] ភេទស្រី
អាយុ ៖ ៥៥ឆ្នាំ
ទីកន្លែងកំណើត ៖ ភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល។
លំនៅបច្ចុប្បន្ន ៖ ភូមិអូរថ្កូវ ឃុំរលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ។
មុខរបរ ៖ ធ្វើចំការ
សញ្ជាតិ ៖ ខ្មែរ
នៅលីវ ឬ ☑រៀបការ ប្ដីឈ្មោះ [redacted] មានកូនចំនួន ០១នាក់។
ឪពុកឈ្មោះ ៖ [redacted] "ស្លាប់" ម្ដាយឈ្មោះ ៖ [redacted] "ស្លាប់" ។
អនីតិជន☐ ឬ ជានីតិជន☑ ទោសពីមុន ៖ គ្មាន ។

***អ្នកត្រូវបានចោទប្រកាន់ពីអង្គហេតុ:***

កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង១០ព្រឹក ដើមបណ្ដឹងឈ្មោះ [redacted] ភេទប្រុស អាយុ៥១ឆ្នាំ រស់នៅភូមិបណ្ដុះសណ្ដែក សង្កាត់បន្ទាយដី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ បានជិះម៉ូតូជាមួយឈ្មោះ [redacted] និងឈ្មោះ [redacted] ទៅមើលដីស្ថិតនៅក្នុងភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ពេលទៅដល់ទីតាំងដី ស្រាប់តែមានជនសង្ស័យឈ្មោះ [redacted] ភេទស្រី អាយុ៥៥ឆ្នាំ រស់នៅភូមិអូរថ្កូវ សង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ បានដើរមកចង្អុលភ្នែករបស់ដើមបណ្ដឹង ហើយស្រែកជេរថា៖ "មីជីដូនជីតាអ្ហែងនៅទីនេះ កន្ទួយម៉ែអ្ហែងដីនេះជាដីម៉ែអ្ហែងអី ដីនេះជាដីអញទេ អាចុយម្រាយគ្មានដីនៅចំនុចស្រែខ្នង ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ទីនោះទេ" ហើយបានចង្អុលមុខដើមបណ្ដឹង ហើយជេរផង ជេរពាក្យដដែលៗ ហើយខ្លាំងៗ។ ករណីនេះត្រូវបានដើមបណ្ដឹងសម្រេចដាក់ពាក្យប្ដឹងមកតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់។ល

អំពើប្រព្រឹត្តរបស់អ្នកខាងលើជាបទ **ធ្វេសប្រហែសធ្វើឲ្យមានបញ្ហាសាធារណៈ** ប្រព្រឹត្តនៅ ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌឈើ។

សវនាការនៃរឿងក្តីនេះ នឹងប្រព្រឹត្តទៅនៅ*ថ្ងៃទី...........ខែ...........ឆ្នាំ២០១៧ វេលាម៉ោង........* នៅសាលសវនាការនៃសាលាដំបូងខេត្តពោធិ៍សាត់។

## សមាសភាពតុលាការជំនុំជម្រះ

១. លោក ........................... ជាចៅក្រមជំនុំជម្រះ

២. លោក ........................... ជាតំណាងអយ្យការ

៣. លោក .......................... ជាក្រឡាបញ្ជី។

សាមីខ្លួនអាចពឹងមេធាវីឱ្យអមខ្លួនបាន។

សាមីខ្លួនត្រូវបង្ហាញខ្លួនឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងជីវភាពសាមីខ្លួន ឬដំណើររឿងខាងលើមកជាមួយផង ប្រសិនបើមាន។

*ធ្វើនៅពោធិ៍សាត់, ថ្ងៃទី .១៣. ខែ.ឧសភា.ឆ្នាំ២០១៧*

**តំណាងអយ្យការ**

ភាយ ឡុង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់
លេខ: [illegible]/១៨

# ដីកាកោះហៅជនជាប់ចោទឱ្យចូលរួមសវនាការ

**យើង លី សារ៉ា** តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

-បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ៣៩៥ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥។

-យោងដីកាសម្រេចបញ្ជូនរឿងជំនុំជម្រះលេខ ៖ ៧៤៦ ពសព្រទ/១៦ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តពោធិ៍សាត់ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ ឆ្នាំ (ក្រៅឃុំ) ទៅតុលាការព្រហ្មទណ្ឌនៃសាលាដំបូងខេត្តពោធិ៍សាត់ដើម្បីជំនុំជំរះពីបទ ៖ **ធ្វើឱ្យខូចខាតដោយចេតនា** (មានស្ថានទម្ងន់ទោសនាំឱ្យខូចប្រយោជន៍សំណង់គ្រឹះស្ថានសាធារណ:) ប្រព្រឹត្តនៅភូមិអូរព្រាល ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា **៤១១ នៃក្រមព្រហ្មទណ្ឌ**។

បង្គាប់មកជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ ឆ្នាំ (ក្រៅឃុំ) មានទីលំនៅបច្ចុប្បន្ននៅភូមិអូរព្រាល ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

ឱ្យចូលទៅកាន់ទីកន្លែងសាលសវនាការ នៃសាលាដំបូងខេត្តពោធិ៍សាត់ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ៩៖០០ នាទីព្រឹក ជាកំហិតដើម្បីធ្វើការជំនុំជំរះ។

**ចៅក្រមជំនុំជំរះ**

-**លោកស្រី រស់ ផុន** ចៅក្រមនៃសាលាដំបូងខេត្តពោធិ៍សាត់។

**តំណាងអយ្យការ**

-**លោក លី សារ៉ា** ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

**ក្រឡាបញ្ជីសវនាការ**

-**លោក ថុល ពិសិដ្ឋ** ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តពោធិ៍សាត់។

ថ្ងៃ.........ខែ.........ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ពោធិ៍សាត់, ថ្ងៃទី ០៨ ខែ......... ឆ្នាំ២០១៨
**តំណាងអយ្យការ**

លី សារ៉ា

យើង.................................បានប្រគល់ដីកាកោះនេះដល់
ឈ្មោះ..................................................ទីលំនៅ
ភូមិ.................................
ឃុំ....................................
ស្រុក.............................ខេត្ត...............................
នៅថ្ងៃទី.....ខែ............ឆ្នាំ២០........ផ្ទាល់ដៃរួចហើយ។
ធ្វើនៅថ្ងៃទី...........ខែ................ឆ្នាំ២០.......................
**អ្នកទទួល** **អ្នកប្រគល់**

អំពើប្រព្រឹត្តរបស់អ្នកខាងលើជាបទ **ជេរប្រមាថជាសាធារណៈ** ប្រព្រឹត្តនៅ ភូមិសាយ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌឈើ។

សវនាការនៃរឿងក្តីនេះ នឹងប្រព្រឹត្តទៅនៅ***ថ្ងៃទី...........ខែ...........ឆ្នាំ២០១៧ វេលាម៉ោង........*** នៅសាលសវនាការនៃសាលាដំបូងខេត្តពោធិ៍សាត់។

## សមាសភាពតុលាការជំនុំជម្រះ

១. លោក .......................... ជាចៅក្រមជំនុំជម្រះ

២. លោក .......................... ជាតំណាងអយ្យការ

៣. លោក .......................... ជាក្រឡាបញ្ជី។

សាមីខ្លួនអាចពឹងមេធាវីឲ្យអមខ្លួនបាន។

សាមីខ្លួនត្រូវបង្ហាញខ្លួនឲ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងជីវភាពសាមីខ្លួន ឬដំណើររឿងខាងលើមកជាមួយផង ប្រសិនបើមាន។

*ធ្វើនៅពោធិ៍សាត់, ថ្ងៃទី .១៣. ខែឧសភាឆ្នាំ២០១៧*

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់
លេខ: ១១.០៩.៤.៥ អយ/១៧

# <u>ដីកាបង្គាប់ឲ្យនាំជនជាប់ចោទទៅតុលាការ</u>

យើង **ឆាយ ហុង** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ។

បង្គាប់មកលោក ប្រធានពន្ធនាគារខេត្តពោធិ៍សាត់ ឲ្យនាំជនជាប់ចោទមានឈ្មោះដូចខាងក្រោមនេះ ទៅកាន់សាលាដំបូងខេត្តពោធិ៍សាត់ នៅថ្ងៃទី០៧ **ខែវិច្ឆិកា ឆ្នាំ២០១៧** វេលាម៉ោង ០២:០០ នាទីរសៀល ដើម្បីជំនុំជំរះ ។

| ល.រ | នាមត្រកូល-នាមខ្លួន | បទល្មើស ថ្ងៃ ខែ ឆ្នាំ ប្រព្រឹត្តបទល្មើស | លេខ ថ្ងៃ ខែ ឆ្នាំ ឃុំខ្លួន |
|---|---|---|---|
| ០១ | ឈ្មោះ [redacted] ភេទប្រុស អាយុ ២១ឆ្នាំ | លួច,ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។ | ៣៥១ (២១.០៦.១៦) |
| ០២ | ឈ្មោះ [redacted] ភេទប្រុស អាយុ ៣១ ឆ្នាំ | | ៣៥៣ (២១.០៦.១៦) |
| ០៣ | ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ ២១ ឆ្នាំ | ប្រព្រឹត្តនៅភូមិតាកែវលើ ឃុំត្នោតជ្រុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១៦ ។ | ៥៣៦ (០១.១២.១៦) |

យើង...........................ប្រធានពន្ធនាគារខេត្តពោធិ៍សាត់ សូមបញ្ជាក់ថា ឈ្មោះ ខាងលើនេះពិត ជាបានជាប់ឃុំឃាំងនៅមន្ទីររបស់យើងប្រាកដមែន ហើយយើងនិងចាត់ការបញ្ជូនឲ្យបានទាន់ពេលវេលា តាមការកំណត់របស់តុលាការ ។

ពោធិ៍សាត់.ថ្ងៃទី..........ខែ........ឆ្នាំ ២០១៥

**ប្រធានមន្ទីរឃុំឃាំង**

ពោធិ៍សាត់, ថ្ងៃទី១៨ខែតុលា ឆ្នាំ២០១៧

**តំណាងអយ្យការ**

ឆាយ ហុង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| អធិការដ្ឋាននគរបាលស្រុកភ្នំក្រវាញ ផ្នែកសេនាធិការ | |
|---|---|
| ចូល | លេខ 031 |
| | ថ្ងៃទី 19 ខែ 01 ឆ្នាំ 2018 |
| | វេលាម៉ោង 4:00 ... |

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់
លេខ: ......... ...

# ដីកាកោះហៅសាក្សីឱ្យចូលរួមសវនាការ

យើង **លី តារ៉ា** តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

-បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ៣៩៥ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥។

-យោងដីកាសម្រេចបញ្ជូនរឿងជំនុំជម្រះលេខ ៖ ៧៤៦ ពសព្រទ/១៦ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តពោធិ៍សាត់ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ ឆ្នាំ (ក្រៅឃុំ) ទៅតុលាការព្រហ្មទណ្ឌនៃសាលាដំបូងខេត្តពោធិ៍សាត់ដើម្បីជំនុំជំរះពីបទ ៖ **ធ្វើឱ្យខូចខាតដោយចេតនា (មានស្ថានទម្ងន់ទោសនាំឱ្យខូចប្រយោជន៍សំណង់គ្រឹះស្ថានសាធារណៈ)** ប្រព្រឹត្តនៅភូមិអូរព្រាល ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា **៤១១ នៃក្រមព្រហ្មទណ្ឌ**។

អញ្ជើញឈ្មោះ [redacted] ភេទស្រី អាយុ [redacted] ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិអូរព្រាល ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

ឱ្យចូលទៅកាន់ទីកន្លែងសាលសវនាការ នៃសាលាដំបូងខេត្តពោធិ៍សាត់ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ៨៖០០ នាទីព្រឹក ជាកំហិតដើម្បីធ្វើការជំនុំជំរះ។

## ចៅក្រមជំនុំជំរះ

-**លោកស្រី រស់ ផូរ៉ា** ចៅក្រមនៃសាលាដំបូងខេត្តពោធិ៍សាត់។

## តំណាងអយ្យការ

-**លោក លី តារ៉ា** ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

## ក្រឡាបញ្ជីសវនាការ

-**លោក ថុល ពិសិដ្ឋ** ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តពោធិ៍សាត់។

ថ្ងៃ......ខែ......ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ពោធិ៍សាត់, ថ្ងៃទី......ខែ......ឆ្នាំ២០១៨
**តំណាងអយ្យការ**

លី តារ៉ា

យើង......បានប្រគល់ដីកាកោះនេះដល់
ឈ្មោះ [redacted]......ទីលំនៅ
ភូមិ......
ឃុំ......
ស្រុក......ខេត្ត......
នៅថ្ងៃទី......ខែ......ឆ្នាំ២០18...ផ្ទាល់ដៃរួចហើយ។
ធ្វើនៅថ្ងៃទី......ខែ......ឆ្នាំ២០18......

**អ្នកទទួល** **អ្នកប្រគល់**

[redacted] [redacted]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តពោធិ៍សាត់

លេខ: [illegible]

## ដីកាកោះហៅ

## ដើមបណ្តឹងរដ្ឋប្បវេណីឱ្យចូលរួមសវនាការ

**យើង លី សារ៉ា** តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

-បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ៣៩៥ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥។

-យោងដីកាសម្រេចបញ្ជូនរឿងជំនុំជម្រះលេខ ៖ ៧៤៦ ពសព្រទ/១៦ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តពោធិ៍សាត់ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ ឆ្នាំ (ក្រៅឃុំ) ទៅតុលាការព្រហ្មទណ្ឌនៃសាលាដំបូងខេត្តពោធិ៍សាត់ដើម្បីជំនុំជំរះពីបទ ៖ **ធ្វើឱ្យខូចខាតដោយចេតនា (មានស្ថានទម្ងន់ទោសនាំឱ្យខូចប្រយោជន៍សំណង់គ្រឹះស្ថានសាធារណៈ)** ប្រព្រឹត្តនៅភូមិអូរព្រាល ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា **៤១១ នៃក្រមព្រហ្មទណ្ឌ**។

អញ្ជើញឈ្មោះ [redacted] ភេទប្រុស អាយុ ៥០ ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិអូរព្រាល ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

ឱ្យចូលទៅកាន់ទីកន្លែងសាលសវនាការ នៃសាលាដំបូងខេត្តពោធិ៍សាត់ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ៩៖០០ នាទីព្រឹក ជាកំហិតដើម្បីធ្វើការជំនុំជំរះ។

### ចៅក្រមជំនុំជំរះ

**-លោកស្រី រស់ ផុន** ចៅក្រមនៃសាលាដំបូងខេត្តពោធិ៍សាត់។

### តំណាងអយ្យការ

**-លោក លី សារ៉ា** ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

### ក្រឡាបញ្ជីសវនាការ

**-លោក ថុល ពិសិដ្ឋ** ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តពោធិ៍សាត់។

ថ្ងៃ[illegible]ខែ[illegible]ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ពោធិ៍សាត់, ថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ២០១៨

**តំណាងអយ្យការ**

លី សារ៉ា

យើង..................................បានប្រគល់ដីកាកោះនេះដល់

ឈ្មោះ.....................................................ទីលំនៅ

ភូមិ.................................

ឃុំ...................................

ស្រុក.............................ខេត្ត.................................

នៅថ្ងៃទី.....ខែ............ឆ្នាំ២០........ផ្ទាល់ដៃរួចហើយ។

ធ្វើនៅថ្ងៃទី...........ខែ................ឆ្នាំ២០.......................

**អ្នកទទួល** **អ្នកប្រគល់**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តពោធិ៍សាត់

លេខ ១៤៧ ពស/១៧

# ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះ

យើង **អ៊ិត សម្ផស្ស** ប្រធានសាលាដំបូងខេត្ត **ពោធិ៍សាត់**

បានឃើញដីកាសម្រេចលេខ៤៨៩ ពស.ព្រទ/១៧ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ របស់ប្រធានសាលាដំបូងខេត្តពោធិ៍សាត់។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ២៦០ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

បានឃើញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៣៩៧ ពស.ព្រទ/១៧ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ របស់លោកចៅក្រមស៊ើបសួរ ដែលសម្រេចបញ្ជូនៈ

១-ឈ្មោះ [redacted] ភេទប្រុស អាយុ២០ ឆ្នាំ ជាតិខ្មែរ

២-ឈ្មោះ [redacted] ភេទប្រុស អាយុ៤៤ ឆ្នាំ ជាតិខ្មែរ

ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនច្រើនដង, ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនច្រើនដង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ កាលពីអំឡុងខែមិថុនា ឆ្នាំ២០១៦។

## សម្រេចចាត់តាំង

១- លោកស្រី រស់ ផូវា ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

២- លោក មៅ ស៊ីណា ជាចៅក្រមប្រឹក្សា

៣- លោក សុន នាថធារី ជាចៅក្រមប្រឹក្សា

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ២៦០ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ ។

ពោធិ៍សាត់, ថ្ងៃទី[illegible] ខែមេសា ឆ្នាំ២០១៧

អ៊ិត.សម្ផស្ស

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តពោធិ៍សាត់**

**លេខ:** ៧៩៣៦ អ.ម.ស.ពស/១៨

## <u>ដីកាអញ្ជើញឲ្យចូលសវនាការ</u>

យើង **លី តារ៉ា** ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្ត ពោធិ៍សាត់ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ២៦០ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ របស់សាលាដំបូងខេត្តពោធិ៍សាត់ ។

បានឃើញដីកាសម្រេចដាក់រឿងជំនុំជម្រះលេខ ........ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៨ របស់សាលាដំបូងខេត្តពោធិ៍សាត់ ។

អញ្ជើញលោក [redacted] ជានាយផ្នែកនគរបាលយុត្តិធម៌ ។

ឲ្យចូលទៅកាន់សាលាដំបូងខេត្តពោធិ៍សាត់ នៅថ្ងៃទី២៨ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ០៩ និង ០០ នាទីព្រឹក ជាកំហិត ដើម្បីចូលរួមសវនាការ ។

ពីដំណើររឿង ១-ឈ្មោះ [redacted] ភេទ ប្រុស អាយុ ២០ឆ្នាំ ២-ឈ្មោះ [redacted] ភេទ ប្រុស អាយុ ៥៨ឆ្នាំ ជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនច្រើនដង, ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនច្រើនដង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ កាលពីអំឡុងខែ មិថុនា ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា៤០ កថាខណ្ឌទី៥ ចំណុចទី១ មាត្រា៤២ កថាខណ្ឌទី៣ ចំណុចទី១និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**សមាសភាពជំនុំជម្រះ**

| | |
|---|---|
| -លោកស្រី **រស់ ផូរ៉ា** | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| -លោក **សុន នាថធាវី** | ចៅក្រុមប្រឹក្សា |
| -លោក **ម៉ៅ ស៊ីណា** | ចៅក្រុមប្រឹក្សា |
| -លោក **លី តារ៉ា** | តំណាងអយ្យការ |
| -លោក **ថុល ពិសិដ្ឋ** | ក្រឡាបញ្ជីសវនាការ |

ថ្ងៃ ៧ ៤ ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ពោធិ៍សាត់ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៨

**ព្រះរាជអាជ្ញារង**

លី តារ៉ា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់
លេខ: ១៤០៧ អ.យ/១៨

# ដីកាកោះហៅជនចោទឱ្យចូលរួមសវនាការ

**យើង លី តារ៉ា** តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ២៨៦ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៩។

-បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-យោងដីកាសម្រេចបញ្ជូនរឿងជំនុំជម្រះ ៖ ២៩៦៨ ពស១២ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តពោធិ៍សាត់ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៣ ឆ្នាំ (ក្រៅឃុំ) ទៅតុលាការព្រហ្មទណ្ឌនៃសាលាដំបូងខេត្តពោធិ៍សាត់ដើម្បីជំនុំជំរះពីបទ ៖ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិចំការចេកខាងជើង សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៩ តាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

អញ្ជើញឈ្មោះ [redacted] ភេទប្រុស អាយុ ៣១ ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិពោធិ៍តាគួយ សង្កាត់លលកស ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

ឱ្យចូលទៅកាន់ទីកន្លែងសាលសវនាការ នៃសាលាដំបូងខេត្តពោធិ៍សាត់ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ វេលាម៉ោង ៩៖០០ នាទីព្រឹកជាកំហិត ដើម្បីធ្វើការជំនុំជំរះ។

**ចៅក្រមជំនុំជំរះ**

-**លោកស្រី រស់ ផុន** ចៅក្រមនៃសាលាដំបូងខេត្តពោធិ៍សាត់។

**តំណាងអយ្យការ**

-**លោក លី តារ៉ា** ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

**ក្រឡាបញ្ជីសវនាការ**

-**លោក ថុល ពិសិដ្ឋ** ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តពោធិ៍សាត់។

ថ្ងៃ[illegible]ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ខេត្តពោធិ៍សាត់, ថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ២០១៨

**តំណាងអយ្យការ**

លី តារ៉ា

យើង..................................បានប្រគល់ដីកាកោះនេះដល់
ឈ្មោះ....................................................ទីលំនៅ
ភូមិ..................................
ឃុំ....................................
ស្រុក..............................ខេត្ត.................................
នៅថ្ងៃទី.....ខែ............ឆ្នាំ២០........ផ្ទាល់ដៃរួចហើយ។
ធ្វើនៅថ្ងៃទី...........ខែ................ឆ្នាំ២០.......................

**អ្នកទទួល** **អ្នកប្រគល់**

ខ-សមាសភាពក្រុមជំនុំជម្រះ

-លោកស្រី **រស់ ផ្ទរា** ចៅក្រមជំនុំជំរះ

-លោក **ឆាយ ហុខ** តំណាងអយ្យការ

-លោក **ថុល ពិសិដ្ឋ** ក្រឡាបញ្ជីសវនាការ

គ-ឲ្យដំណឹងទៅជនជាប់ចោទពីសិទ្ធិរបស់ខ្លួន នៅចំពោះមុខតុលាការដូចតទៅ ៖

-សិទ្ធិទទួលដឹងពីដីកាសន្និដ្ឋានស្ថាពរ និង ដីកាកោះឲ្យចូលសវនាការ

-សិទ្ធិបង្ហាញភស្តុតាង សំអាងសាក្សី ឬ ធ្វើសំណូមពរផ្សេងៗ

-សិទ្ធិប្តឹងជំទាស់ចៅក្រមជំនុំជម្រះ

-សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬ ពឹងឲ្យមេធាវីការពារខ្លួន

ពោធិ៍សាត់, ថ្ងៃទី ១៦ ខែ ... ឆ្នាំ ២០១៧

**តំណាងអយ្យការ**

ឆាយ ហុខ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តពោធិ៍សាត់

# កំណត់ហេតុស្ដីពីការធ្វើសម្បថ

សំណុំរឿងព្រហ្មទណ្ឌលេខ...០៩.......ចុះថ្ងៃទី...០៩...ខែ...មករា.....ឆ្នាំ...២០១៧.....។

ឆ្នាំពីរពាន់...ដប់ប្រាំពីរ.....ខែ...កុម្ភៈ.....ថ្ងៃទី...ម្ភៃមួយ...វេលាម៉ោង...ពីរ.....និង...សាមសិបនាទី រសៀល.....។

យើង [redacted] ក្រឡាបញ្ជីអមសាលាដំបូងខេត្តពោធិ៍សាត់ បានដឹកនាំឱ្យឈ្មោះ [redacted]...........ភេទ...ប្រុស...អាយុ...51...ឆ្នាំ សញ្ជាតិ...ខ្មែរ.....សាសនា...ព្រះពុទ្ធ...មានទីលំនៅបច្ចុប្បន្ន នៅភូមិ...ភពាល.....ឃុំ/សង្កាត់...ត្រពាំង........ស្រុក/ក្រុង...អន្លង់វែង...ខេត្ត...ឧត្តរមានជ័យ.......មុខរបរ...ធ្វើស្រែ.....ជា...សាក្សី......... ធ្វើសច្ចាប្រណិធាន នៅចំពោះមុខវត្ថុស័ក្តិសិទ្ធិនៃសាលាដំបូងខេត្តពោធិ៍សាត់។

ក្រោយពីអ្នកស្បថបានអុជទៀន ធូប បូជាចំពោះមុខវត្ថុស័ក្តិសិទ្ធិរួចហើយ យើងបានអានប្រាប់ព្ធវាទ ខ្លាំងៗ ច្បាស់ៗ ឱ្យអ្នកស្បថស្ដាប់ រួចអានពាក្យសច្ចាប្រណិធានឱ្យអ្នកស្បថថាតាមដែលមានសេចក្ដីដូចខាងក្រោម៖

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និងចាំផ្ទាល់។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេវព្រឹក្ស អារក្សអ្នកតា និងបារមីដ៏ស័ក្តិសិទ្ធិទាំងអស់បរាមុខខ្ញុំ ឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំ មានទ្រព្យសម្បត្តិហូរហៀរ និងរស់នៅប្រកបដោយមានសេចក្ដីសុខក្សេមក្សាន្ត ជួបជុំបងប្អូន កូនចៅ ញាតិផៅសណ្ដាន ជារៀងរហូតគ្រប់ជាតិ កុំបីអាក់ខានឡើយ។

ពាក្យសច្ចាប្រណិធានខាងលើនេះ ឈ្មោះ..[redacted]..............បានថាតាមយើងយ៉ាងច្បាស់ៗ គ្មានចន្លោះពាក្យត្រង់ណាមួយឡើយ។

បញ្ចប់កំណត់ហេតុនេះនៅវេលាម៉ោង...ពីរ...ដប់...សាមសិបប្រាំនាទី.....ថ្ងៃ ខែ ឆ្នាំ ដដែលហើយបាន អានឱ្យឈ្មោះខាងលើស្ដាប់ ឆ្លើយថាត្រឹមត្រូវ និងយល់ព្រមផ្តិតមេដៃជាមួយយើង។

| | |
|---|---|
| **អ្នកស្បថ** | **ក្រឡាបញ្ជី** |
| [redacted] | ជុល ពិសិដ្ឋ |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តពោធិ៍សាត់

**<u>បញ្ជីវត្តមានពេលសវនាការ</u>**

សំណុំរឿងព្រហ្មទណ្ឌលេខ ០៩ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧

| ល.រ | ឈ្មោះជនជាប់ទាក់ទិន | ត្រូវជា | ស្នាមមេដៃ ឬហត្ថលេខា |
|---|---|---|---|
| ០១ | [redacted] | ជនជាប់ចោទ | |
| ០២ | [redacted] | មេធាវី | [redacted] |
| ០៣ | [redacted] | មេធាវី | |
| ០៤ | [redacted] | សាក្សី | |
| ០៥ | [redacted] | សាក្សី | |
| ០៦ | [redacted] | សាក្សី | |

ថ្ងៃ.........ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ពោធិ៍សាត់, ថ្ងៃទី២១..ខែកុម្ភៈ ឆ្នាំ២០១៨

**ក្រឡាបញ្ជី**

ថុល ពិសិដ្ឋ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តពោធិ៍សាត់**
សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៥
ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤
**សាលក្រមព្រហ្មទណ្ឌ**
**លេខ: ១៧០ (ខ)**
ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨

*តាងនាមប្រជារាស្ត្រខ្មែរ*

*សាលាដំបូងខេត្តពោធិ៍សាត់*

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង ពីរ និងសូន្យនាទីរសៀល។

ដោយមានសមាសភាពដូចខាងក្រោម:

**ចៅក្រមជំនុំជម្រះ**

-លោកស្រី **រស់ ផូរ៉ា** ចៅក្រមនៃសាលាដំបូងខេត្តពោធិ៍សាត់។

**តំណាងអយ្យការ**

-លោក **លី ភារ៉ា** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

**ក្រឡាបញ្ជីសវនាការ**

-លោក **ឌុល ពិសិដ្ឋ** ក្រឡាបញ្ជីសវនាការនៃសាលាដំបូងខេត្តពោធិ៍សាត់។

ដើម្បីធ្វើការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៥ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ដែលមានជនជាប់ចោទឈ្មោះ៖

-ឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ ទំលំនៅបច្ចុប្បន្នភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់។

ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទ ហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌ មានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ៣៨ ឆ្នាំ រស់នៅភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់។

**អង្គហេតុមានដូចតទៅ:**

កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០១៤ ឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ ឆ្នាំ រស់នៅភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ បានឈ្លោះប្រកែកគ្នាជាមួយឈ្មោះ [redacted] ហើយ [redacted] ក៏បាន [redacted] ទៅវាយ លើឈ្មោះ [redacted] ជាច្រើនដៃហើយបន្ទាប់មកក៏បានអ្នកជិតខាងជួយចាប់បំបែក លុះម៉ោង ប្រហែលជា ៩

យប់ ពេលនោះឈ្មោះ [redacted] ដើរត្រលប់មកផ្ទះវិញក៏ស្រាប់តែឈ្មោះ [redacted] កាន់ដំបងមកវាយឈ្មោះ [redacted] ពីក្រោយត្រូវជាច្រើនដំបងបណ្តាលឱ្យបែកចញ្ចើមខាងស្តាំហូរឈាម ហើយជនត្រូវចោទក៏បានរត់គេចខ្លួនបាត់។

## នាពេលសវនាការ

-ក្រោយពីដំណើរការនៃកិច្ចពិភាក្សាដេញដោល

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យឯកសារដែលមាននៅក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>សាលាដំបូងខេត្តពោធិ៍សាត់ យល់ឃើញថា:</u>

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ឆ្នាំ ដែលបានប្រព្រឹត្តកាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ នៅភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ គឺជាអំពើហិង្សាស្រាលបំពានដោយចេតនាលើមាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌ។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថា: កាលពីថ្ងៃខែឆ្នាំមិនចាំ ឈ្មោះ [redacted] បានចូលមកលួចវាយប្តី ខ្លួនពីក្រោយបណ្តាលឱ្យបាក់ឆ្អឹងជំនី ពេលដែលគេវាយប្តីខ្លួនរួចហើយជននោះក៏រត់គេចខ្លួនបាត់។ ប៉ុន្តែសព្វថ្ងៃនេះ ឈ្មោះ [redacted] បានត្រលប់មករស់នៅផ្ទះរបស់គេវិញហើយស្ថិតនៅភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់។ ខ្លួនបានចំណាយប្រាក់អស់ ៨.០០០.០០០ (ប្រាំបីលាន) រៀល ដើម្បីព្យាបាលប្តីរបស់ខ្លួនរហូតដល់ជាសះស្បើយ។

-តាមអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បានឆ្លើយថា: កាលពីថ្ងៃខែឆ្នាំមិនចាំ វេលាម៉ោង ០៧ យប់ ខ្លួនបានទៅយកថ្លៃម្ជៀង ដែលទិញហើយភ្លេចយកនៅផ្ទះរបស់ឈ្មោះ [redacted] នៅភូមិជាមួយគ្នា ពេលដែលបានទៅដល់ក៏បានជួប នឹងឈ្មោះ [redacted] នៅទីនោះដែរ។ ស្រាប់តែឈ្មោះ [redacted] បានជេរថា "អាចុយម្រាយ អញវាយអាចុយម្រាយឥលូវ" ហើយខ្លួនក៏បានសួរវាថា "ហ្អែងជេរអាណា បើទីនេះមនុស្សចាស់មានតែអញហ្នឹង" ក៏បណ្តាលឱ្យទាស់សំដីគ្នា រួចឈ្មោះ [redacted] ក៏បានលោតមកវាយតប់លើខ្លួនជាច្រើនដៃ ខ្លួនក៏រត់ទៅផ្ទះឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលនៅជិតគ្នា ពេលនោះឈ្មោះ [redacted] ក៏បានវាយខ្លួននឹងដំបងត្រូវឆ្អឹងជំនី បាក់ដំបងជាពីរកំណាត់ ខ្លួនមិនបានតបវិញទេ ព្រោះខ្លួនមិនដឹងខ្លួន។ សព្វថ្ងៃឈ្មោះ [redacted] រស់នៅភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់។ បន្ទាប់ពីគេវាយខ្លួនបានដេកពេទ្យអស់រយៈពេល ០២ ខែ និងព្យាបាលអស់ប្រាក់ចំនួន ៨.០០០.០០០. (ប្រាំបីលាន) រៀល កន្លងមកខ្លួនមិនដែលមានទំនាស់គ្នាជាមួយឈ្មោះ [redacted] ទេ។

-តាមអំណានរបស់សាក្សីឈ្មោះ [redacted] បានឆ្លើយថា: កាលពីថ្ងៃ៣០ ខែកក្កដា ឆ្នាំ២០១៤ ពេលល្ងាច ឈ្មោះ [redacted] បានទិញផ្លែមៀនហើយភ្លេចយកទៅផ្ទះ រហូតដល់ម៉ោង ០៩ យប់ ឈ្មោះ [redacted] ក៏បានមកយកវិញ។ ពេលនោះឈ្មោះ [redacted] និងឈ្មោះ [redacted] បានជិះម៉ូតូមកដល់ផ្ទះខ្លួន ដោយឈ្មោះ [redacted] បានទិញស្រាបៀមួយកំប៉ុងផឹក ពេលនោះក៏បានស្រែកជេរថា "អាចុយម្រាយ អញវាយហ្វែងចុយម្រាយឥឡូវ"ឈ្មោះ [redacted] លឺជេរក៏សួរថា "ហ្វែងជេរអ្នកណា" ឈ្មោះ [redacted] ក៏បានតបថា "ខ្ញុំជេរគ្នាខ្ញុំតើ" ពេលនោះអ្នកទាំងពីរឈ្លោះគ្នានៅមុខផ្ទះរបស់ខ្លួន ស្រាប់តែឈ្មោះ [redacted] បានរត់តាមមកពីក្រោយក៏បានវាយឈ្មោះ [redacted] ជាច្រើនដៃ ពេលនោះអ្នកស្រុកក៏ចេញមក ជួយចាប់បំបែកគ្នាចេញ។ បន្ទាប់មកឈ្មោះ [redacted] ក៏បានរត់ទៅត្បូងហើយបានត្រលប់មកវិញបានយកដំបងប៉ុនកំភួនដៃ វាយទៅលើឈ្មោះ [redacted] ចំនួន ០១ ដំបងហើយក៏រត់គេចទៅត្បូងបាត់ទៅ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] បានឆ្លើយថា: កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ វេលាប្រហែលជាម៉ោង ០៩ យប់ ខ្លួនកំពុងតែសម្រាកស្រាប់តែលឺសម្លេងឡូឡានៅមុខផ្ទះខ្លួន ពេលនោះខ្លួនក៏បានស្ទុះងើបហើយបានឃើញមនុស្សពីរនាក់កំពុងវាយគ្នា ខ្លួនក៏បានចុះទៅមើលស្រាប់តែឃើញឈ្មោះ [redacted] វាយគ្នាជាមួយឈ្មោះ [redacted] ដោយដៃ និងដៃ ហើយក៏មានអ្នកភូមិជួយបំបែកផងដែរ។ ពេលនោះឈ្មោះ [redacted] ក៏បានរត់ទៅត្បូងមួយសន្ទុះក្រោយមកស្រាប់តែឈ្មោះ [redacted] បានរត់មកវិញ ដោយមានដំបងកាន់នឹងដៃក៏បានវាយទៅលើឈ្មោះ [redacted] មួយដំបងហើយក៏បានរត់គេចខ្លួនបាត់ទៅ។

-លោកតំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំនាពេលសវនាការថា ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីនាពេលសវនាការរួចមកពិនិត្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ ពិតជាបាន ប្រព្រឹត្តអំពើហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស នៅភូមិព្រៃដំរី ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ ពិតប្រាកដមែន ជាបទល្មើសដែលបញ្ញត្តិតាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។ ដោយជនជនជាប់ចោទ ឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ឆ្នាំ ជានីតិជន មានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវ ចំពោះអំពើរបស់ខ្លួនហើយមានចេតនាពិតប្រាកដក្នុងការប្រព្រឹត្តអំពើខាងលើ។ ម្យ៉ាងទៀត អំពើរបស់ជនជាប់ចោទពិតជាធ្វើឱ្យ ប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម និងប៉ះពាល់ដល់បុគ្គលភាពរបស់អ្នកដទៃ។ ប៉ុន្តែដោយសារ ជនជាប់ចោទពុំមានអត្តសញ្ញាណគ្រប់គ្រប់គ្រាន់ តុលាការគួរធ្វើការស្វែងរកអត្តសញ្ញានជនជាប់ចោទឲ្យបានច្បាស់លាស់ជាមុនសិន មុននឹងធ្វើការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។ ហេតុដូចនេះ តំណាងអយ្យការស្នើសុំឲ្យតុលាការសម្រេចចាត់របៀបដើម្បីស្រាវជ្រាវបំពេញអត្តសញ្ញាណរបស់ជនជាប់ចោទ។

## ហេតុដូច្នេះ សាលាដំបូងខេត្តពោធិ៍សាត់
## វិនិច្ឆ័យសេចក្តី

១. ចាត់របៀបដើម្បីស្រាវជ្រាវពីសាវតាជាតិរបស់ជនជាប់ចោទឈ្មោះ [redacted]។

២. ចាត់តាំងលោកស្រី [redacted] ជាចៅក្រមស៊ើបសួរដើម្បីបំពេញកិច្ចស្រាវជ្រាវនេះ។

៣. លោកស្រី [redacted] ត្រូវធ្វើការស្រាវជ្រាវឱ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន។

៤. សាលក្រមនេះជំនុំជម្រះនៅថ្ងៃ២៨ ខែកុម្ភៈ ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ កំបាំងមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។

ក្រឡាបញ្ជី

ថុល ពិសិដ្ឋ

ចៅក្រមជំនុំជម្រះ

រស់_ផូរ៉ា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តពោធិ៍សាត់**
សំណុំរឿងព្រហ្មទណ្ឌលេខ ១៤
ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០២
**សាលក្រមព្រហ្មទណ្ឌ**
**លេខ: ១៧១ (ខ)**
ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨

*តាងនាមប្រជាពលរដ្ឋខ្មែរ*
*សាលាដំបូងខេត្តពោធិ៍សាត់*
បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨
វេលាម៉ោងប្រាំបួនព្រឹក ដោយមានសមាសភាពៈ

**ចៅក្រមជំនុំជម្រះ**

-លោកស្រី **រស់ ផុន** ចៅក្រមនៃសាលាដំបូងខេត្តពោធិ៍សាត់។

**តំណាងអយ្យការ**

-លោក **លី តារ៉ា** ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់។

**ក្រឡាបញ្ជីសវនាការ**

-លោក **ថុល ពិសិដ្ឋ** ក្រឡាបញ្ជីនៃសាលាដំបូងខេត្តពោធិ៍សាត់។

ដើម្បីធ្វើការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ១៤ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ ដែលមានជនជាប់ចោទឈ្មោះ៖

-ឈ្មោះ [redacted] ភេទប្រុស អាយុ ២៣ ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិចំការចេកខាងត្បូង ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ទីលំនៅបច្ចុប្បន្ននៅភូមិចំការចេកខាងត្បូង សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ជានីតិជន ទោសពីមុន៖ គ្មាន។

-ឈ្មោះ [redacted] ភេទប្រុស អាយុ ២២ ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិពាលញែក១ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ទីលំនៅបច្ចុប្បន្ននៅភូមិពាលញែក១ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ មុខរបរ ជាងឡូរស័ព្ទ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] ជានីតិជន ទោសពីមុន៖ គ្មាន។

ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិពាលញែក១ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ២៩ ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅភូមិចំការចេកខាងត្បូង សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ និងឈ្មោះ [redacted] ភេទប្រុស អាយុ ៥១ ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ភូមិពាលញែក១ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

## អង្គហេតុមានដូចតទៅ:

កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ វេលាម៉ោងប្រហែល ៦ ល្ងាចឈ្មោះ [redacted] កំពុងតែអង្គុយហូបពងទាកូននៅចំណុចឡូទ៍ប៉ុងផ្សារចាស់ក្នុងភូមិពាលញែក១ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ស្រាប់តែមានឈ្មោះ [redacted] បានធ្វើសកម្មភាពវាយលើឈ្មោះ [redacted] ចំនួនពីរ ទៅបីដៃ និងចាប់ហែកអាវ ពេលនោះក៏មានអ្នកបំបែកចេញ ហើយក៏ត្រលប់ទៅផ្ទះរៀងខ្លួន។ លុះដល់ម៉ោងប្រហែល ៧ យប់ឈ្មោះ [redacted] កំពុងតែលេងប៊ូលនៅម្ដុំបេនឡានផ្សារចាស់ ក៏មានគេមកប្រាប់ថាមានគេវាយប្អូនរបស់ខ្លួន ឈ្មោះ [redacted] ក៏បានទៅវាយឈ្មោះ [redacted] និងឈ្មោះ [redacted] ដោយអាយក្លូមបណ្ដាលឲ្យមានរបួស រីឯឈ្មោះ [redacted] ក៏ត្រូវរបួសដែរ។

## នាពេលសវនាការ

ក្រោយពីដំណើរការនៃកិច្ចពិភាក្សាដេញដោល

ក្រោយពីបានស្ដាប់អំណានចម្លើយជនជាប់ចោទ

ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

ក្រោយពីបានស្ដាប់អំណានចម្លើយសាក្សី

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានពិនិត្យឯកសារដែលមានក្នុងសំណុំរឿងចប់សព្វគ្រប់ហើយ

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## យល់ឃើញថា:

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៣ ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ ២២ ឆ្នាំ ដែលបានប្រព្រឹត្តនៅភូមិពាលញែក១ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ គឺជាអំពើហិង្សាស្រាល ដែលបំពានលើមាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា: កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ វេលាម៉ោង ២ រសៀល ខ្លួនបានទៅលេងបុកប៊ីយ៉ាជាមួយឈ្មោះ [redacted] ក៏បានទាស់សំដីជាមួយគ្នា រួចក៏ទៅផ្ទះរៀងៗខ្លួន។ លុះម៉ោង ៧ យប់ខ្លួនបានទៅដើរលេង ក៏បានឃើញឈ្មោះ [redacted] កំពុងស៊ីពងទាកូន ខ្លួនក៏ដើរចូលទៅចាប់កអាវ និងដាល់វាមួយដៃចំផ្ទៃមុខ រួចវាក៏ប្រតាយប្រតប់ជាមួយខ្លួនវិញ ហើយវាក៏ទៅផ្ទះ ចំណែកខ្លួនមិនបានទៅណាទេ។ មួយសន្ទុះក្រោយមកឈ្មោះ [redacted] ក៏បានមកដល់ហើយក៏បានទាស់សំដីជាមួយនឹងប្អូនប្រុសរបស់ខ្លួន ហើយបានប្រតាយប្រតប់គ្នា ហើយខ្លួនក៏បានចូលទៅជួយ ម្ដាយនិងបងស្រីខ្លួនក៏បានទៅជួយចាប់បំបែក។

ឈ្មោះ [redacted] បានយកអាយកូមក្រវាយចំក្បាលរបស់បងស្រីរបស់ខ្លួន ហើយសមត្ថកិច្ចមកដល់ក៏បានចាប់ពួកខ្លួនតែម្តង។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថាៈ នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ វេលាម៉ោងប្រហែល ៦ ល្ងាច មានគេមកប្រាប់ខ្លួនថា គេវាយប្អូនរបស់ខ្លួនឈ្មោះ [redacted] នៅផ្ទះម៉ែ [redacted] ខ្លួនក៏ជិះម៉ូតូជាមួយឈ្មោះ [redacted] ពេលជិះទៅដល់មិនឃើញគេវាយគ្នាទេ ខ្លួនក៏អង្គុយនៅលើម៉ូតូ មួយសន្ទុះក្រោយមកឈ្មោះ [redacted] និងឈ្មោះ [redacted] បានដើរចូលមកវាយ ពេលនោះក៏មានការប្រតាយប្រតប់គ្នា រួចក៏មានគេចូលមកបំបែក។ ពេលដែលកំពុងប្រតាយប្រតប់ជាមួយនឹងឈ្មោះ [redacted] ខ្លួនបានយកអាយកូមក្រវាយត្រូវក្បាលរបស់បងស្រីរបស់ឈ្មោះ [redacted]។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted], ឈ្មោះ [redacted] និងសាក្សីឈ្មោះ [redacted] និងឈ្មោះ [redacted] បានឆ្លើយប្រហាក់ប្រហែលគ្នាថា ពិតជាមានករណីហិង្សាទៅវិញទៅមកពិតប្រាកដមែនដែលបង្កដោយឈ្មោះ [redacted] និងឈ្មោះ [redacted]។

-លោកតំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ នាពេលសវនាការថាៈ ផ្អែកតាមកិច្ចពិភាក្សាដេញដោលបង្ហាញថា កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ ពិតជាមានករណីហិង្សា ដែលបង្កដោយជនជាប់ចោទ ឈ្មោះ [redacted] ភេទប្រុស អាយុ ២៣ ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ ២២ ឆ្នាំ ពិតប្រាកដមែន។ ចៅក្រមស៊ើបសួរបានចេញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះកាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ មកដល់ពេលនេះមានរយៈពេល ៦ ឆ្នាំហើយ ដែលសាលាដំបូងខេត្តពោធិ៍សាត់បើកសវនាការជំនុំជម្រះលើសំណុំរឿងនេះ ដោយបទល្មើសនេះជាបទល្មើសលហុ អាជ្ញាយុកាលនៃបទល្មើសមានរយៈពេល ១ ឆ្នាំ ដូច្នេះសំណុំរឿងនេះ ផុតអាជ្ញាយុកាលនៃបទល្មើសហើយ។ តំណាងអយ្យការ ស្នើសុំឱ្យចៅក្រមសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទ តាមបញ្ញត្តិមាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-អាជ្ញាយុកាលនៃបទល្មើសដែលបានចោទប្រកាន់ខាងលើ បានកន្លងផុតទៅហើយ ហេតុដូច្នេះតុលាការ គប្បីសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទ។

## ហេតុដូច្នេះ សាលាដំបូងខេត្តពោធិ៍សាត់
## វិនិច្ឆ័យសេចក្តី

១-ឱ្យជនជាប់ចោទៈ

-ឈ្មោះ [redacted] ភេទប្រុស អាយុ ២៣ ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ)

-និងឈ្មោះ [redacted] ភេទប្រុស អាយុ ២២ ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) រួចផុតពីបទចោទ ពីបទហិង្សាស្រាល ប្រព្រឹត្តនៅភូមិពាលញែក១ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២២៨នៃក្រមព្រហ្មទណ្ឌ។

២-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជី | ចៅក្រមជំនុំជម្រះ
--- | ---
ថុល ពិសិដ្ឋ | រស់-ផូរ៉ា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តពោធិ៍សាត់**
សំណុំរឿងព្រហ្មទណ្ឌលេខៈ២១០
ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៧
លេខៈ [illegible]

# លិខិតជូនដំណឹងពីសាលក្រមកំបាំងមុខ

យើង **ថុល ពិសិដ្ឋ** ក្រឡាបញ្ជីសាលាដំបូងខេត្តពោធិ៍សាត់។

ប្រាប់មកឈ្មោះ [redacted] ហៅ [redacted] ភេទស្រី អាយុ ៣២ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិបឹងវាល ឃុំត្នោតជុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ទីលំនៅបច្ចុប្បន្ននៅភូមិបឹងវាល ឃុំត្នោតជុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ មុខរបរ ធ្វើស្រែចំការ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្តីឈ្មោះ [redacted] ហៅជា មានកូន ០៣ នាក់ ឲ្យដឹងថាតាមសាលក្រមកំបាំងមុខលេខៈ ២៣៥ (ខ) ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០១៧ របស់សាលាដំបូងខេត្តពោធិ៍សាត់ ដែលបានសម្រេចសេចក្តីដូចខាងក្រោម:

១. សម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] ភេទស្រី អាយុ ៣២ ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) ដោយពិន័យជាប្រាក់ចំនួន ១០០.០០០ (មួយសែន) រៀល តែទោសនេះត្រូវព្យួរ ពីបទ ជេរប្រមាថជាសាធារណៈ ប្រព្រឹត្តនៅភូមិបឹងវាល ឃុំត្នោតជុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ។

២. បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] សងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៣.០០០.០០០ (បីលាន) រៀល ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាប់ពីពេលសាលក្រមចូលស្ថាពរ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៧ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃពុធ ៣រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ពោធិ៍សាត់ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៨
**ក្រឡាបញ្ជីសវនាការ**

ថុល ពិសិដ្ឋ

ក្រឡាបញ្ជី ថុល ពិសិដ្ឋ
លេខទូរស័ព្ទ៖ ០៩៧ ៣១៧ ៤២៣៥

យើង......មេភូមិ [illegible]......................................

បានប្រគល់លិខិតជូនដំណឹងនេះឲ្យឈ្មោះ.......[redacted]......ទៅ [redacted]......................

ទីលំនៅបច្ចុប្បន្ននៅភូមិ.......[illegible].............ឃុំ/សង្កាត់.....[illegible]............................

ស្រុក/ខណ្ឌ...............[illegible].........................ខេត្ត/ក្រុង.......ពោធិ៍សាត់...................................

នៅថ្ងៃទី..០២...ខែ.....០៥...ឆ្នាំ ២០១៩ ផ្ទាល់រួចហើយ ហើយប្រាប់ថាបើមិនសុខចិត្តនិងដីកាសម្រេចនេះទេ ត្រូវចូលប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ឲ្យបានទាន់ពេលវេលា។

| | |
|---|---|
| **អ្នកទទួលលិខិត** | **អ្នកប្រគល់** |
| **ហត្ថលេខា ឬស្នាមមេដៃ** | **ហត្ថលេខា ឬស្នាមមេដៃ** |

ក្រឡាបញ្ជី ថុល ពិសិដ្ឋ

លេខទូរស័ព្ទ៖ ០៩៧ ៣១៧ ៤២៣៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងខេត្តស្វាយរៀង
លេខៈ២៥៧២ អ.យ/១៩

# លិខិតឲ្យដំណឹងពីការអនុវត្តប្រាក់ពិន័យ

**កម្មវត្ថុ**៖អំពីការជូនដំណឹងដល់ទណ្ឌិតត្រូវដោះលែង ដែលពុំទាន់បង់ប្រាក់ពិន័យចូលជាថវិការរដ្ឋ ។

**យោង** ÷សាលក្រមព្រហ្មទណ្ឌលេខៈ ១២៥(គ) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង ។

តបកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជូនដំណឹងលោកប្រធានពន្ធនាគារថាៈ ចំពោះទណ្ឌិតឈ្មោះ [illegible] ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារចំនួនៈ ០២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ចូលថវិការរដ្ឋចំនួនៈ ចំនួនៈ ១,០០០,០០០(មួយលាន)រៀល ពីបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិថ្នា ឃុំថ្នាធ្នង់ ស្រុករំដួល ខេត្តស្វាយរៀង កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញាត្តិមាត្រា ២១៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ទណ្ឌិតរូបនេះត្រូវផុតទោសដោះលែង នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ ហើយទណ្ឌិតឈ្មោះ [illegible] ពុំទាន់បានបង់ប្រាក់ប្រាក់ពិន័យនូវឡើយទេ ដូច្នេះសូមលោកប្រធានពន្ធនាគារ ឲ្យដំណឹងទៅដល់ទណ្ឌិតអំពីការបង់ប្រាក់ពិន័យជាមុនផង ។

អាស្រ័យដូចបាន ជូនដំណឹងខាងលើសូមលោកប្រធានពន្ធនាគារ ទទួលនូវដោយសេចក្តីរាប់អានអំពីខ្ញុំ ៕

ថ្ងៃពុធ ១កើត ខែមគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ស្វាយរៀង,ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩
គម. ព្រះរាជអាជ្ញា

[illegible]
ព្រះរាជអាជ្ញារង

គំរូលេខ០១សហវ/ចមព

26-1-0059945

1125516601500101

**ក្រសួងយុត្តិធម៌**

**អង្គភាព** [illegible]

# បង្កាន់ដៃបង់ប្រាក់

(ភ្ជាប់សំណុំរឿង)

ទទួលពី [illegible] អង្គភាព [illegible]

ចំនួនទឹកប្រាក់ជាលេខ 1 000 000 រៀល

ជាអក្សរ មួយលានរៀល

អត្ថន័យចំណូល [illegible] 436 [illegible] 9-12-2017 មាតិកាថវិកា

ថ្ងៃទី១២ ខែ១២ ឆ្នាំ២០១[illegible]

[illegible] 125(គ)

12-6-2018

អ្នកប្រមូលចំណូល

**ស៊ុំ ពេជ្រសុធារី**

បង្កាន់ដៃនេះត្រូវបានបោះពុម្ព និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមអនុក្រឹត្យលេខ៨២អនក្រ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តស្វាយរៀង
លេខ:.....៣៧៥.......អ.យ/១៩

## ដីកាបញ្ជាឲ្យបង្ខំ និងឲ្យឃុំខ្លួន
## ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តស្វាយរៀង

-បានឃើញ:មាត្រា៥២៣ មាត្រា៥២៦ និងមាត្រា៥៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស.រកត/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

-បានឃើញ:សំណុំរឿងព្រហ្មទណ្ឌលេខ: ៤៣៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ។

-បានឃើញ:សាលក្រមព្រហ្មទណ្ឌលេខ: ១២៥ (គ) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨ ។

-បានឃើញ:ដីកាបង្គាប់ឲ្យដោះលែងលេខ: ១៧៤ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ: ១២៥(គ) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង បានពិន័យលើឈ្មោះ [illegible] ឲ្យបង់ថវិការចូលរដ្ឋចំនួន: ១,០០០,០០០ (មួយលាន) រៀល ហើយឈ្មោះនេះបានបញ្ជាក់នៅក្នុងពេលឲ្យដំណឹងថា ខ្លួនពុំមានលទ្ធភាពបង់ប្រាក់ពិន័យចូលថវិការដ្ឋឡើយ គប្បីដាក់បង្ខំរូបកាយ ។

## ដើម្បីការពារផលប្រយោជន៍ នៃស្មារតីច្បាប់ឲ្យមានប្រសិទ្ធិភាព

បញ្ជាឲ្យបង្ខំ និងឲ្យឃុំខ្លួនលើឈ្មោះ [illegible] ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិថ្នា ឃុំថ្នាធ្នង់ ស្រុករំដួល ខេត្តស្វាយរៀង រយៈពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ ដល់ថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០ ដើម្បីឲ្យបង្ខំរូបកាយទារប្រាក់ពិន័យ ។

បង្គាប់ឲ្យលោកប្រធានពន្ធនាគារ ខេត្តស្វាយរៀងឃុំខ្លួនឈ្មោះ [illegible] (មានសាវតាជាតិដូចខាងលើ) តាមដីកាបញ្ជាខាងលើនេះឲ្យមានប្រសិទ្ធិភាព ។

ថ្ងៃច័ន្ទ ១៣កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ស្វាយរៀង,ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩

តប:ព្រះរាជអាជ្ញា

[illegible]

ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
ខេត្តស្វាយរៀង
លេខ: ១៧៤ អ.ឃ/១៩

**<u>ដីកាបង្គាប់ឲ្យដោះលែង</u>**

**ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តស្វាយរៀង**

**<u>-បានឃើញ:</u>** មាត្រា៤៩៦ និងមាត្រា៤៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស.រកត/០៨០៧/០២៤ ចុះថ្ងៃទី១០.០៨.២០០៧ ។

**-បានឃើញ:** សំណុំរឿងព្រហ្មទណ្ឌលេខ: ៤៣៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នា២០១៧ ។

**-បានឃើញ:** សាលក្រមព្រហ្មទណ្ឌលេខ: ១២៥ (គ) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង បានសម្រេចផ្តន្ទាទោសឈ្មោះ ដាក់ពន្ធនាគារចំនួន: ០២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ចូលថវិការរដ្ឋចំនួន: ១,០០០,០០០(មួយលាន)រៀល គិតពីថ្ងៃឃុំខ្លួនពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិថ្នា ឃុំថ្នាធ្នង់ ស្រុករំដួល ខេត្តស្វាយរៀង កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៧ បទល្មើសដែលបានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

-ទណ្ឌិតឈ្មោះ ឃុំខ្លួនថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ។

**<u>ពិនិត្យឃើញថា:</u>** ទណ្ឌិតរូបនេះបានរងទោសគ្រប់ចំនួន: ០២(មួយ)ឆ្នាំ រួចហើយ គិតចាប់ពីថ្ងៃឃុំខ្លួនថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ មកដល់ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ រួចរាល់ហើយ ។

-ទណ្ឌិតឈ្មោះ ត្រូវផុតទោសដោះលែងនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ ។

**<u>ហេតុដូច្នេះសម្រេច៖</u>**

បង្គាប់ឲ្យលោកប្រធានពន្ធនាគារខេត្តស្វាយរៀង ឲ្យដោះលែងជាបន្ទាន់នូវឈ្មោះ ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិថ្នា ឃុំថ្នាធ្នង់ ស្រុករំដួល ខេត្តស្វាយរៀង នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ ប្រសិនបើជននេះមិនត្រូវបានឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ ៕

ថ្ងៃច័ន្ទ ១៣កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ស្វាយរៀង,ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩
តប. ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

យើង.................................ប្រធានមន្ទីរឃុំឃាំងខេត្តស្វាយរៀង បានទទួលអនុវត្តដីកានេះរួចហើយ នៅថ្ងៃទី..........ខែ..........ឆ្នាំ............ហើយយើងបានប្រាប់សាមីខ្លួនថាត្រូវចូលខ្លួនចំពោះតុលាការជានិច្ចកាលណាមាន ដីកាកោះហៅតុលាការសាជាថ្មីទៀត។

ស្វាយរៀង,ថ្ងៃទី..........ខែ...........ឆ្នាំ២០១៩

**ប្រធានមន្ទីរឃុំឃាំង**